គណៈកម្មាធិការស្ត្រីកម្ពុជា

The Cambodian Committee of Women

CAMBOW

# អំពើហិង្សាប្រឆាំងនារីភេទ៖
# តើច្បាប់កម្ពុជារើសអើង
# ប្រឆាំងនារីភេទដោយរបៀបណា



របាយការណ៍ CAMBOW

ខែវិច្ឆិកា ឆ្នាំ២០០៧

គណៈកម្មាធិការស្ត្រីកម្ពុជា

The Cambodian Committee of Women

# អំពើហិង្សាប្រឆាំងនារីភេទ:

# តើច្បាប់ប្រទេសកម្ពុជារើសអើងប្រឆាំងនារីភេទដោយរបៀបណា

របាយការណ៍ CAMBOW

ខែវិច្ឆិកា ឆ្នាំ២០០៧

## គណៈកម្មាធិការស្ត្រីកម្ពុជា

គណៈកម្មាធិការស្ត្រីកម្ពុជា គឺជាក្រុមសម្ព័ន្ធភាពរវាងអង្គការមិនមែនរដ្ឋាភិបាល (NGOs) ចំនួន៣៤ ដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២000 នឹងសំរបសំរួលដោយអង្គការលីកាដូ ហើយធ្វើសកម្មភាពការងារផ្តោតជាសំខាន់លើការលើកស្ទួយបុព្វហេតុស្ត្រី។ តាមរយៈសកម្មភាពរបស់ខ្លួន CAMBOW ប្រឹងប្រែងលើកកំពស់ការយល់ដឹងនឹងធ្វើការផ្លាស់ប្តូរផ្នត់គំនិតសង្គម ដែលពាក់ព័ន្ធទៅនឹងទង្វើប្រើអំពើហិង្សាលើស្ត្រីដោយផ្តោតលើអំពើរំលោភសេពសន្ថវៈ អំពើហិង្សាក្នុងគ្រួសារ និងការជួញដូរស្ត្រី ដើម្បីគោលបំណងអាជីវកម្មផ្លូវភេទ។

CAMBOW ធ្វើការដើម្បីលើកដំកើងការគោរព និងការការពារសិទ្ធិស្ត្រីតាមរយៈការអប់រំបណ្តុះបណ្តាល ស្រាវជ្រាវ ចងក្រងឯកសារ នឹងទាក់ទាញមតិគាំទ្រ។

**ចំពោះព័ត៌មានបន្ថែម សូមទំនាក់ទំនង**


លោកស្រី វេជ្ជបណ្ឌិត. ពុង ឈីវកេក ប្រធានអង្គការលីកាដូ និងគណៈកម្មការស្ត្រីកម្ពុជា CAMBOW។

អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)

ផ្ទះលេខ១៦ ផ្លូវលេខ ៩៩

ភ្នំពេញ កម្ពុជា

ទូរស័ព្ទ: (៨៥៥)២៣ ៣៦0 ៩៦៥/៣៦៤ ៩0១

ទូរសារ: (៨៥៥)២៣ ៣៦0 ៩៦៥/២១៧ ៦២៦

អ៊ីមែល: contact@licadho.org

គេហទំព័រ: http://www.licadho.org

# មាតិកា


**របាយការណ៍សង្ខេប** ~~~~~~~~~~~~~~~~~~~~ **១**

**១. បុព្វកថា** ~~~~~~~~~~~~~~~~~~~~ **៤**

គោលបំណងនៃរបាយការណ៍ -------------------- ៤

អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ (CEDAW) ------------ ៤

វិធីសាស្ត្រ : តើរបាយការណ៍នេះចងក្រងដោយរបៀបណា -------------------- ៥

**២. អំពើហិង្សាក្នុងគ្រួសារ** ~~~~~~~~~~~~~~~~~~~~ **៨**

***ករណីសិក្សាទី១: អំពើហិង្សាក្នុងគ្រួសារ -រឿងរបស់សុផាន់ណា*** -------------------- ៩

អំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា -------------------- ១០

ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ -------------------- ១១

និយមន័យមិនពេញលេញនៃអំពើហិង្សាក្នុងគ្រួសារនៅក្នុងច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ -------------------- ១១

មាត្រាចែងពីទោសទណ្ឌនៃអំពើហិង្សាក្នុងគ្រួសារ -------------------- ១២

កិច្ចការពារខ្លួន -------------------- ១៣

អំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ -------------------- ១៤

ការដាក់ពិន័យតាមទម្លាប់វប្បធម៌ខ្មែរ -------------------- ១៤

និយមន័យនៃពាក្យអាជ្ញាធរមានសមត្ថកិច្ច -------------------- ១៥

ការជម្លៀសជនរងគ្រោះ និងបទបញ្ជាការពារ -------------------- ១៥

ការផ្សះផ្សា និងការសម្រុះសម្រួល -------------------- ១៦

វិធានការស្តារនីតិសម្បទា -------------------- ១៧

សេចក្តីសន្និដ្ឋាន -------------------- ១៧

**៣. អាពាហ៍ពិពាហ៍** ~~~~~~~~~~~~~~~~~~~~ **១៨**

***ករណីសិក្សាទី២: រឿងរបស់ណារ៉ែន*** -------------------- ១៩

អាពាហ៍ពិពាហ៍នៅកម្ពុជា -------------------- ២១

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ -------------------- ២២

អាយុរៀបអាពាហ៍ពិពាហ៍ជាអប្បបរមា -------------------- ២២

នីតិវិធីនៃការលះលែង------------------------------------------------------------២៣
ការរៀបអាពាហ៍ពិពាហ៍ជាថ្មី -----------------------------------------------------២៥
សេចក្តីសន្និដ្ឋាន ----------------------------------------------------------------២៥
**៤. អំពើរំលោភសេពសន្ថវៈ ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ២៦**
**ករណីសិក្សាទី៣: អំពើរំលោភសេពសន្ថវៈជាពួក -រឿងរបស់រតនា** ---------------------------២៦
**ករណីសិក្សាទី៤: អំពើរំលោភសេពសន្ថវៈ -រឿងរបស់ស៊ីថា**-------------------------------------២៨
អំពើរំលោភសេពសន្ថវៈនៅកម្ពុជា-----------------------------------------------------២៩
និយមន័យនៃពាក្យរំលោភសេពសន្ថវៈ ---------------------------------------------៣១
កង្វះនិយមន័យនៃពាក្យព្រមព្រៀង-----------------------------------------------------៣១
អំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ -------------------------------------៣២
វិធានការស្តារនីតិសម្បទា ---------------------------------------------------------៣២
**៥. អំពើជួញដូរមនុស្ស ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៣៤**
**ករណីសិក្សាទី៥: រឿងរបស់សុភា** ---------------------------------------------------------៣៤
អំពើជួញដូរមនុស្សនៅកម្ពុជា ---------------------------------------------------------៣៦
ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្ស និងអំពើអាជីវកម្មមនុស្ស ------------------៣៧
កង្វះនិយមន័យក្នុងច្បាប់ជួញដូរមនុស្ស-------------------------------------------------៣៨
ច្បាប់អន្តោប្រវេសន៍ ------------------------------------------------------------------៣៩
ច្បាប់ការងារ-------------------------------------------------------------------------- ៤០
វិធានការស្តារនីតិសម្បទា ---------------------------------------------------------- ៤០
សេចក្តីសន្និដ្ឋាន ----------------------------------------------------------------៤១
**៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៤២**
**ឧបសម្ព័ន្ធទី ១: ឯកសារសិក្សាប្រៀបធៀប~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៤៥**
**ឧបសម្ព័ន្ធទី ២: សមាជិករបស់ CAMBOW ~~~~~~~~~~~~~~~~~~~~~~~~~~~~ ៥១**

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះអង្គការសេវាសង្គ្រោះកាតូលិកប្រចាំកម្ពុជា ដែលបានជួយគាំទ្រដោយសប្បុរសនូវថវិកាក្នុងការបោះពុម្ពរបាយការណ៍នេះ។

សូមថ្លែងអំណរគុណចំពោះសមាជិកទាំងឡាយនៃគណៈកម្មាធិការស្ត្រីកម្ពុជា ដែលបានជួយ នឹងគាំទ្រគម្រោងនេះ និងសូមថ្លែងអំណរគុណចំពោះបុគ្គលិកអង្គការលីកាដូទាំងអស់ ដែលបានរៀបចំបទសម្ភាសន៍ជាមួយអង្គការសមាជិកគណៈកម្មាធិការស្ត្រីកម្ពុជា និងអតិថិជន។

សូមថ្លែងអំណរគុណជាពិសេសចំពោះស្ត្រីមួយចំនួន ដែលបានចែករំលែកនូវរឿងរ៉ាវរបស់ពួកគេយ៉ាងក្លាហានជាមួយយើង ដើម្បីយកមកចងក្រងរបាយការណ៍នេះ។ យើងសង្ឃឹមថា រឿងរ៉ាវរបស់ពួកគេ នឹងលើកទឹកចិត្តដល់ជនរងគ្រោះដទៃទៀត ដែលរងគ្រោះដោយអំពើហិង្សាឱ្យហ៊ានចេញមុខបង្ហាញខ្លួន ដើម្បីទាមទារសិទ្ធិសេរីភាពរបស់ពួកគេជាមិនខាន។

□□□

# របាយការណ៍សង្ខេប

នៅឆ្នាំ១៩៩២ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ CEDAW ។ ច្បាប់សិទ្ធិស្ត្រីអន្តរជាតិនេះ រួមមានមាត្រាមួយចំនួនដែលសំដៅកាត់បន្ថយ នឹងលុបបំបាត់អំពើហិង្សាចំពោះស្ត្រី ។ ដោយការផ្តល់សច្ចាប័ននេះ កម្ពុជាបានប្តេជ្ញាចិត្តរបស់ខ្លួនចំពោះកិច្ចការពារស្ត្រីកម្ពុជាឱ្យរួចផុតពីអំពើហិង្សានឹងលុបបំបាត់រាល់ការរើសអើងប្រឆាំងនឹងនារីភេទ ។

ច្បាប់នានាដែលពាក់ព័ន្ធជាមួយនឹងទម្រង់នៃអំពើកេងប្រវ័ញ្ច និងការរើសអើងចំពោះស្ត្រីកម្ពុជា ដូចជា អំពើហិង្សាក្នុងគ្រួសារ អំពើរំលោភសេពសន្ថវៈ និងអំពើជួញដូរមនុស្សក្នុងគោលបំណងអាជីវកម្មផ្លូវភេទ ដែលមានចំណុចខ្វះខាតជាច្រើននូវវិធានការការពារ និងកិច្ចធានាឱ្យមានសមភាពសម្រាប់ស្ត្រីនៅកម្ពុជា។ ជាលទ្ធផល ច្បាប់ទាំងនេះមានលក្ខណៈផ្ទុយទៅនឹងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ ដោយការរើសអើងចំពោះស្ត្រីកម្ពុជាជាទូទៅ ។

រហូតមកដល់ឆ្នាំ២០០៧ រាជរដ្ឋាភិបាលកម្ពុជានៅពុំទាន់បានអនុម័តច្បាប់ណាថ្មី ដើម្បីការពារស្ត្រីរងគ្រោះដោយអំពើហិង្សាឱ្យបានគ្រប់គ្រាន់នៅឡើយទេ។ ច្បាប់ទាំងឡាយក្នុងពេលបច្ចុប្បន្ននេះ ក៏នៅពុំទាន់ត្រូវបានអនុវត្តឱ្យបានទូលំទូលាយនៅទូទាំងប្រទេសដែរ ហើយប្រជាពលរដ្ឋជាច្រើន រួមទាំងមន្ត្រីផ្នែកច្បាប់ តុលាការ អាជ្ញាធរមូលដ្ឋាន សាធារណៈជនទូទៅ បុរស ហើយនិងសំខាន់បំផុតនោះ គឺស្ត្រីទូទៅនៅមិនទាន់បានយល់អំពីច្បាប់ទាំងនេះ រួមទាំងការប្រឹងប្រែងក្នុងកិច្ចការពារសិទ្ធិស្ត្រីនៅកម្ពុជានៅឡើយ។

## អំពើហិង្សាក្នុងគ្រួសារ

*ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ* បានចែងនូវវិធានការមួយចំនួនដើម្បីការពារជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ នឹងឆ្លុះបញ្ចាំងឱ្យឃើញពីចេតនារបស់រដ្ឋាភិបាលក្នុងការប្រកាសឱ្យប្រើច្បាប់ដែលឆ្ពោះទៅរកការដោះស្រាយបញ្ហានេះ។ ប៉ុន្តែច្បាប់នេះតម្រូវឱ្យមានការផ្លាស់ប្តូរនូវចំណុចជាច្រើន ដើម្បីឱ្យមានលក្ខណៈគ្រប់គ្រាន់ក្នុងការលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ។ នៅពេលបច្ចុប្បន្ន ទម្រង់ច្បាប់នេះនៅមានមាត្រាសំខាន់ៗមួយចំនួន ដែលចែងអត្ថន័យមិនច្បាស់លាស់ ដូចជានិយមន័យនៃពាក្យអំពើហិង្សាក្នុងគ្រួសារ អំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ និងការទទួលខុសត្រូវរបស់អាជ្ញាធរក្នុងកិច្ចការពារជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារជាដើម ។

## អាពាហ៍ពិពាហ៍

*ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ* គឺជាច្បាប់មួយដែលមានលក្ខណៈទូលំទូលាយ ហើយមានគោលបំណង ដើម្បីធានានូវសមភាពរបស់ដៃគូនៅក្នុងចំណងអាពាហ៍ពិពាហ៍។ ទោះបីជាយ៉ាងណាក៏ដោយ ចំពោះមាត្រាចែងនូវនីតិវិធីសម្រាប់ការលះលែងគ្នានៅក្នុងច្បាប់នេះមានលក្ខណៈស្មុគស្មាញ ចំណាយពេលច្រើន ដែលបានកំណត់ពីដំណើរវិធីលះលែងដ៏លំបាកៗសម្រាប់ភាគីទាំងពីរអនុវត្តតាម ហើយជាពិសេស គឺភាគីស្រ្តីតែម្តងដែលច្បាប់នេះជាទូទៅបានកំណត់នូវនីតិវិធីផ្ទុះផ្ទារាមួយដែលមានភាពលំអៀង។

## អំពើរំលោភសេពសន្ថវៈ

ច្បាប់ស្តីពីអំពើរំលោភសេពសន្ថវៈ ដែលមានបច្ចុប្បន្ននេះ ពុំបានកំណត់និយមន័យបទល្មើសនៃការរំលោភសេពសន្ថវៈឱ្យបានច្បាស់លាស់គ្រប់គ្រាន់ទេ។ សារៈសំខាន់បំផុតនោះគេមិនបានចែងពីបញ្ហានៃការព្រមព្រៀងគ្នា។ នៅក្នុងច្បាប់ស្តីពីអំពើរំលោភសេពសន្ថវៈមានន័យថា ការបញ្ចូលអវៈយវៈភេទប្រព្រឹត្តដោយ "ឃោឃៅដោយបង្ខំ ឬដោយមិនឱ្យដឹងខ្លួនជាមុន " ដែលជាហេតុនាំឱ្យតុលាការពិចារណាថា អំពើរំលោភសេពសន្ថវៈ ត្រូវតែទាក់ទិននឹងអំពើឃោឃៅ និងមានរបួសធ្ងន់ធ្ងរ។ ដោយមិនអើពើលើករណីរំលោភសេពសន្ថវៈជាច្រើនដែលត្រូវបានប្រព្រឹត្តឡើងដោយពុំមានរបួសធ្ងន់ធ្ងរទេ។ នៅកម្ពុជា ជារឿយៗអ្នករំលោភជាជនកាន់ឧបករណ៍ជាអាវុធ ហើយធ្វើការគំរាមកំហែងដោយប្រើហិង្សា ឬកាប់សំលាប់ ដែលជាហេតុធ្វើឱ្យជនរងគ្រោះពុំអាចតស៊ូប្រឆាំងជាមួយអ្នករំលោភបានឡើយ ព្រោះតែការភ័យខ្លាចចំពោះសុវត្ថិភាពអាយុជីវិតរបស់ពួកគេ។ ភាពកង្វះខាតទាំងឡាយនៅក្នុងមាត្រាច្បាប់ប្រឆាំងនឹងអំពើរំលោភសេពសន្ថវៈ និងក្នុងមធ្យោបាយមួយចំនួនបានពង្រឹងឥរិយាបថសង្គមឱ្យទោរទន់ទៅរកការស្តីបន្ទោស ឬធ្វើឱ្យមានភាពអាម៉ាស់ចំពោះស្រ្តីដែលត្រូវបានគេរំលោភទៅវិញ។

## អំពើជួញដូរមនុស្ស

ប្រទេសកម្ពុជា គឺជាប្រភពដែលអំពើជួញដូរឆ្លងកាត់ និងជាប្រទេសគោលដៅនៃអំពើជួញដូរមនុស្សមួយបច្ចុប្បន្ននេះពុំទាន់មានស្ថិតិស្តីពីចំនួនស្រ្តីដែលកំពុងត្រូវបានគេជួញដូរនៅក្នុង និងក្រៅកម្ពុជាឱ្យបានច្បាស់លាស់នៅឡើយទេ ហើយក៏បានបង្ហាញយ៉ាងច្បាស់ពីអំពើជួញដូរនេះ គឺជាបញ្ហាមួយដែលប៉ះពាល់ដល់ស្រ្តីជាច្រើន។ ច្បាប់ស្តីពីអំពើជួញដូរមនុស្សដែលមានសព្វថ្ងៃនេះ ក៏ពុំបានកំណត់និយមន័យនៃទំរង់បទល្មើសជួញដូរនេះឱ្យបានច្បាស់លាស់គ្រប់គ្រាន់ដែរទេ ដោយពុំបានដាក់បញ្ចូលនូវបទល្មើសដែលប្រព្រឹត្តពីសំណាក់មនុស្សច្រើននាក់ដែលអាចចាត់

ទុកជាអំពើជួញដូរផងដែរនោះ។ លើសពីនេះទៀតច្បាប់ស្តីពីអំពើជួញដូរ ក៏ពុំបានផ្តល់កិច្ចការពារឬការស្តារនីតិសម្បទាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងស្រុក និងអន្តរជាតិទេ។

## សេចក្តីសន្និដ្ឋាន

ច្បាប់របស់កម្ពុជា ដែលពាក់ព័ន្ធទៅនឹងអំពើហិង្សាប្រឆាំងចំពោះស្ត្រីពុំបានការពារស្ត្រីកម្ពុជាឱ្យរួចចាកផុតពីអំពើហិង្សាពីរាល់ទម្រង់នៃអំពើអាជីវកម្ម និងពីរាល់ទម្រង់នៃអំពើរើសអើងឡើយ។ ច្បាប់ទាំងឡាយដែលពាក់ព័ន្ធជាមួយនឹងអំពើហិង្សាចំពោះស្ត្រីត្រូវតែធ្វើវិសោធនកម្ម ធ្វើសេចក្តីព្រាង នឹងអនុវត្តឱ្យស្របតាមគោលការណ៍របស់ *អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ (CEDAW)* ។

□□□

# ១. បុព្វកថា

## គោលបំណងនៃរបាយការណ៍

ភាពរើសអើងក្នុងការតាក់តែងច្បាប់ អាចកើតឡើងនៅក្នុងទំរង់មួយចំនួនដូចជា តាមរយៈពាក្យពេចន៍ច្បាប់ជាក់លាក់លើយេនឌ័រ ដែលមានផលប៉ះពាល់ជាអវិជ្ជមានដ៏ច្រើនលើសលប់លើស្ត្រីច្រើនជាងបុរស ឬតាមរយៈកតព្វកិច្ចមិនគប្បីចំពោះស្ត្រី ឬការខកខានមិនបានបញ្ចូលនិមយន័យច្បាប់ និងដំណើរការជំនុំជំរះដ៏ស្មុគ្រស្មាញ ឬអាចជាលទ្ធផលបណ្តាលឱ្យមានកង្វះខាតនូវវិធានការការពារ ។

របាយការណ៍នេះ គឺជារបាយការណ៍វិភាគ ថាតើច្បាប់កម្ពុជាដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រីមានភាពផ្ទុយគ្នាទៅនឹងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW)[១] ដែរឬទេ ហើយប្រសិនបើមានពិតមែន គេគួរត្រូវពិនិត្យមើលពីតទ្ធិពលនៃភាពផ្ទុយគ្នានោះមានក៏រិតប៉ះពាល់យ៉ាងដូចម្តេចចំពោះស្ត្រីនៅកម្ពុជា ។

## អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ (CEDAW)

អនុសញ្ញា CEDAW គឺជាឯកសារច្បាប់អន្តរជាតិមួយស្តីពីសិទ្ធិស្ត្រីដែលត្រូវបានអនុម័តនៅ ឆ្នាំ១៩៧៩ ដោយមហាសន្និបាតអង្គការសហប្រជាជាតិ ។ វាជាច្បាប់ទូលំទូលាយមួយដែលបានថែងយ៉ាងច្បាស់ពីអត្ថន័យនៃសមភាពសម្រាប់ស្ត្រី នឹងគូសបញ្ជាក់នូវរបៀបវារៈសម្រាប់រដ្ឋភាគីនានាត្រូវអនុវត្តតាមក្នុងគោលបំណងឈានទៅរកសំរេចគោលដៅរួមមួយ ។ នៅឆ្នាំ១៩៩២ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញា CEDAW ដោយបានសន្យាធានារកវិធានការជាបន្តបន្ទាប់ ដើម្បីលុបបំបាត់រាល់ទំរង់នៃការរើងអើសប្រឆាំងនារីភេទ។ អនុសញ្ញា CEDAW នេះបានតម្រូវឱ្យរដ្ឋភាគីទាំងឡាយត្រូវតែប្រកាន់យក "វិធានការណ៍ដ៏សមរម្យនានា រួមទាំងបញ្ញតិច្បាប់ផងដែរ ដើម្បីធ្វើឱ្យមានការចំរើនលូតលាស់ និងជឿនលឿនយ៉ាងពេញលេញរបស់នារីភេទក្នុងគោលដៅធានាឱ្យនារីអាចប្រើប្រាស់នឹងទទួលបាននូវសិទ្ធិព្រមទាំងសេរីភាពជាគ្រឹះទាំងឡាយលើមូលដ្ឋានស្មើភាពនឹងបុរស"[២] ។ អនុសញ្ញា CEDAW បានកំណត់និយមន័យនៃការរើសអើងប្រឆាំងនារីភេទថា "ការបែងចែក ការផាត់ចេញ ឬការដាក់កំហិតណាដែលធ្វើឡើងលើមូលដ្ឋានភេទ ហើយដែលបង្កឡើង ឬដែលមានទិសដៅធ្វើឱ្យខូចខាត ឬធ្វើឱ្យទៅ

---

[១] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទនៅទីនេះហៅកាត់ថា (CEDAW) ។

[២] មាត្រា ៣ នៃអនុសញ្ញា CEDAW ។

ជាមោឃដល់ការទទួលស្គាល់ ការទទួលបាន ឬការប្រើប្រាស់ដោយនារីភេទនូវសិទ្ធិមនុស្ស និងរាល់សេរីភាពជាគ្រឹះនៅក្នុងវិស័យនយោបាយ សេដ្ឋកិច្ច វប្បធម៌ ពលរដ្ឋ ឬក៏ក្នុងវិស័យផ្សេងៗទៀតលើមូលដ្ឋានស្មើភាពរវាងបុរស និងនារីក្នុងស្ថានភាពអាពាហ៍ពិពាហ៍បែបណាក៏ដោយ"[៣] ។

ក្នុងសេចក្ដីបន្ថែមលើអនុសញ្ញា CEDAW គណៈកម្មាធិការអង្គការសហប្រជាជាតិនៃអនុសញ្ញាស្ដីពីការលុបបំបាត់ភាពរើសអើងប្រឆាំងនារីភេទ បានផ្ដល់យោបល់ និងអនុសាសន៍ជាទៀតទាត់នូវមាត្រាជាក់លាក់ទាំងឡាយនៃអនុសញ្ញា CEDAW ។ អនុសាសន៍ទូទៅផ្ដល់ចំពោះរដ្ឋភាគីនីមួយៗ នូវសេចក្ដីណែនាំច្បាស់លាស់ថាតើត្រូវអនុវត្ត CEDAWក្នុងស្ថានភាពបែបណា។ អនុសាសន៍មួយ ជាពិសេសអនុសាសន៍ទូទៅ ១៩ ចំណុច[៤] ដែលបានផ្ដល់យោបល់ទៅលើមាត្រាទាំងឡាយក្នុងអនុសាសន៍ CEDAW ដែលពាក់ព័ន្ធនឹងអំពើហិង្សាប្រឆាំងនារីភេទ។ សំរាប់គោលបំណងនៃរបាយការណ៍នេះ អនុសាសន៍ទូទៅ ១៩ចំណុច គឺផ្ដោតចំពោះមាត្រាទាំងឡាយណាក្នុងអនុសញ្ញា CEDAWដែលជាចំណុចបង្ហាញស្ដីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនារីភេទ។

## វិធីសាស្ត្រ : តើរបាយការណ៍នេះចងក្រងដោយរបៀបណា

របាយការណ៍នេះត្រូវបានសិក្សាស្រាវជ្រាវតាមរយៈវិធីសាស្ត្រផ្សេងៗ ដើម្បីបង្កើតការត្រួតពិនិត្យឱ្យបានពេញលេញថែមទៀត ថាតើច្បាប់កម្ពុជាទាំងឡាយមានការរើសអើងទាក់ទងទៅនឹងបញ្ហាហិង្សាចំពោះស្ត្រី ហើយធ្វើឱ្យប៉ះពាល់ទៅលើជីវភាពជាក់ស្ដែងរបស់ស្ត្រីកម្ពុជាដូចម្ដេចខ្លះ។ វិធីសាស្ត្រដែលប្រើសំរាប់ការសិក្សាស្រាវជ្រាវរួមមាន:

## ការពិនិត្យឡើងវិញមាត្រាច្បាប់នានា

ការពិនិត្យឡើងវិញនេះត្រូវបានដកស្រង់ចេញពីឯកសារនានាដែលមានស្រាប់ ហើយបានពិភាក្សាអំពីច្បាប់កម្ពុជាដែលពាក់ព័ន្ធ។ ការពិនិត្យនេះ មានគោលបំណងចងក្រងការវិភាគច្បាប់ដែលមានស្រាប់ និងភាពរើសអើងក្នុងមាត្រាច្បាប់ទាំងនេះ ទោះបីជាអ្នកនិពន្ធបានរកឃើញថាការងារលើការវិភាគកន្លងមកនៅមានព្រំដែនកំណត់ក៏ដោយ។

---

[៣] មាត្រា ១ នៃអនុសញ្ញា CEDAW ។

[៤] អនុសាសន៍ទូទៅ ១៩ ចំណុច (សម័យប្រជុំទី១១ ឆ្នាំ១៩៩២) http://www.un.org/womenwatch/daw/cedaw/recommendatios/index.html

# ការវិភាគអំពីច្បាប់កម្ពុជាបច្ចុប្បន្ន ទាក់ទិននឹងអំពើហិង្សាប្រឆាំងនារីភេទ

ខាងក្រោមនេះ គឺជាច្បាប់ដែលបានលើកយកមកធ្វើវិភាគៈ

- *ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥*
- *ច្បាប់ស្តីពីស្ថានទម្ងន់ទោសបទល្មើសឧក្រិដ្ឋ ឆ្នាំ២០០១*
- *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ និងវិសោធនកម្ម ឆ្នាំ១៩៩៩*
- *បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅកម្ពុជាក្នុងសម័យអន្តរកាល (អ៊ុនតាក់) ឆ្នាំ១៩៩២ (ពាក់ព័ន្ធនឹងបទល្មើសរំលោភសេពសន្ថវៈ និងករណីជួញដូរមនុស្ស)*
- *ច្បាប់ស្តីពីការបង្រ្កាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើអាជីវកម្មលើមនុស្ស ឆ្នាំ១៩៩៦*
- *ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩*
- *ច្បាប់អន្តោប្រវេសន៍ ឆ្នាំ១៩៩៤ (មាត្រាពាក់ព័ន្ធជាមួយអំពើជួញដូរមនុស្ស)*
- *ច្បាប់ការងារ ឆ្នាំ១៩៩៧*

ច្បាប់ទាំងនេះត្រូវបានជ្រើសរើសសម្រាប់ធ្វើការវិភាគ ដោយច្បាប់និមួយៗសុទ្ធតែមានចែងអំពីសិទ្ធិស្រ្តីនៅក្នុងផ្នែកជួញដូរមនុស្ស អំពើហិង្សាក្នុងគ្រួសារ អំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍។ ការវិភាគត្រូវបានធ្វើឡើងដើម្បីរិះរកឱ្យឃើញថា តើច្បាប់ណាខ្លះបានចែងផ្ទុយគ្នាទៅនឹងអនុសញ្ញា CEDAW ដោយការរើសអើងចំពោះស្រ្តីកម្ពុជាក្នុងបញ្ហាហិង្សានានារបស់ស្រ្តី ។

## ការសម្ភាសន៍ជាមួយសមាជិក CAMBOW

ទម្រង់សំណួរសម្ភាសន៍ត្រូវបានរៀបចំឡើង ហើយបានប្រើប្រាស់នៅក្នុងកិច្ចសម្ភាសន៍ជាមួយនឹងសមាជិក CAMBOWមួយចំនួន ដើម្បីប៉ាន់ប្រមាណពីការយល់ដឹងនូវបញ្ហាមួយចំនួនដែលសមាជិកបានជួបប្រទះ និងដើម្បីស្វែងយល់អំពីបទពិសោធន៍របស់ពួកគេ ដែលទាក់ទងជាមួយនឹងផលប៉ះពាល់ពីភាពផ្ទុយគ្នាទាំងឡាយនៅក្នុងច្បាប់កម្ពុជាទៅនឹងអនុសញ្ញា CEDAW និងដើម្បីស្វែងរកអតិថិជនសម្រាប់ធ្វើជាករណីសិក្សានៅក្នុងរបាយការណ៍នេះផងដែរ ។

## ការសម្ភាសន៍ជាមួយអតិថិជន

យើងបានរៀបចំសំណួរ ហើយបានប្រើប្រាស់ដើម្បីសម្ភាសន៍អតិថិជនចំនួន ៦៣ នាក់ ដែលជាអតិថិជនរបស់អង្គការសមាជិក CAMBOW ដែលបានរងគ្រោះដោយអំពើហិង្សា ការកេងប្រវ័ញ្ច និងការរើសអើងដោយ

ច្បាប់កម្ពុជា ។ រឿងទាំងនេះមួយចំនួនបានមកពីការសម្ភាសន៍ដោយយកមកធ្វើជាករណីសិក្សានៅក្នុងរបាយការណ៍នេះនឹងបង្កើតបានជាមូលដ្ឋានគ្រឹះសំរាប់យុទ្ធនាការតស៊ូមតិ ។ ករណីសិក្សាទាំងនេះ គឺមានគោលបំណងគ្រាន់តែបង្ហាញប៉ុណ្ណោះ វាពុំបានបង្កើតនូវមូលដ្ឋានពីរបកគំឃើញនៅក្នុងរបាយការណ៍នេះទេ។

## កំណត់សម្គាល់ក្នុងករណីសិក្សា

*នៅក្នុងករណីសិក្សាទាំងនេះយើងបានប្តូរឈ្មោះ និងលក្ខណៈសម្គាល់មួយចំនួន ដើម្បីរក្សាការសម្ងាត់ជូនអតិថិជនរបស់យើង។ រឿងទាំងនេះ គឺផ្អែកលើបទពិសោធន៍ជាក់ស្តែង ដែលអតិថិជនរបស់យើងបានជួបប្រទះ ប៉ុន្តែ ក៏បានបន្ថែមសេចក្តីខ្លះទៅក្នុងសាច់រឿងដែរ ដើម្បីឱ្យមានអត្ថន័យពេញលេញ ។*

□□□

## ២. អំពើហិង្សាក្នុងគ្រួសារ

*"រដ្ឋភាគីទាំងឡាយនឹងចាត់វិធានការណ៍ដែលសមស្រប ដើម្បីកែប្រែទម្រង់តរិយាបទបុរស និងនារីខាងវិស័យសង្គម និងវប្បធម៌ ក្នុងទស្សនៈបំបាត់ចោលនូវការប្រកែប្រកាន់ និងការអនុវត្តន៏តាមទំលាប់ ព្រមទាំងការអនុវត្តន៏ផ្សេងទៀត ដែលឈរលើមូលដ្ឋាននៃការគិតអំពីភាពអន់ថយ ឬឧត្តមភាពរបស់ភេទណាមួយ ឬគិតអំពីតួនាទីជាទំលាប់របស់បុរស និងនារី[៥] ។"*

*"រដ្ឋភាគីត្រូវប្រកាន់យកគ្រប់វិធានការណ៍សមស្របទាំងអស់ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទនៅក្នុងគ្រប់វិស័យដែលទាក់ទងទៅនឹងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងគ្រួសារ និងជាពិសេសដោយឈរលើមូលដ្ឋានសមភាពរវាងបុរសនិងនារី រដ្ឋត្រូវធានាជូននារីនូវៈ សិទ្ធិដូចគ្នាសំរាប់គូរស្រករទាំងពីរនៅក្នុងការកាន់កាប់កម្មសិទ្ធិ ការទទួលបាន ការចាត់តាំង ការគ្រប់គ្រង ការអាស្រ័យផល និងការប្រើប្រាស់កម្មសិទ្ធិទោះជាដោយមិនគិតថ្លៃក្តី ឬគិតថ្លៃក្តី[៦] ។"*

*"រដ្ឋភាគីនានាត្រូវធានាឱ្យមានច្បាប់ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ និងការធ្វើទុក្ខទោស ការរំលោភសេពសន្ថវៈ ការរំលោភបំពាន និងអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រផ្សេងទៀត ដោយបញ្ញត្តិកិច្ចការពារស្ត្រីទូទៅឱ្យបានគ្រប់គ្រាន់ និងគោរពបូរណភាព និងសេចក្តីថ្លៃថ្នូររបស់ស្ត្រី ។"[៧]*

*"អំពើហិង្សាក្នុងគ្រួសារគឺជាទម្រង់មួយនៃអំពើហិង្សាប្រឆាំងនឹងនារីភេទ ហើយវារាលដាលពាសពេញក្នុងសង្គម ។ នារីគ្រប់វ័យទាំងអស់ក្នុងគ្រួសារជាគោលដៅនៃអំពើហិង្សាគ្រប់ប្រភេទរួមមានការបង្ករបួសស្នាម ការរំលោភសេពសន្ថវៈ ការបៀតបៀនកេរ្តិ៍ខ្មាស បញ្ហាស្មារតី និងរាល់អំពើហិង្សាផ្សេងៗទៀត ដែលជាទំលាប់ប្រពៃណី មានជាបន្តបន្ទាប់រៀងមក ។ កង្វះឯករាជ្យភាពសេដ្ឋកិច្ចបានជំរុញឱ្យនារីស្ថិតក្នុងអំពើហិង្សា ។ ការបំបាត់ចោលនៃការទទួលខុសត្រូវក្នុងគ្រួសាររបស់ពួកគេ ដោយបុរសអាចជាទម្រង់នៃអំពើហិង្សា និងការបង្ខិតបង្ខំ ។ ទម្រង់នៃអំពើហិង្សាទាំងនេះធ្វើឱ្យសុខភាពនារីធ្លាក់ចុះក្នុងគ្រោះថ្នាក់ និងពុំមានលទ្ធភាពចូលរួមក្នុងការទទួលខុសត្រូវក្នុងគ្រួសារ និងសាធារណៈដោយផ្អែកលើមូលដ្ឋានស្មើភាពគ្នា ។"[៨]*

---

[៥] អនុសញ្ញា CEDAW មាត្រា ៥ ។

[៦] អនុសញ្ញា CEDAW មាត្រា ១៦ ( កថាខណ្ឌ ១) ( ជ)

[៧] អនុសាសន៏ទូទៅ ១៩ ផ្តល់យោបល់ទៅលើមាត្រាពិសេសទាំងឡាយក្នុងអនុសញ្ញា CEDAW ( កថាខណ្ឌ ២៤) ( ខ) ។

[៨] អនុសាសន៏ទូទៅ ១៩ ផ្តល់យោបល់ទៅលើមាត្រាពិសេសទាំងឡាយក្នុងអនុសញ្ញា CEDAW ( កថាខណ្ឌ ២៣) ។

## ករណីសិក្សាទី១:    អំពើហិង្សាក្នុងគ្រួសារ -រឿងរបស់សុផាន់ណា

*នាងខ្ញុំឈ្មោះ សុផាន់ណា អាយុ ៣៥ ឆ្នាំ។ ខ្ញុំបានរៀបការជាមួយប្ដីខ្ញុំឈ្មោះ បឿន អស់រយៈពេល ៧ ឆ្នាំ។ ក្រោយពីរៀបការយើងរស់នៅជាមួយឪពុកម្ដាយ និងប្អូនប្រុស២របស់ខ្ញុំ។ ពីរឆ្នាំដំបូងនៃជីវិតអាពាហ៍ពិពាហ៍ យើងទាំងពីរនាក់មានសេចក្ដីសុខសប្បាយជាធម្មតា។ ប៉ុន្ដែ ប្រហែលពីរឆ្នាំក្រោយមក ប្ដីរបស់ខ្ញុំបានចាប់ផ្ដើមប្រើអំពើហិង្សាមកលើខ្ញុំ។ គាត់វាយដំ និងជេរបញ្ចោរខ្ញុំឥតឈប់ឈរ។ ជារៀងរាល់ថ្ងៃ គាត់តែងតែទុកកាំបិតមួយនៅជិតខ្លួនជានិច្ច ហើយតែងតែគំរាមខ្ញុំថា ថ្ងៃណាមួយគាត់នឹងសម្លាប់ខ្ញុំចោល។ ខ្ញុំជឿថាគាត់ពិតជាហ៊ានសម្លាប់ខ្ញុំ។ ថ្ងៃមួយគាត់បានវាយដំខ្ញុំយ៉ាងធ្ងន់ធ្ងររហូតដល់ខ្ញុំមិនអាចក្រោកឈរបាន។*

*ដោយសារអំពើហិង្សាបែបនេះ ខ្ញុំបានចុះចោលគាត់ពីរលើក ប៉ុន្ដែគាត់តែងតែតាមរកខ្ញុំឃើញមកវិញជានិច្ច។ ខ្ញុំខ្លាចគាត់ខ្លាំងណាស់នៅពេលដែលខ្ញុំមិនព្រមធ្វើតាមគាត់។*

*ថ្ងៃមួយ គាត់បានចូលមកក្នុងផ្ទះដោយមានអារម្មណ៍ខឹងនឹងអ្វីមួយយ៉ាងខ្លាំង ហើយគាត់បានបោកបំបែកសម្ភារៈក្នុងផ្ទះអស់ជាច្រើន ក្រោយពីបោករួចគាត់ដើរចូលមកជិតខ្ញុំ ហើយច្របាច់កខ្ញុំយ៉ាងខ្លាំងរហូតដល់ខ្ញុំមិនអាចដកដង្ហើមបាន។ ខ្ញុំគិតថា ខ្ញុំប្រាកដជាស្លាប់ហើយពេលនោះ។ ម្ដាយខ្ញុំ បានរត់ចូលមកក្នុងផ្ទះខ្ញុំ គាត់បានប្រាប់ប្ដីខ្ញុំថា ឱ្យឈប់ច្របាច់កខ្ញុំ ប៉ុន្ដែ គាត់រឹតតែច្របាច់ខ្លាំងឡើង។ គាត់ស្រែកដាក់ម្ដាយខ្ញុំថា "កុំចេះលូកដៃ នេះគឺជារឿងផ្ទៃក្នុងគ្រួសារខ្ញុំតែប៉ុណ្ណោះ "។ ហើយគាត់ក៏លែងខ្ញុំ ហើយស្ទុះទៅរកវាយម្ដាយខ្ញុំវិញម្ដង។*

*ក្រោយមកបន្ដិច បងប្រុសខ្ញុំបានមកដល់ដោយគាត់ឮសម្លេងស្រែក។ គាត់ចាប់ប្ដីខ្ញុំជាប់ ហើយឃាត់គាត់ កុំឱ្យវាយម្ដាយខ្ញុំតទៅទៀត។ ស្រាប់តែប្ដីខ្ញុំចាប់ទាញកាំបិតមួយបម្រុងចាក់បងខ្ញុំ ប៉ុន្ដែ គាត់ចាក់មិនត្រូវ។ បងខ្ញុំក៏រត់ទៅក្រៅហើយជិះម៉ូតូទៅបាត់។ គាត់បានទៅរាយការណ៍ប្រាប់មេភូមិ ហើយសុំឱ្យមេភូមិជួយគ្រួសារខ្ញុំ។ ពេលនោះមេភូមិបានបដិសេធមិនព្រមជួយទេ ហើយប្រាប់បងប្រុសខ្ញុំ ថាឱ្យឈប់ឈ្លោះគ្នាទៅ ប៉ុន្ដែ គាត់មិនចង់មកផ្ទះខ្ញុំវិញទេ។ ពេលបងខ្ញុំមកដល់ផ្ទះខ្ញុំវិញ គាត់វាយតប់គ្នាជាមួយប្ដីខ្ញុំទៀត ដោយគាត់ខំជួយការពារម្ដាយ និងរូបខ្ញុំ ហើយគាត់វាយប្ដីខ្ញុំរហូតដល់សន្លប់។ ម្ដាយខ្ញុំ និងខ្ញុំបានរត់ចូលក្នុងបន្ទប់ដាក់គន្លឹះទ្វារជាប់ ព្រមទាំងស្រែកទ្រហោយំយ៉ាងខ្លាំង។*

*មានអ្នកជិតខាងម្នាក់ចូលមក ហើយបានឃើញបងខ្ញុំកំពុងវាយប្ដីខ្ញុំ។ គាត់បានឃាត់អ្នកទាំងពីរកុំឱ្យវាយគ្នាតទៅទៀត ហើយបានជួយជូនប្ដីខ្ញុំទៅមន្ទីរពេទ្យ។ មួយថ្ងៃក្រោយមក នគរបាលបានកោះហៅម្ដាយខ្ញុំនិងបងប្រុសខ្ញុំទៅប៉ុស្ដិ៍ ដោយគេនិយាយថា ប្ដីខ្ញុំបានប្ដឹងបងប្រុស និងម្ដាយខ្ញុំ ហើយគេបានបញ្ជាឱ្យបង់លុយចំនួន ១.000ដុល្លារអាមេរិក។ បងប្រុសខ្ញុំមិនចង់បង់លុយសងទេ។ គាត់និយាយថា ប្ដីខ្ញុំបានព្យាយាមសម្លាប់ខ្ញុំហើយថែមទាំងបានវាយម្ដាយខ្ញុំថែមទៀត ហើយអ្វីដែលគាត់បានធ្វើ គឺដើម្បីការពារពួកខ្ញុំតែប៉ុណ្ណោះ ។*

*ប៉ុន្តែ នគរបាលនិយាយថាបើមិនបង់លុយទេ នោះគាត់នឹងត្រូវជាប់គុក ។*

*បងប្រុសខ្ញុំលែងរស់នៅជាមួយគ្រួសារខ្ញុំទៀតទេ ហើយបច្ចុប្បន្ននេះ ខ្ញុំកំពុងដាក់ពាក្យបណ្តឹងលះលែងជាមួយប្តីខ្ញុំ ។ អ្វីៗដែលខ្ញុំរៀនសូត្របានពីបញ្ហានេះ គឺខ្ញុំស្អប់ប្តីខ្ញុំខ្លាំងណាស់ ខ្ញុំខ្លាចមនុស្សប្រុសគ្រប់គ្នា ហើយស្អប់នគរបាលទាំងអស់ដោយគេពុំដែលបានជួយដល់នារីរងគ្រោះទេ ។*

*នេះជារឿងរ៉ាវរបស់ខ្ញុំ ។*

# អំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា

អំពើហិង្សាក្នុងគ្រួសារ គឺជាបញ្ហាដែលមានភាពស្មុគ្រស្មាញខ្លាំង ហើយលើសពីទៀតនេះ គឺជាអំពើមួយលាយឡំជាមួយប្រពៃណីវប្បធម៌មិនទន់ខ្សោយ និងពីភាពងាយចុះចាញ់របស់ស្ត្រីកម្ពុជា។ បុរសជាច្រើនមិនដែលទទួលស្គាល់ថាស្ត្រីមានសិទ្ធិសេរីភាពចាកផុតពីរាល់ទំរង់នៃអំពើហិង្សាសោះឡើយ ម្យ៉ាងវិញទៀតស្ត្រីជាច្រើនក៏មិនដែលបានយល់ដឹងលើសិទ្ធិនេះឡើយ ឬមិនមានអារម្មណ៍ថា តើពួកគេអាចមានមធ្យោបាយណាដើម្បីធ្វើរឿងនេះឱ្យជាក់លាក់ឡើយ ។ ក្រោយពេលមានការអនុម័ត *ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ* កាលពីឆ្នាំ២០០៥មក មានការទទួលស្គាល់ខ្លះៗអំពីសិទ្ធិស្ត្រីដែលមានពីកំណើតត្រូវទទួលបានសិទ្ធិរួចផុតពីអំពើហិង្សា ប៉ុន្តែស្ត្រីកម្ពុជា មន្ត្រីអនុវត្តច្បាប់ និងសាធារណៈជនទូទៅភាគច្រើនពុំដែលដឹងថាមានច្បាប់នេះនៅឡើយទេ ។

នៅកម្ពុជាស្ត្រីត្រូវបានគេមើលឃើញថាជាមនុស្សទន់ខ្សោយជាងបុរសជាដៃគូ។ បញ្ហានេះបានឆ្លុះបញ្ចាំងនៅក្នុងច្បាប់ទំនៀមទំលាប់ វប្បធម៌ ដូចជាច្បាប់ស្រីបានបង្រៀនឱ្យស្ត្រីទាំងឡាយត្រូវគោរពកោតខ្លាចបុរស។ ថ្វីត្បិតបើរាជរដ្ឋាភិបាលកម្ពុជាប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារក៏ដោយ តែនៅមានតម្រូវការឱ្យមានការព្យាយាមផ្លាស់ប្តូរច្រើនថែមទៀត ជាពិសេសក្នុងផ្នែកនីតិក្រម។ សំខាន់បំផុត គឺត្រូវធ្វើយ៉ាងណាឱ្យជនល្មើសក្នុងអំពើហិង្សាក្នុងគ្រួសារដឹងថា ពួកគេជាអ្នកទទួលខុសត្រូវនូវរាល់អំពើដែលខ្លួនប្រព្រឹត្ត ហើយអាចប្រឈមនឹងការដាក់ទណ្ឌកម្ម ។

បញ្ហាមួយទៀតនោះ គឺជានិន្នាការសង្គមដែលនៅចាត់ទុកថាអំពើហិង្សាក្នុងគ្រួសារជាបញ្ហាផ្ទៃក្នុងគ្រួសារដែលបញ្ហានេះធ្វើឱ្យភាគីជនរងគ្រោះមានការស្ទាក់ស្ទើរក្នុងការស្វែងរកជំនួយពីមនុស្សដទៃ ឬទទួលស្គាល់ថានេះជាបញ្ហាគ្រួសារខ្លួន។ នេះជាការប៉ះទង្គិចខាងទស្សនៈដែលចាំបាច់ត្រូវផ្លាស់ប្តូរ ដើម្បីឱ្យជនរងគ្រោះ ជនល្មើស អាជ្ញាធរ និងសាធារណៈជនទូទៅអាចសហការគ្នា ដើម្បីលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ ។

## ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

ច្បាប់នេះ គឺជាច្បាប់រដ្ឋបាលដែលធ្វើឱ្យនីតិក្រមមានភាពពេញលេញ ហើយជំរុញឱ្យអំពើហិង្សាក្នុងគ្រួសារក្លាយជាអំពើខុសច្បាប់ ។ ជាពិសេស អំពើហិង្សាក្នុងគ្រួសារត្រូវបានឱ្យនិយមន័យថា ជាអំពើហិង្សាដែលកើតឡើងរវាងមនុស្ស ដែលរស់នៅក្នុងផ្ទះជាមួយគ្នា និងសមាជិកជាកូនចៅនៅក្នុងបន្ទុកគ្រួសារ[៥] ។

**អំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា ត្រូវបានគ្រប់គ្រងដោយ:**

- ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ
- ច្បាប់អ៊ិនតាក់
- ច្បាប់ស្ដីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ
- រដ្ឋធម្មនុញ្ញកម្ពុជា

**អំពើហិង្សាក្នុងគ្រួសារត្រូវបានឱ្យនិយមន័យរួមមាន :**

- ការប៉ះពាល់ដល់ជីវិត
- ការប៉ះពាល់ដល់បូរណភាពរាងកាយ
- អំពើទារុណ្ណកម្ម ឬការធ្វើអំពើឃោរឃៅ
- ការគំរាមកំហែងដែលប៉ះពាល់ដល់ផ្លូវចិត្ត សតិអារម្មណ៍ បញ្ញាស្មារតី
- ការធ្វើឱ្យប៉ះទង្គិចលើផ្លូវចិត្ត និងលើរូបកាយដែលប្រព្រឹត្តហួសសីលធម៌ និងច្បាប់កំណត់
- ការរំលោភបំពានផ្លូវភេទ (ដូចជាការប្រើហិង្សាសេពសន្ថវៈ ការបៀតបៀនកេរ្តិ៍ខ្មាស និងការធ្វើអាស្រូវភាស)
- ការគំរាមកំហែងក្នុងគោលបំណងបំភិតបំភ័យ តក់ស្លុត និង
- អំពើទាំងឡាយដែលប៉ះពាល់ដល់បុគ្គល និងទ្រព្យសម្បត្តិ ។

## និយមន័យមិនពេញលេញនៃអំពើហិង្សាក្នុងគ្រួសារនៅក្នុងច្បាប់ ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

## មនុស្សរស់នៅក្រោមដំបូលផ្ទះតែមួយ

មាត្រា ២ នៃច្បាប់នេះបានឱ្យនិយមន័យនូវពាក្យជនរងគ្រោះថា " *ជនទាំងឡាយរស់នៅក្រោមដំបូលផ្ទះ និងកូនចៅនៅក្នុងបន្ទុកគ្រួសារ* " ប៉ុន្តែអំពើហិង្សាក្នុងគ្រួសារបានពាក់ព័ន្ធទៅនឹងមនុស្សដែលមិនបានរស់នៅក្នុងផ្ទះជាមួយគ្នានោះ មិនត្រូវបានគេរាប់បញ្ចូលទេ។ ឧទាហរណ៍: នៅកម្ពុជាទំនាក់ទំនងជាទូទៅរវាងបុរស និងគូរកំណាន់ សង្សារ ឬអតីតភរិយាមិនបានរាប់ចូលក្នុងនិយមន័យនៃជនរងគ្រោះដែលត្រូវការការពារឡើយ។ ស្ត្រីដែល

[៥] មាត្រា ២ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ។

រស់នៅក្នុងស្ថានភាពបែបនេះអាចជាមនុស្សស្ថិតក្នុងភាពគ្រោះថ្នាក់ដោយអំពើហិង្សាពីសំណាក់ដៃគូររបស់ពួកគេ ។

ភស្តុតាងខ្លះបានបញ្ជាក់ថា នៅពេលដែលសមាជិករដ្ឋសភាពិភាក្សាអំពីសេចក្តីព្រាងច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារបានជជែកអំពីនិយមន័យនៃអំពើហិង្សាក្នុងគ្រួសារយ៉ាងទូលំទូលាយ ដោយរាប់បញ្ចូលទាំងគូរកំណាន់ សង្សារ អតីតភរិយា ផងដែរ ។ ទោះជាយ៉ាងណាក្តី មានសមាជិករដ្ឋសភាមួយចំនួនមានអារម្មណ៍ថាត្រូវទទួលការពិតចំពោះការរួមរ័ក និងភាពទំនាក់ទំនងស្នេហាក្រៅចំណងអាពាហ៍ពិពាហ៍ ដែលជាទង្វើផ្ទុយនឹងទំនៀមទំលាប់ខ្មែរ ។ ហេតុនេះការសំរេច ឱ្យមាននិយមន័យនេះនៅមានភាពតូចចង្អៀតនៅឡើយ ។

## កូនចៅជាសមាជិកក្នុងបន្ទុកគ្រួសារ

និយមន័យអំពីមនុស្សដែលត្រូវការការពារដោយច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះមានវិសាលភាពគ្របដណ្តប់ទៅលើ *"កូនចៅជាសមាជិកក្នុងបន្ទុក"* ប៉ុន្តែ ពុំមានសេចក្តីបញ្ជាក់ចំពោះពាក្យនេះថែមទៀតឡើយ ។ ដោយសារតែហេតុផលសេដ្ឋកិច្ច ឬហេតុផលផ្សេងៗទៀត ការរើសអើងអាចកើតឡើងនៅពេលស្ថានភាពណាមួយដែលបានកើតឡើងលើសាច់ញាត្តិជាស្ត្រីណាម្នាក់ដូចជាមីង/ម្តាយធំ ឬម្តាយត្រូវរងការរំលោភបំពាន ហេតុនេះគេមិនបានចាត់ទុកថាជា *"កូនចៅជាសមាជិកក្នុងបន្ទុក"*

## ហិង្សាផ្នែកសេដ្ឋកិច្ច

អំពើហិង្សាផ្នែកសេដ្ឋកិច្ចជាហេតុធ្វើឱ្យស្ត្រីបាត់បង់ឱកាសរកការងារ លទ្ធភាពបង្កើនប្រាក់ចំណូល និងគំរិតជីវភាពរស់នៅប្រសើររបស់ពួកគេ ។ អំពើហិង្សាផ្នែកសេដ្ឋកិច្ចវាទាក់ទិនជាធម្មតាជាមួយនឹងបុរសដែលបង្ខំស្ត្រីឱ្យក្លាយជាមនុស្សពឹងផ្អែកសេដ្ឋកិច្ចលើពួកគេ ។ អំពើហិង្សាផ្នែកសេដ្ឋកិច្ចមិនត្រូវបានកំណត់និយមន័យនៅក្នុងច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារទេ ហេតុដូច្នេះ ចំណុចនេះវាផ្ទុយទៅនឹងអនុសញ្ញា CEDAW ។

## មាត្រាចែងពីទោសទណ្ឌនៃអំពើហិង្សាក្នុងគ្រួសារ

ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ មិនមានមាត្រាណាមួយចែងឱ្យច្បាស់លាស់អំពីការផ្តន្ទាទោសទេ នេះស្តែងឱ្យឃើញថា ច្បាប់នេះពុំអាចផ្តន្ទាទោសជនល្មើសដែលប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារទេ។ ប៉ុន្តែមាត្រា ៣៥ នៃច្បាប់នេះបានភ្ជាប់រាល់អំពើហិង្សាក្នុងគ្រួសារទាំងឡាយដែលគេចាត់ទុកជាបទល្មើសព្រហ្មទណ្ឌត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌវិញ ។ ចំណុចនេះស្តែងបញ្ជាក់ថា អំពើហិង្សាក្នុងគ្រួសារបានពិពណ៌នានៅក្នុងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះអាចដាក់

ទោសបានតាមតម្លៃសមមូលមាត្រានៃច្បាប់ព្រហ្មទណ្ឌ។ បច្ចុប្បន្ននេះ កម្ពុជាពុំទាន់មានច្បាប់ព្រហ្មទណ្ឌណាមួយជាក់លាក់នៅឡើយទេ ប៉ុន្តែ *បទល្មើសព្រហ្មទណ្ឌនានាត្រូវបានផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌអន្តរកាល និងច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ*។

បទល្មើសព្រហ្មទណ្ឌនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល និងក្នុងច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលឆ្លើយតបជាមួយនឹងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះនោះ រួមមានបទល្មើសមនុស្សឃាតដោយអចេតនា និងដោយចេតនា ឃាតកម្ម ឃុំឃាំងខុសច្បាប់ បៀតបៀនកេរ្តិ៍ខ្មាស រំលោភសេពសន្ថវៈ និងបង្ករបួសស្នាម។ តាមទ្រឹស្តីនេះមានន័យថា អំពើហិង្សាក្នុងគ្រួសារដែលជាសកម្មភាពពាក់ព័ន្ធនឹងបទល្មើសទាំងនេះនឹងត្រូវបានផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌអន្តរកាល និងច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។ ជាអកុសលមិនមែនរាល់ធាតុផ្សំទាំងឡាយនៃអំពើហិង្សាក្នុងគ្រួសារ (ដែលបានបញ្ញត្តិដោយច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនេះ) សុទ្ធតែស្របគ្នាជាមួយបទល្មើសវាយដំធ្វើឱ្យមានរបួសស្នាម ដូចបានបញ្ញត្តិនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាលឡើយ។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះបានចែងនូវធាតុផ្សំនៃហិង្សាខាងស្មារតី/ចិត្តសាស្ត្រ ដែលមិនត្រូវបានគ្របដណ្តប់ដោយច្បាប់ព្រហ្មទណ្ឌអន្តរកាលដែលគេពិចារណាតែអំពើហិង្សាលើរាងកាយតែប៉ុណ្ណោះ។ ហេតុដូច្នេះ ពេលដែលច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ បានចាត់ទុកអំពើហិង្សាខាងស្មារតី/ផ្លូវចិត្តថាជាបទល្មើសឧក្រិដ្ឋនោះ ពេលនេះគ្មានច្បាប់ព្រហ្មទណ្ឌណាមួយមានឥទ្ធិពលដាក់ទោសបញ្ញត្តិបទល្មើសបែបនេះឡើយ។

## កិច្ចការពារខ្លួន

គួរកត់សម្គាល់ថា ពុំទាន់មានមាត្រាណាមួយចែងអំពីធាតុផ្សំនៃកិច្ចការពារខ្លួនក្នុងនីតិក្រមកម្ពុជាសម្រាប់ស្ត្រីការពារខ្លួនពីអំពើហិង្សាក្នុងគ្រួសារឡើយ។ កន្លងមក មានករណីជាច្រើនដែលស្ត្រីកម្ពុជាត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារដោយសារបានសម្លាប់ប្តីរបស់ខ្លួន ដោយសារបុព្វហេតុកិច្ចការពារខ្លួនពីអំពើហិង្សាក្នុងគ្រួសារ នឹងនៅមានករណីជាច្រើន កិច្ចការពារខ្លួនមិនត្រូវបានគេលើកយកមកពិចារណាទេ។ ការបាត់បង់កិច្ចការពារបែបនេះពីក្នុងច្បាប់ពាក់ព័ន្ធទាំងនោះ វាជាការរើសអើងចំពោះស្ត្រីកម្ពុជាដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ដើម្បីជាវិធីការពារខ្លួនពការរំលោភបំពានម្តងហើយម្តងទៀត ទើបបណ្តាលឱ្យពួកគេរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌដែលពុំបាន កំណត់និយមន័យពីកិច្ចការពារខ្លួននៅក្នុងច្បាប់ណាមួយ ។

## អំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍

រហូតមកដល់ឆ្នាំ២០០៥ កន្លងទៅនេះ ទើបច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះត្រូវបានអនុម័ត ប៉ុន្តែកន្លងមក មិនមានបទល្មើសព្រហ្មទណ្ឌនៃអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍បានចែងនៅក្នុងច្បាប់កម្ពុជាណាមួយឡើយ។ ខណៈពេលដែលអំពើរំលោភសេពសន្ថវៈ គឺជាបទល្មើសព្រហ្មទណ្ឌចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល ប៉ុន្តែ តុលាការ និងអាជ្ញាធរមិនចាត់ទុកករណីរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ថាជាបទល្មើសទេ។

មាត្រា ៣ និង ៧ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះមានចែងអំពីអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ដោយរួមបញ្ចូល "ការឈ្លានពានផ្លូវភេទ" ជាទម្រង់មួយនៃអំពើហិង្សាក្នុងគ្រួសារ នឹងរួមបញ្ចូល "ការប្រើហិង្សាសេពសន្ថវៈ" ដែលជាធាតុផ្សំមួយរបស់ "ការឈ្លានពានផ្លូវភេទ"។ ជាអកុសល នៅក្នុងច្បាប់ពុំមានចែងនិយមន័យនៃពាក្យ "ការប្រើហិង្សាសេពសន្ថវៈ"ទេ។ សកម្មភាពនៃអំពើរំលោភសេពសន្ថវៈ គឺជាសកម្មភាពហិង្សាមាននៅក្នុងបទល្មើសនោះរួចស្រេចទៅហើយ ដូច្នេះ មិនចាំបាច់បញ្ចូលពាក្យហិង្សាបន្ថែមភ្ជាប់ជាមួយអំពើរំលោភសេពសន្ថវៈនោះទេ។ តាមមើលទៅស្ត្រីកម្ពុជាភាគច្រើនដែលជាភរិយាមិនអាចតស៊ូប្រឆាំងតបតនឹងប្តីរបស់ពួកគេទេ ហើយព្រមនៅស្ងៀមស្ងាត់នៅពេលដែលប្តីរបស់គេប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះពុំបានការពារគ្រប់គ្រាន់ចំពោះស្ត្រីឱ្យរួចផុតពីអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ទេ។ យោងតាមច្បាប់ដែលចែងថា "ការប្រើហិង្សាសេពសន្ថវៈ" និងការមិននិយាយអំពីបញ្ហានៃការព្រមព្រៀង ជាកត្តាសំខាន់បញ្ជាក់ពីអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍(ឬក្នុងករណីរំលោភសេពសន្ថវៈខ្លះទៀត)។ នេះមានន័យថាជនរងគ្រោះទាំងឡាយ ត្រូវតែបង្ហាញភស្តុតាងអំពីហិង្សាដែលបានប្រព្រឹត្តនៅពេលមានអំពើរំលោភសេពសន្ថវៈ។ (ហើយបញ្ហានេះវាកាន់តែអាក្រក់ថែមទៀត ដូចគ្នានឹងការឱ្យនិយមន័យមិនពេញលេញនៃអំពើរំលោភសេពសន្ថវៈដែលមានចែងក្នុងច្បាប់អ៊ុនតាក់: មើលជំពូក ៤ (អំពើរំលោភសេពសន្ថវៈ) ក្នុងរបាយការណ៍នេះ)។

## ការដាក់ពិន័យតាមទម្លាប់វប្បធម៌ខ្មែរ

មាត្រា ៨ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារ ជនរងគ្រោះ បានចែងអំពីការដាក់ពិន័យមនុស្ស (រួមទាំងប្តីប្រពន្ធ) ស្របតាម វប្បធម៌ទំនៀមទំលាប់ខ្មែរត្រូវបានអនុញ្ញាត តែត្រូវអនុលោមទៅនឹង "អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស និងសិទ្ធិកុមារ"។ ចំណុចដែលចែងនៅក្នុងមាត្រានេះមានភាពមិនច្បាស់លាស់ ថាតើចំណុចនេះចង់និយាយរួមទាំងកិច្ចការពារសិទ្ធិស្ត្រី ដែលមានចែងនៅក្នុង

អនុសញ្ញា CEDAW ដែរ ឬអត់។ ប្រសិនបើ មាត្រានេះពុំមានចេតនារួមបញ្ចូលនូវការគោរពសិទ្ធិស្ត្រីដូចមានចែងក្នុងអនុសញ្ញា CEDAW ទេនោះ គឺពិតជាមានទម្រង់នៃការដាក់ពិន័យមួយចំនួនត្រូវបានអនុញ្ញាត ឱ្យដាក់ពិន័យចំពោះស្ត្រីដែលបានប្រព្រឹត្តអំពើហិង្សា។ បុរសកម្ពុជាមានសក្តានុពលព្យាយាមប្រើប្រាស់មាត្រានេះ ដើម្បីការពារខ្លួនឯងឱ្យចាកផុតពីការចោទប្រកាន់ បទល្មើសឧក្រិដ្ឋ ឬការដាក់ទោសទណ្ឌផ្សេងៗចំពោះការប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ (បុរសៗហាក់ដូចជាចង់ដាក់ពិន័យទៅលើស្ត្រីដែលជាប្រពន្ធពួកគេច្រើនជាងខ្លួនឯង)។

**"ពួកប្រុសៗចេញទៅក្រៅផ្ទះសេពសុរា ហើយវាយប្រពន្ធរបស់ពួកគេ ប៉ុន្តែសង្គមពុំបានស្តីបន្ទោស ឬទិតៀនពួកគេឡើយ។ ខ្ញុំមានអារម្មណ៍ថា ស្ត្រីជាកម្មវត្ថុដាក់ឱ្យទទួលរងនូវអំពើអយុត្តិធម៌។"**

*សំដីរបស់ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារអាយុ២៥ ឆ្នាំនៅខេត្តកំពង់ធំ។*

## និយមន័យនៃពាក្យអាជ្ញាធរមានសមត្ថកិច្ច

នៅក្នុងអត្ថន័យច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សា និងកិច្ចការពារជនរងគ្រោះទាំងមូលមានការបញ្ជាក់ថា "អាជ្ញាធរមានសមត្ថកិច្ច" ឬ "អាជ្ញាធរមានសមត្ថកិច្ចនៅជិតបំផុត" ។ ឧទាហរណ៍ មាត្រា ៩ ចែងថា "អាជ្ញាធរមានសមត្ថកិច្ចនៅជិតបំផុតមានភារៈកិច្ចធ្វើអន្តរាគមន៍ជាបន្ទាន់ ក្នុងករណីអំពើហិង្សាក្នុងគ្រួសារកើតឡើង ឬបំរុងនឹងកើតឡើងដើម្បីទប់ស្កាត់ និងការពារជនរងគ្រោះ" ។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះនេះពុំបានបញ្ជាក់ថាអាជ្ញាធរណាមួយក្នុងចំណុចនេះទេ។ ផលវិបាកដែលតែងតែកើតចេញពីស្ថានភាពបែបនេះ គឺអាចមានន័យថាអាជ្ញាធរខកខានមិនបានធ្វើសកម្មភាព ព្រមទាំងមិនបានជួយស្ត្រីរងគ្រោះនៅពេលមានអំពើហិង្សាក្នុងគ្រួសារកើតឡើងផងដែរ។

## ការជម្លៀសជនរងគ្រោះ និងបទបញ្ជាការពារ

មាត្រា ១៣ (២) និង ២៥ (៥) អនុញ្ញាតឱ្យអាជ្ញាធរជម្លៀសជនរងគ្រោះពីកន្លែងកើតអំពើហិង្សាក្នុងករណីពិសេស "ដោយពុំចាំបាច់មានសំណើទេ ប្រសិនបើមានមូលហេតុចាំបាច់ត្រូវធ្វើដូច្នេះ"។ ពុំមានការកំណត់និយមន័យនៃពាក្យ "ករណីពិសេស" ឬ "មូលហេតុចាំបាច់" ទេ។ ការជម្លៀសជនរងគ្រោះចេញអាចមានន័យថាជនរងគ្រោះបានប្រព្រឹត្តកំហុសអ្វីមួយ។ គោលបំណងច្បាប់ គឺផ្តល់អាទិភាពទៅលើកិច្ចការពារជនរងគ្រោះ ហើយមិនត្រូវធ្វើអ្វីដែលនាំឱ្យមានការលំបាកបន្ថែមទៀតដល់ជនរងគ្រោះឡើយ។ គ្រប់ករណីទាំងអស់ជនល្មើស គឺជាមនុស្ស ដែលគួរតែជម្លៀសចេញពីកន្លែងកើតហេតុនៃអំពើហិង្សា ហើយជនរងគ្រោះមិនគួរជម្លៀសដោយគ្មានការយល់ព្រមពីនាងឡើយ។

ជំពូក ៥ នៃច្បាប់នេះបានបញ្ញត្តឱ្យអាជ្ញាធរ តុលាការរមានអំណាចចេញដីកាការពារ។ ប៉ុន្តែ ក្នុងករណីដីកាការពារបណ្តោះអាសន្នជាបន្ទាន់នោះ គួរតែមានមាត្រាណាមួយអនុញ្ញាតឱ្យនគរបាល ឬអាជ្ញាធរដែនដីមាន

អំណាចបណ្ដោះអាសន្នក្នុងការទទួលបាននូវសិទ្ធិអំណាចក្នុងការចេញបទបញ្ជានេះដែរ។ មាត្រា ១៤ អនុញ្ញាតឱ្យធ្វើដូច្នេះ តែទោះជាយ៉ាងណាក៏ដោយ ក៏កង្វះខាតនៃការឱ្យនិយមន័យនៃពាក្យ "អាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត" ខាងលើវាធ្វើឱ្យមានភាពមិនច្បាស់លាស់ ប្រសិនបើមាត្រានេះមានន័យចង់រាប់បញ្ចូលទាំងប៉ូលីស និងអាជ្ញាធរដែនដីនោះ។

## ការផ្សះផ្សា និងការសម្រុះសម្រួល

មាត្រា ២៦ បានចែងថានៅពេលដែលភាគីទាំងពីរយល់ព្រមធ្វើការផ្សះផ្សា ឬសម្រុះសម្រួលនោះគេអាចធ្វើការសម្រុះសម្រួលបានក្នុងករណីហិង្សា ដូចជាហិង្សាក្នុងករណីបទល្មើសព្រហ្មទណ្ឌកំរិតមជ្ឈឹមស្រាល ឬបទលហុដែលធ្វើឱ្យប៉ះពាល់ខាងផ្លូវចិត្ត និងជីវភាពសេដ្ឋកិច្ច។ "បទល្មើសមជ្ឈឹមស្រាល" ឬ" បទល្មិសកំប៉ិកកំប៉ុក" មិនត្រូវបានគេកំណត់និយមន័យ ដើម្បីបើកចំហរឱ្យបទល្មើសបែបនេះត្រូវផ្តន្ទាទោស ដូចជាបទល្មើសដែលពាក់ព័ន្ធផ្សេងទៀតទេ ប៉ុន្តែបទល្មើសបែបនេះត្រូវធ្វើតាមរយៈការផ្សះផ្សាទៅវិញ។ (ក្នុងច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់-បទល្មើសមជ្ឈឹមរួមមានការវាយដំធ្វើឱ្យ មានរបួស និងបៀនបៀតកេរ្តិ៍ខ្មាសជាដើម)។

**"យោងតាមបទពិសោធន៍របស់ខ្ញុំ បានធ្វើឱ្យខ្ញុំមានសង្ឃឹមតិចតួចណាស់អំពីច្បាប់"**

*សំដីរបស់ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារអាយុ២៣ ឆ្នាំនៅខេត្តសៀមរាប។*

ក្នុងខណៈពេលការផ្សះផ្សា និងការសម្រុះសម្រួលដែលជាវិធីមួយផ្សេងល្អលើភាពជាក់ស្តែងក្នុងវប្បធម៌កម្ពុជា គឺស្ត្រីភាគច្រើនទំនងជាត្រូវបង្ខំចិត្តជ្រើសរើសយកវិធីសម្រុះសម្រួលក្នុងករណីព្រហ្មទណ្ឌ ដើម្បីរក្សាកេរ្តិ៍ឈ្មោះគ្រួសារ នឹងមិនចង់ឱ្យមានរឿងវែងឆ្ងាយចំពោះករណី "*តូចតាច*" ដែលមិនមែនជាអំពើហិង្សាលើរាងកាយនោះ។ ប៉ុន្តែដើម្បីការពារជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារឱ្យមានប្រសិទ្ធិភាព ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះគួរតែចែងឱ្យច្បាស់លាស់ស្តីពីការផ្សះផ្សានិងការសម្រុះសម្រួល នឹងត្រូវបញ្ជាក់ឱ្យជាក់លាក់ពីប្រភេទនៃអំពើហិង្សាបែបណាដែលត្រូវបញ្ចូលក្នុងដំណើរការផ្សះផ្សា ឬការសម្រុះសម្រួល។

នៅក្នុងមាត្រា ២៦ បានចែងផងដែរថា "សមាជិកក្នុងគ្រួសារ" អាចជ្រើសរើសអាជ្ញាកណ្តាលនៅពេលមានការព្រមព្រៀង ដើម្បីធ្វើការផ្សះផ្សា ឬការសម្រុះសម្រួលគ្នា (មាត្រានោះបញ្ជាក់ឧទាហរណ៍អំពីអាជ្ញាកណ្តាល រួមមានដូចជា: ឪពុកម្តាយ ញាត្តិសន្តាន និងបង១ជាដើម)។ មាត្រានេះមានភាពអយុត្តិធមិយ៉ាងខ្លាំងដោយការជ្រើសរើសនេះវាគួរតែជាជនរងគ្រោះ ជាអ្នកមានសិទ្ធិក្នុងការ ជ្រើសរើសធ្វើជាអាជ្ញាកណ្តាល។ សមាជិកក្នុងបន្ទុកគ្រួសារគេអាចជ្រើសរើសអាជ្ញាកណ្តាលដូចជា: ឪពុកម្តាយ ឬបងប្អូនបង្កើតដែលភាគច្រើនជាមនុស្សអាចមានភាពលំអៀង ហើយផ្តោតទៅលើការរក្សានូវទំនាក់ទំនងជាជាងការជួយជនរងគ្រោះ និងគោរពតាមបំណងប្រាថ្នារបស់នាង។ ក្រៅពីនេះអ្នកជ្រើសរើសធ្វើជាអាជ្ញាកណ្តាលសំរាប់គូរភាគី ដែលត្រូវគេស្គាល់ឱ្យមកសម្រុះ

សម្រួលក្នុងករណីរបស់ខ្លួន (ដូចជាៈ ឪពុកម្តាយ និងញាត្តិសន្តានជាដើម) ។ ការធ្វើបែបនេះរឹតតែធ្វើឱ្យជនរងគ្រោះទទួលរងការលំបាកខ្លាំងថែមទៀត ដោយជនរងគ្រោះត្រូវទទួលសម្ពាធពីគ្រួសាររបស់ខ្លួនឱ្យយល់ព្រមទទួលយកការសំរេចរបស់អាជ្ញាកណ្តាល ដែលអាចជាមនុស្សរលំអៀង ហើយអាចគាំទ្រផលប្រយោជន៍ជនល្មើសដោយមិនគិតពីការរងទុក្ខសោកនៃភាគីជនរងគ្រោះទៀតផង។

## វិធានការស្តារនីតិសម្បទា

នៅក្នុងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ពុំមានមាត្រាចែងអំពីការស្តារនីតិសម្បទាឡើយ។ អនុសាសន៍ទូទៅ ១៩ចំណុច នៃអនុសញ្ញា CEDAW បាននិយាយថា រដ្ឋនានាគួរអនុវត្ត" វិធានការការពាររួមមាន ការជម្លៀស ប្រឹក្សាយោបល់ ស្តារនីតិសម្បទា និងសេវាឧបត្ថម្ភផ្សេងៗសម្រាប់ស្ត្រីរងគ្រោះដោយអំពើហិង្សា ឬស្ត្រីប្រឈមមុខនឹងគ្រោះថ្នាក់ដោយអំពើហិង្សា[១០] ។"

## សេចក្តីសន្និដ្ឋាន

សេចក្តីអនុម័តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះក្នុងឆ្នាំ២០០៥ គឺជាពេលវេលាមួយកំពុងបង្ហាញពីការបោះជំហានឆ្ពោះទៅរកកិច្ចការពារសិទ្ធិស្ត្រី នឹងលុបបំបាត់ភាពរើងអើងប្រឆាំងនារីភេទ ។ ប៉ុន្តែច្បាប់នេះ នៅមិនទាន់មានលក្ខណៈគ្រប់គ្រាន់ល្មមស្របទៅនឹងមាត្រាចែងនៅក្នុង CEDAW នៅឡើយ ។ ច្បាប់នេះនៅមានចំណុចខ្វះខាតលើការកំណត់និយមន័យ-ថាតើអ្វីទៅជាអំពើហិង្សាក្នុងគ្រួសារ ការផ្សះផ្សារ និងការសម្រុះសម្រួល និងកង្វះនូវភាពមិនចុះសម្រុងស្របទៅនឹងច្បាប់ព្រហ្មទណ្ឌ ហើយទាំងអស់នេះជាខ្លឹមសារខ្លះៗដែលផ្ទុយគ្នាពី CEDAW ។ ម្យ៉ាងវិញទៀត ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ មានចំណុចរើសអើងលើជនរងគ្រោះដោយមិនបានផ្តល់កិច្ចការពារឱ្យបានគ្រប់គ្រាន់ផងដែរ ។

□□□

[១០] អនុសាសន៍ទូទៅ ១៩ ចំណុចនិយាយអំពីមាត្រាមួយចំនួននៅអនុសញ្ញា CEDAW (កថាខណ្ឌ ២៤ (ន) (iii) )។

# ៣. អាពាហ៍ពិពាហ៍

## អនុសញ្ញា CEDAW

*"១.រដ្ឋជាភាគី នឹងប្រកាន់យកគ្រប់វិធានការណ៍សមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនារីភេទនៅក្នុងគ្រប់វិស័យដែលទាក់ទិនទៅនឹងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងគ្រួសារ និងជាពិសេសដោយឈរលើមូលដ្ឋានសមភាពរវាងបុរស និងនារី :*

*(ក) -សិទ្ធិដូចគ្នាក្នុងអាពាហ៍ពិពាហ៍ ។*

*(ខ) -សិទ្ធិដូចគ្នាក្នុងការជ្រើសរើសគូស្រករដោយសេរី និងរៀបអាពាហ៍ពិពាហ៍ដោយការស្ម័គ្រចិត្តទាំងស្រុង និងដោយគ្មានការបង្ខិតបង្ខំ ។*

*(គ) -សិទ្ធិនិងការទទួលខុសត្រូវដូចគ្នានៅក្នុងចំណងអាពាហ៍ពិពាហ៍ និងនៅក្នុងការរំលាយកិច្ចអាពាហ៍ពិពាហ៍នេះ (ការលះលែងគ្នា) ។*

*(ឃ) សិទ្ធិនិងការទទួលខុសត្រូវដូចគ្នានៅក្នុងតួនាទីជាឪពុកម្តាយ នៅលើគ្រប់វិស័យដែលទាក់ទងទៅនឹងកូនចៅខ្លួនដោយមិនគិតពីស្ថានភាពអាពាហ៍ពិពាហ៍ឡើយ ។ នៅក្នុងគ្រប់ករណីទាំងអស់ផលប្រយោជន៍របស់កូនចៅត្រូវស្ថិតនៅជាចំបង ។*

*(ង) -សិទ្ធិដូចគ្នាក្នុងការសំរេចដោយសេរីនិងក្នុងស្មារតីទទួលខុសត្រូវ នូវចំនួនកូននិងចន្លោះពេលដែលត្រូវមានកូនហើយមានលទ្ធភាពនឹងទទួលព័ត៌មាន ការអប់រំ និងមធ្យោបាយនានាដែលអាចអោយនារីប្រើប្រាស់បាននូវសិទ្ធិទាំងឡាយនេះ ។*

*(ច) -សិទ្ធិនិងការទទួលខុសត្រូវដូចគ្នានៅការថែទាំ ការធ្វើអាណាព្យាបាល ការទទួលបន្ទុក និងការសុំចិញ្ចឹមកូន ឬក៏នៅក្នុងទំរង់ដូចគ្នានេះ បើសិនជាគោលគំនិត ទាំងនេះនៅក្នុងបញ្ញត្តិច្បាប់ប្រទេសជាតិហើយ ។ នៅក្នុងគ្រប់ករណីទាំងអស់ផលប្រយោជន៍របស់កូនចៅត្រូវស្ថិតនៅជាចំបង ។*

*(ឆ) -សិទ្ធិជាបុគ្គលដូចគ្នាក្នុងតួនាទីជាប្តី និងប្រពន្ធរួមបញ្ចូលទាំងការជ្រើសរើសនាមត្រកូល វិជ្ជាជីវៈ និងមុខរបរផង ។*

*(ជ) -សិទ្ធិដូចគ្នាសំរាប់គូស្រករទាំងពីរនៅក្នុងការកាន់កាប់កម្មសិទ្ធ ការទទួលបានការចាត់តាំង ការគ្រប់គ្រង ការអាស្រ័យផល និងប្រើប្រាស់កម្មសិទ្ធ ទោះជាដោយមិនគិតថ្លៃក្តី ឬគិតថ្លៃក្តី ។*

*២. ការភ្ជាប់ពាក្យ និងការរៀបអាពាហ៍ពិពាហ៍បុត្រធីតាពុំមានឥទ្ធិពលអ្វីខាងផ្លូវច្បាប់ឡើយ ដូច្នោះត្រូវតែប្រកាន់យកវិធានការណ៍ចាំបាច់នានារួមបញ្ចូលទាំងបញ្ញត្តិច្បាប់ផង ដើម្បីកំណត់ពីអាយុតិចបំផុតក្នុងការរៀបអាពាហ៍ពិពាហ៍ហើយនឹងការដាក់កំហិតឱ្យចុះបញ្ជីការរៀបអាពាហ៍ពិពាហ៍ ជាចាំបាច់ក្នុងបញ្ជីផ្លូវការ[១១] "។*

## ករណីសិក្សាទី២: រឿងរបស់ណារ៉ែន

*នាងខ្ញុំឈ្មោះ ណារ៉ែន អាយុ៣៩ឆ្នាំ ហើយខ្ញុំបានព្យាយាមគេចចេញពីអំពីរំលោភបំពាននៅក្នុងចំណងអាពាហ៍ពិពាហ៍របស់ខ្ញុំ ។ ខាងក្រោមនេះគឺជារឿងរ៉ាវរបស់ខ្ញុំ ។*

*បញ្ហារបស់ខ្ញុំជាមួយប្តីខ្ញុំឈ្មោះ វុទ្ធី កើតមានបន្ទាប់ពីដើមដំបូងនៃអាពាហ៍ពិពាហ៍មកម្ល៉េះ ក្រោយពេលគាត់មានស្រីកំណាន់ ។ ស្រីកំណាន់រស់នៅភូមិជាប់គ្នា ហើយប្តីរបស់ខ្ញុំតែងតែទៅរកនាងរៀងរាល់ចុងសប្តាហ៍ ។ មុនដំបូងគាត់ប្រាប់ខ្ញុំថា ទៅលេងផ្ទះមិត្រភ័ក្រ្ត ឬធ្វើការងារ ប៉ុន្តែក្រោយមកគាត់ចេញពីផ្ទះដោយមិនបាច់ប្រាប់ថាទៅណាឡើយ ។ ខ្ញុំបានដឹងថាគាត់ទៅធ្វើអ្វី ។ ដើម្បីអនាគតកូន៧ ខ្ញុំបានអត់ធ្មត់រស់នៅជាមួយគាត់ដោយរងទុក្ខសោក ទោះបីជាគាត់រំលោភបំពានលើរាងកាយ និងផ្លូវចិត្តខ្ញុំយ៉ាងណាក៏ដោយ ។ ជាញឹកញាប់គាត់បង្ខំរួមរ័ក ហើយស្រែកគំហកដាក់ខ្ញុំព្រមទាំងជេរថា ខ្ញុំជាប្រពន្ធមិនល្អ ការរំលោភដ៏ធ្ងន់ធ្ងរជាច្រើនតែងកើតឡើងនៅពេលដែលគាត់មកពីផ្ទះស្រីកំណាន់របស់គាត់វិញ ។ ក្រៅពីការអស់សង្ឃឹម ខ្ញុំក៏បានប្តឹងមេភូមិ ប៉ុន្តែគាត់និយាយថា គាត់មិនអាចជួយខ្ញុំឱ្យរួចផុតពីការលំបាកទាំងនេះបានទេ ហើយប្រាប់ថាខ្ញុំគួរតែសំរបទៅនឹងបញ្ហានេះ ។*

*ច្រើនឆ្នាំកន្លងទៅអំពើហិង្សាចេះតែបន្តឥតឈប់ឈរ ហើយប្តីខ្ញុំពេលខ្លះបាត់មុខជួនកាលអស់រយៈពេលច្រើនសប្តាហ៍ ។ ខ្ញុំក៏បានដឹងថា គាត់ទៅនៅផ្ទះស្រីកំណាន់នោះ ហើយថែមទាំងបានផ្តល់ប្រាក់កាសដល់នាងទៀតផង ។ ដូច្នេះ ខ្ញុំក៏សម្រេចចិត្តទៅជួបមេភូមិម្តងទៀត ហើយគាត់ក៏បានសំណូមពរឱ្យយើងទាំងពីរផ្សះផ្សាគ្នា ។ មេភូមិប្រាប់ថា គាត់នឹងទៅនិយាយជាមួយប្តីខ្ញុំ ដើម្បីឱ្យគាត់ និងខ្ញុំអាចដោះស្រាយបញ្ហាអាពាហ៍ពិពាហ៍នេះ ។ ខ្ញុំរីករាយ ដោយយល់ថា លោកមេភូមិបានជួយក្នុងរឿងនេះ ប៉ុន្តែប្តីរបស់ខ្ញុំបានបដិសេធមិនចូលមកផ្សះផ្សាទេ ហើយបានប្រាប់ខ្ញុំឱ្យបន្តរស់នៅជាមួយប្តីខ្ញុំតទៅទៀត ។*

*ខ្ញុំពិតជាចង់លះលែងគ្នាមែន ។ លើកនេះខ្ញុំទៅរកលោកមេឃុំម្តង ព្រោះយល់ថា គាត់ជាមនុស្សមានអំណាចច្រើនជាង តែលោកមេឃុំនៅតែប្រាប់ខ្ញុំថាត្រូវតែរកវិធីផ្សះផ្សាសិន ព្រោះនេះជានីតិវិធីច្បាប់ ។ ប្តីខ្ញុំ*

[១១] អនុសញ្ញា CEDAW មាត្រា ១៦

ព្រមចូលរួមផ្សះផ្សា ប៉ុន្តែ ជាលទ្ធផលលោកមេឃុំនៅតែប្រាប់ឱ្យខ្ញុំបន្តរស់នៅជាមួយប្តីដោយការគោរពតទៅទៀត។ តែអ្វីៗនៅតែដដែល ប្តីខ្ញុំនៅតែចាកចោលផ្ទះទៅរកស្រីកំណាន់គាត់ ហើយនឹងវាយដំប្រពន្ធកូន ជារឿយៗ។ ខ្ញុំបានទៅរកលោកមេឃុំសារជាថ្មី ដោយសុំគាត់ឱ្យខ្ញុំលះលែងគ្នា តែលោកមេឃុំថា ខ្ញុំត្រូវធ្វើការផ្សះផ្សាមួយលើកទៀតសិន។ លើកនេះ ប្តីខ្ញុំបានសន្យាថា នឹងធ្វើល្អដាក់ខ្ញុំ ហើយឈប់ទៅជួបស្រីកំណាន់គាត់ទៀត ។ ខ្ញុំទទួលអារម្មណ៍ថាល្អប្រសើរព្រមទាំងសង្ឃឹមថាស្ថានភាពនឹងកែប្រែ។

ពីរ-បីសប្តាហ៍ក្រោយមក ប្តីខ្ញុំវិលទៅរកស្រីកំណាន់នោះទៀត។ គាត់កាន់តែមានកំហឹងច្រើនដាក់កូនប្រពន្ធ ព្រមទាំងផ្តល់ប្រាក់កាសទៅស្រីកំណាន់កាន់តែច្រើន។ ហេតុនេះ ខ្ញុំរឹតតែចង់លះលែងភ្លាមៗ ប៉ុន្តែលោកមេឃុំបានប្រាប់ខ្ញុំឱ្យប្តឹងទៅតុលាការដើម្បីលះលែងគ្នា។ ខ្ញុំដឹងថាការដាក់ពាក្យបណ្តឹងត្រូវចំណាយលុយកាក់ច្រើនសំរាប់រូបខ្ញុំដែលជាជនក្រីក្រ។ម្យ៉ាងវិញទៀត ខ្ញុំរិតតែភ័យខ្លាចពីទង្វើប្តីខ្ញុំ ប្រសិនបើរឿងនេះពាក់ព័ន្ធក្នុងតុលាការ ។

ក្រោយមកនៅថ្ងៃមួយនោះ មានមិត្តភ័ក្ត្រម្នាក់ប្រាប់ឱ្យខ្ញុំទៅរកជំនួយពីអង្គការមិនមែនរដ្ឋាភិបាល។ នៅពេលប្តីខ្ញុំរវល់ទៅរកស្រីកំណាន់គាត់ ខ្ញុំបាននាំកូនទៅរកអង្គការមិនមែនរដ្ឋាភិបាលមួយនៅទីរួមខេត្តដើម្បីសុំជំនួយអន្តរាគមន៍។ បុគ្គលិកអង្គការបានសន្យាជួយរៀបចំពាក្យបណ្តឹងដាក់ទៅតុលាការ ប៉ុន្តែ តុលាការនៅតែបន្តធ្វើការផ្សះផ្សានៅចំពោះមុខចៅក្រមម្តងទៀត។ ខ្ញុំបានយល់ព្រម តែខ្ញុំបាននិយាយប្រាប់តុលាការថា ប្តីខ្ញុំនឹងរឹតតែមានកំហឹងនៅពេលគាត់ដឹងថាត្រូវឡើងតុលាការ។ ខ្ញុំមានអារម្មណ៍ភ័យខ្លាចពេលវិលត្រឡប់មកផ្ទះវិញ តែអង្គការមិនមែនរដ្ឋាភិបាលបានជួយរកជំរកបណ្តោះអាសន្នឱ្យខ្ញុំ និងកូនៗស្នាក់នៅ ចៀសវាងការវាយធ្វើបាបពីប្តីកំណាចនោះ។

ប្តីខ្ញុំមានកំហឹងក្រេវក្រោធជាខ្លាំង ពេលគាត់ដឹងថា ខ្ញុំបានដាក់ពាក្យបណ្តឹងសុំលះលែងទៅតុលាការ។ នៅឯតុលាការពេលធ្វើសវនាការការផ្សះផ្សា ខ្ញុំមានការភ័យខ្លាចយ៉ាងខ្លាំងខណៈពេលឃើញមុខគាត់ ដែលខ្ញុំខានឃើញគាត់អស់ជាច្រើនសប្តាហ៍កន្លងមក។ តុលាការនៅតែសំរេចឱ្យខ្ញុំរួមរស់ជាមួយប្តីដដែល។ សូម្បីតែលោកក្រឡាបញ្ជីតុលាការ ក៏និយាយប្រាប់ខ្ញុំថា " កុំព្រួយបារម្ភអី មនុស្សប្រុសសុទ្ធតែអញ្ចឹង "។ ខ្ញុំនៅតែមិនអាចលះលែងគ្នាដដែល ហើយបន្តរស់នៅក្នុងជំរកបណ្តោះអាសន្នសំរាប់ស្ត្រីតទៅទៀត ។

មួយរយៈក្រោយ ខ្ញុំត្រូវចូលរួមការផ្សះផ្សានៅឯតុលាការម្តងទៀត ហើយបានត្រឹមតែទទួលការសំរេចចិត្តពីតុលាការឱ្យខ្ញុំរួមរស់ជាមួយប្តីឡើងវិញ។ នៅពេលដែលតុលាការកោះហៅលើកទី៣ និងជាពេលបើកសវនាការលើកចុងក្រោយ ប្តីខ្ញុំមិនចូលខ្លួនមកទេ ប៉ុន្តែតុលាការបានអនុញ្ញាតឱ្យខ្ញុំលះលែងគ្នា តែប្តីខ្ញុំមិនព្រមលែងទេ នៅក្នុងការសម្រេចនោះ តុលាកាពុំបានសម្រេចឱ្យប្តីខ្ញុំផ្តល់ប្រាក់អាហារកិច្ចចិញ្ចឹមកូនផងទេ។

ខ្ញុំអាចយល់បានថា ប្រសិនបើខ្ញុំមានលុយនោះ ខ្ញុំអាចធ្វើឱ្យករណីដំណើរការក្តីតុលាការនេះលឿន

*ជាងធម្មតា។ ម្យ៉ាងវិញខ្ញុំក៏យល់ដែរថាការរើសអើងចំពោះស្ត្រីបានធ្វើឱ្យខ្ញុំខ្លាច មិនចង់ធ្វើបណ្តឹងជាមួយអាជ្ញាធរដែនដីទេ។ ក្រោយពីបានព្យាយាមគេចចេញពីប្តី និងការរំលោភបំពានអស់ជាច្រើនឆ្នាំមក ខ្ញុំមានអារម្មណ៍សប្បាយចិត្តជាងមុន ប៉ុន្តែខ្ញុំមិនសប្បាយចិត្តចំពោះរបៀបដោះស្រាយយ៉ាងយូរវែងអន្លាយបែបនេះទេ។*

## អាពាហ៍ពិពាហ៍នៅកម្ពុជា

អាពាហ៍ពិពាហ៍នៅកម្ពុជា គឺជាអាពាហ៍ពិពាហ៍មួយដែលហ៊ុមព័ទ្ធដោយបញ្ហាសង្គម និងវប្បធម៌ជាច្រើនជាន់ ហើយកើតមានពាសពេញនៅក្នុងសង្គមកម្ពុជាសព្វថ្ងៃ។ ស្ត្រីកម្ពុជាច្រើននាក់តែងចាត់ទុកខ្លួនថាជាមនុស្សទន់ខ្សោយជាងប្តីរបស់ខ្លួន ហើយកត្តានេះបានបង្កើតឱ្យមានបញ្ហាជាច្រើនដល់ស្ត្រី ជាពិសេសស្ត្រីដែលរងការរំលោភបំពាន ឬស្ត្រីដែលចង់លះលែងប្តី។ តាមប្រពៃណី ស្ត្រីជាច្រើននៅកម្ពុជាត្រូវបានជម្រុញឱ្យរៀបអាពាហ៍ពិពាហ៍តាំងពីវ័យក្មេង ឬជួនកាលមានការគាបសង្កត់ពីសំណាក់ក្រុមគ្រួសារឱ្យរៀបអាពាហ៍ពិពាហ៍។ ការទុកដាក់ឱ្យមានប្តីដោយឪពុកម្តាយ (ជាធម្មតាឪពុកម្តាយ ឬសមាជិកគ្រួសារណាម្នាក់ជាអ្នករៀបចំទុកដាក់កូនចៅ) បញ្ហានេះនៅតែកើតមានដដែល។ ជាពិសេសនៅតាមតំបន់ជនបទ នៅពេលដែលស្វាមី-ភរិយារៀបការរួចហើយ ជារឿយ។ តែងតែមានការគាបសង្កត់យ៉ាងខ្លាំងទៅលើគូរស្វាមី-ភរិយាទាំងពីរកុំឱ្យលះលែងគ្នា។ នៅក្នុងសង្គមកម្ពុជា ការលះលែងគ្នាត្រូវបានចាត់ទុកថាជាអំពើអាម៉ាស់ជាទីបំផុត ជាពិសេស ប្រសិនបើស្ត្រីជាអ្នកចង់លះលែងប្តី ហើយការលះលែងនេះ គឺជាការលំបាកយ៉ាងខ្លាំងទំរាំឈានដល់ការលះលែងតាមច្បាប់ត្រឹមត្រូវនៅទីបញ្ចប់នោះ។ ក្នុងករណីខ្លះការបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍កើតមាននៅពេលដែលស្ត្រីណាម្នាក់មានផ្ទៃពោះ ហើយឱ្យរៀបការជាមួយឪពុករបស់ទារកដែលមិនទាន់កើតមកនោះ ឬនៅពេលដែលស្ត្រីណាម្នាក់ត្រូវគេចាប់រំលោភ ហើយនាងត្រូវបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយបុរសដែលជាជនរំលោភរូបនាងផងដែរ។

ស្ត្រីដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារក៏ជួបប្រទះផលវិបាក ក្នុងការលះលែងជាមួយប្តីរបស់នាងដែរ។ តាមប្រពៃណី នៅក្រោយពេលរៀបការ បុរសជាស្វាមីចូលមករស់នៅក្នុងគ្រួសាររបស់ស្ត្រីជាភរិយា ហើយរស់នៅជាមួយឪពុកម្តាយ និងបងប្អូនរបស់នាង។ ក្នុងករណីខ្លះ ការធ្វើបែបនេះជាការផ្តល់នូវកិច្ចការពារដល់ស្ត្រីជាភរិយាឱ្យរួចផុតពីអំពើហិង្សា ប៉ុន្តែចំណុចមិនល្អនោះ គឺនៅពេលមានអំពើហិង្សា គ្រួសាររបស់នាងអាចជាមនុស្សដែលជម្រុញឱ្យនាងចេះអត់ទ្រាំចំពោះការរំលោភបំពានពីសំណាក់ស្វាមីនាង ហើយព្យាយាមទប់ស្កាត់កុំឱ្យនាងលះលែងគ្នាដោយពុំបានគិតពីផលវិបាករបស់នាងទាល់តែសោះ។ ស្ត្រីភាគច្រើនជាមនុស្សរស់នៅដោយសារប្តីចិញ្ចឹម (ការពឹងផ្អែកថវិកា ឬអ្វីមួយផ្សេងទៀត) ដូច្នេះ បញ្ហានេះស្ត្រីមានការពិបាកក្នុងការចាកចេញពីប្តី ជាពិសេសនៅពេលមានកូនចៅ ។

## ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារត្រូវបានអនុម័តតាំងពីឆ្នាំ១៩៨៩ មកម្ល៉េះ ហើយជាច្បាប់មួយដែលមានលក្ខណៈ *ពិស្តារ* និងមានគោលបំណង ដើម្បីធានានូវសមភាពរបស់គូរស្វាមីភរិយានៅក្នុងចំណងអាពាហ៍ពិពាហ៍ ច្បាប់នេះបានគ្របដណ្តប់នូវចំណុចដូចខាងក្រោមនេះ :

- លក្ខខណ្ឌក្នុងការរៀបអាពាហ៍ពិពាហ៍
- បណ្តឹងទាស់នឹងអាពាហ៍ពិពាហ៍
- មោឃភាពអាពាហ៍ពិពាហ៍
- សិទ្ធិ និងការទទួលខុសត្រូវរបស់គូរស្វាមី-ភរិយា
- ការលះលែង
- អាពាហ៍ពិពាហ៍ជាមួយជនបរទេស
- កូនឥតខាន់ស្លា
- សុំកូនចិញ្ចឹម
- ទំនាក់ទំនងរបស់ឪពុក ម្តាយ និងកូន១ និង
- ការដកហូតអំណាចមេបា

**ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារត្រូវបានគ្រប់គ្រងដោយ:**

- ច្បាប់ស្តីពីអាពារហ៍ពិពារហ៍ និងគ្រួសារ

## អាយុរៀបអាពាហ៍ពិពាហ៍ជាអប្បបរមា

### មាត្រា ៥

*អាចឱ្យរៀបអាពាហ៍ពិពាហ៍បានបុរសចាប់ពីអាយុ ២០ ឆ្នាំឡើងទៅ នារីចាប់ពីអាយុ ១៨ឆ្នាំឡើងទៅ។ ក្នុងករណីពិសេសដែលបុរសមិនទាន់ដល់អាយុ ២០ឆ្នាំ និងនារីអាយុមិនទាន់ដល់ ១៨ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បាន ប្រសិនបើ នារីមានផ្ទៃពោះ ហើយមានការអនុញ្ញាតពីឪពុកម្តាយ ឬអាណាព្យាបាល ។*

មាត្រា ៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារបានចែងពីអាយុអប្បបរមាដើម្បីរៀបអាពាហ៍ពិពាហ៍នៅកម្ពុជា។ ចំណុចនេះឃើញថាមានការរើសអើងចំពោះបុរស ប៉ុន្តែមាត្រានេះ បានបំពេញតាមលក្ខខណ្ឌរបស់អនុសញ្ញា CEDAW[១២] ដោយបានចែងនូវអាយុអប្បបរមាដើម្បីរៀបការ។ បើពិនិត្យមើលផ្នែកទី ២ នៃមាត្រា ៥ នេះបានចែងអំពីការលើកលែងចំពោះអាយុអប្បបរមា ដែលនាំឱ្យខូះលក្ខខណ្ឌអាយុអប្បបរមាពិតប្រាកដទៅ

[១២] អនុសញ្ញា CEDAW ១៩៧៩ មាត្រា ១៦ (២) ។

វិញ។ ភាពមិនស្របគ្នា នៅក្នុងមាត្រា ៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារនេះអាចនាំឱ្យឪពុកម្តាយខាងស្ត្រី ដែលមានផ្ទៃពោះបង្ខំនាងឱ្យព្រមរៀបការដោយពុំបានគិតពីអាយុរបស់នាងទេ ប្រសិនបើឪពុកម្តាយយល់ព្រម។ នៅក្នុងបរិបទសង្គម និងវប្បធម៌របស់កម្ពុជាដែលគេមិនចង់ឃើញទារកកើតមកក្រៅចំណងអាពាហ៍ពិពាហ៍។ ហេតុនេះ វាហាក់ដូចជាគេបង្ខំនារីអាយុវ័យក្មេងដែលមានផ្ទៃពោះរួចហើយ ទទួលព្រមរៀបការឱ្យខាងតែបាន ។

## នីតិវិធីនៃការលះលែង

ផ្នែកទី ៣ នៃច្បាប់នេះបានចែងពីនីតិវិធីនៃការលះលែង ដូចមានខាងក្រោមៈ

១-បណ្តឹងលះលែងត្រូវតែសរសេរជាលាយល័ក្ខអក្សរដោយបញ្ជាក់ពីមូលហេតុនៃការលះលែង[១៣] ។

២-ប្រសិនបើពាក្យបណ្តឹងចូលមកមន្ត្រីមូលដ្ឋានខេត្ត-ក្រុង មន្ត្រីទាំងនោះត្រូវព្យាយាមផ្សះផ្សាភាគីទាំងពីរឱ្យឈប់ប្តឹង។ ប្រសិនបើមិនអាចធ្វើទៅបានមន្ត្រីមូលដ្ឋានត្រូវបញ្ជូនពាក្យបណ្តឹងនោះឡើងទៅតុលាការ។[១៤]

៣-តុលាការកោះហៅដើមបណ្តឹងឱ្យចូលខ្លួននៅតុលាការ "ប្រសិនបើត្រូវធ្វើ" ហើយតុលាការនឹងបញ្ចុះបញ្ចូលដើមបណ្តឹងឱ្យឈប់ប្តឹងតទៅទៀត[១៥] ។

៤-ប្តី និងប្រពន្ធត្រូវបានកោះឱ្យចូលមកតុលាការ ដើម្បីធ្វើការផ្សះផ្សា (ដោយមិនអនុញ្ញាតឱ្យមានមេធាវីចូលរួមទេ)[១៦] ។

៥-ប្រសិនបើ គ្មានការព្រមព្រៀងនៅក្នុងការផ្សះផ្សាលើកទី ១ទេ តុលាការនឹងកោះហៅ ដើម្បីធ្វើការផ្សះផ្សាជាលើកទី ២ (មួយខែក្រោយ-មិនឱ្យលើសពីរយៈពេល ២ខែ)[១៧] ។

៦-ប្រសិនបើ ការផ្សះផ្សាលើកទី ២ ពុំមានការព្រមព្រៀងទៀតនោះតុលាការនឹងកោះហៅជាលើកទី៣ ដើម្បីបើកសវនាការ[១៨] ។

៧-ប្រសិនបើ ចុងចោទបដិសេធមិនទទួលស្គាល់មូលហេតុនៃការលះលែងទេ នោះនឹងត្រូវចាត់ការស៊ើបអង្កេត ហើយមានការអញ្ជើញសាក្សី ដើម្បីផ្តល់ភស្តុតាង[១៩] ។

---

[១៣] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ មាត្រា ៤២ ។

[១៤] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ មាត្រា ៤២ ។

[១៥] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ មាត្រា ៤៣ ។

[១៦] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ ១៩៨៩ មាត្រា ៤៥ ។

[១៧] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ ១៩៨៩ មាត្រា ៤៦ និង ៥១។

[១៨] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ ១៩៨៩ មាត្រា ៥៣ ។

[១៩] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ ១៩៨៩ មាត្រា ៥៦ និង ៥៧ ។

៨-អាចអនុញ្ញាតឱ្យលះលែងគ្នាបាន ប្រសិនបើ ភាគីទាំងពីរយល់ព្រម ឬតុលាការរកឃើញថាមូលហេតុនៃការលះលែងនោះមានសុពលភាពត្រឹមត្រូវ[២០] ។

**"មេឃុំជាបុរសម្នាក់។ គាត់មិនដែលជឿសោះថាប្តីខ្ញុំវាយខ្ញុំទេ។ គាត់បាននិយាយថាប្តីរបស់ខ្ញុំជាមនុស្សស្លូតបូត កុំឈ្លោះប្រកែកជាមួយគាត់"**

*សំដីរបស់ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារអាយុ៣៨ ឆ្នាំនៅខេត្តកំពត ។*

ដោយច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារនេះមាននីតិវិធីពិស្តារស្តីពីដំណើរការលះលែងបែបនេះទើបវាភាពស្មុគ្រស្មាញ ដើម្បីអាចឱ្យគូរភាគីទទួលយកសំរាប់ការអនុវត្ត ដើម្បីធានាឱ្យបុរស និងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការលះលែង ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារនេះគួរតែបញ្ញត្តឱ្យប្តី និងប្រពន្ធទាំងឡាយអនុវត្តន៍តាមនីតិវិធីលះលែងមួយ ដោយមិនមានភាពលំអៀង ដោយឡែកនៅពេលដែលយើងពិនិត្យពិចារណាក្នុងបរិបទវប្បធម៌កម្ពុជា គឺភាគច្រើនទំនងជាស្ត្រីដែលជាអ្នកដាក់ពាក្យបណ្តឹងលះលែង (ជាពិសេសស្តីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ) ហើយច្បាប់នេះបានបង្កឱ្យមានការលំបាកចំពោះស្ត្រីរងគ្រោះ ហើយត្រូវទទួលបាននូវភាពអវិជ្ជមានពីដំណើរការផ្សះផ្សានៃច្បាប់ដ៏វែងអន្លាយនេះទៅវិញ ។

នៅក្នុងនីតិវិធីទី ៣ ដែលបានគូសបញ្ជាក់ខាងលើ ក្នុងពេលដាក់ពាក្យបណ្តឹងលះលែង តុលាការនឹងត្រូវ *បញ្ចុះបញ្ចូល* " ដើមបណ្តឹងឱ្យឈប់បន្តការប្តឹងរបស់ខ្លួនតទៅទៀត។ ប្រាកដណាស់នៅកម្ពុជា ការធ្វើបែបនេះមានន័យថាមុននឹងធ្វើការពិចារណាអំពីមូលហេតុនៃការលះលែងគ្នា មន្ត្រីតុលាការ (ដែលភាគច្រើនជាបុរស) មានចេតនាបញ្ចុះបញ្ចូលឱ្យដើមបណ្តឹង (ដែលភាគច្រើនជាស្ត្រីងាយរងគ្រោះដែលត្រូវប្តីរំលោភបំពាន និងបោះបង់ចោល) កុំឱ្យលែងប្តីរបស់នាង។ ប្រសិនបើយើងពិនិត្យមើលភាពទន់ខ្សោយរបស់ស្ត្រីនៅកម្ពុជា ការគាបសង្កត់ឱ្យស្ត្រីមិនឯកភាពជាមួយយោបល់នៃមន្ត្រីតុលាការដែលសុទ្ធតែជាបុរសនោះ គឺជាបញ្ហាមួយគួរឱ្យយកចិត្តទុកដាក់ជាពិសេសនៅដំណាក់កាលដំបូងនៃការដាក់ពាក្យបណ្តឹង។ ដូច្នេះ នីតិវិធីលះលែងគ្នាដែលបានបង្ហាញឱ្យឃើញនូវវប្បធម៌លំអៀងក្នុងការផ្សះផ្សា បញ្ហាលះលែងនេះត្រូវបានសរសេរនៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារព្រមទាំងបានរារាំងដោយប្រសិទ្ធិភាពមិនឱ្យស្ត្រីទទួលបាននូវភាពស្មើគ្នានៅក្នុងនីតិវិធីលះលែងថែមទៀតផង។

វប្បធម៌លំអៀងប្រឆាំងលើស្ត្រីបានបន្តដាក់បញ្ចូលទៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារដោយបានតម្រូវឱ្យគូរភាគីត្រូវចូលរួមផ្សះផ្សាយ៉ាងតិចឱ្យបានពីរដងសិន មុននឹងអាចលះលែងគ្នាបាន។ ខណៈពេលនៃការចូលខ្លួនផ្សះផ្សា មើលទៅហាក់ដូចជាមិនមានគំនាបមកលើស្ត្រីភាគច្រើនក៏ដោយ ប៉ុន្តែ ស្ត្រីអាចជួបការលំបាកច្រើន ជាពិសេសស្ត្រីដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ដែលស្ត្រីទាំងនោះអាចត្រូវនៅតែប្រឈមមុខជា

[២០] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ ១៩៨៩ មាត្រា ៥៨ និង ៥៩ ។

មួយបុរសជាប្ដីដែលធ្លាប់បានធ្វើបាបរូបនាងកន្លងមក ហើយបុរសនោះអាចបន្តធ្វើបាប វាយដំលើរាងកាយ បំពានខាងផ្លូវភេទ ខាងផ្លូវចិត្ត និងផ្នែកសេដ្ឋកិច្ចជាដើមក្នុងដំណាក់កាលផ្សះផ្សានេះ។ ភាពតក់ស្លុតដោយការប្រឈមមុខជាមួយមនុស្សបែបនេះអាចកើតឡើងចំពោះស្ត្រី។ តាមរយៈភស្តុតាងដែលគួរឱ្យចាប់អារម្មណ៍បានបង្ហាញឱ្យឃើញដែរថា ការផ្សះផ្សាទាំងពីរលើកដែលតម្រូវដោយច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារក៏ដោយ ប៉ុន្តែធាតុពិតជាញឹកញាប់តុលាការបានចេញបញ្ហា ហើយមេឃុំជាអ្នករៀបចំព័តិមានសំរាប់ការផ្សះផ្សាទាំងនោះ។ ស្រដៀងគ្នានេះ ការគាបសង្កត់ឱ្យមានការផ្សះផ្សាគ្នាក៏មានសារៈសំខាន់ដែរ ហើយក៏មិនបាច់សង្ស័យពីកំណើននៃសម្ពាធកើតមានលើស្ត្រីរងគ្រោះនៅគ្រប់ដំណាក់កាលនៃការផ្សះផ្សាទាំងអស់នោះឡើយ។ សង្គមកម្ពុជាបានឱ្យតម្លៃយ៉ាងខ្លាំងទៅលើចំណងអាពាហ៍ពិពាហ៍ ហើយស្ត្រីណាដែលនៅលីវត្រូវគេចាត់ទុកថាជាអ្នកនាំមកនូវភាពអាម៉ាស់ធំបំផុតឱ្យគ្រួសារ។ តាមរយៈការធ្វើឱ្យដំណើរវិធីនៃការលះលែងគ្នាអូសបន្លាយពេលវេលាបានក្លាយជាគុណវិបត្តិដល់ស្ត្រីកម្ពុជា ដែលចង់លះលែងប្រកបដោយប្រសិទ្ធិភាពស្ទើរតែមិនអាចកើតឡើងបានឡើយ។

## ការរៀបអាពាហ៍ពិពាហ៍ជាថ្មី

ក្នុងមាត្រា ៩ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារបានចែងថា នារីម្នាក់អាចរៀបអាពាហ៍ពិពាហ៍ថ្មីមួយទៀតបាន ដោយមូលហេតុប្ដីស្លាប់ មោឃភាពអាពាហ៍ពិពាហ៍ ឬលែងលះគ្នា ប៉ុន្តែត្រូវស្ថិតនៅក្នុងវិធវភាព "ភាពមេម៉ាយ" ចំនួន៣00ថ្ងៃ គិតពីថ្ងៃដែលមោឃភាពអាពាហ៍ពិពាហ៍។ ការកំណត់បែបនេះ បានដាក់បន្ទុកយ៉ាងជាក់ស្ដែងទៅលើនារី ដោយមានការរើសអើង និងផ្ទុយទៅនឹងអនុសញ្ញា CEDAW ទាំងស្រុង។

## សេចក្ដីសន្និដ្ឋាន

ថ្វីបើច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារមានមាត្រាចែងដទៃទៀតដែលលើកកំពស់ឱ្យមានសមភាពរវាងបុរស និងនារីក៏ដោយ តែនៅមានលក្ខណៈខ្វះខាតត្រង់ចំណុចកំណត់និយមន័យស្ដីពីអាយុអប្បបរមានៃការរៀបអាពាហ៍ពិពាហ៍ និងកង្វះក្នុងការធានាថាបុរស និងនារីមានសមភាពក្នុងការលះលែង (បញ្ហាពីរដែលជាមូលដ្ឋានគ្រឹះនៃអនុសញ្ញា CEDAW)។ សេចក្ដីបន្ថែមទៅលើបរិបទនៃកំណែទំរង់ច្បាប់កម្ពុជាតាំងពីចុងបញ្ចប់នៃសង្គ្រាមស៊ីវិលក្នុងទសវត្សរ៍ទី៩0 ដែលច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ មិនទាន់ធ្វើបច្ចុប្បន្នភាពនៅឡើយ ហើយច្បាប់នេះចាំបាច់ត្រូវធ្វើកំណែទំរង់។

□□□

# ៤. អំពើរំលោភសេពសន្ថវៈ

## អនុសញ្ញា CEDAW

*"រដ្ឋទាំងឡាយនិងយកវិធានការសមស្រប ដើម្បីកែប្រែឥរិយាបថរបស់បុរស និងនារីខាងវិស័យសង្គម និងវប្បធម៌ក្នុងទស្សនៈ បំបាត់ចោលនូវការប្រកែប្រកាន់ និងការអនុវត្តន៍តាមទំលាប់ព្រមទាំងការអនុវត្តន៍ផ្សេងៗទៀតដែលឈរលើមូលដ្ឋាននៃការគិតអំពីភាពអន់ថយ ឬឧត្តមភាពរបស់ភេទណាមួយ ឬគិតអំពីតួនាទីជាទម្លាប់របស់បុរស និងនារី[២១] ។"*

*"រដ្ឋភាគីនានាត្រូវវិធានាឱ្យច្បាប់ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ និងអំពើរំលោភសេពសន្ថវៈ បៀតបៀនផ្លូវភេទ និងអំពើហិង្សាដែលកើតឡើងដោយយេនឌ័រមួយចំនួនទៀតបានផ្តល់នូវកិច្ចការពារសមរម្យដល់ស្ត្រីព្រមទាំងគោរពនូវបូរណភាព និងសេចក្តីថ្លៃថ្នូររបស់ពួកគេ[២២]"* ។

### ករណីសិក្សាទី៣: អំពើរំលោភសេពសន្ថវៈជាពួក –រឿងរបស់រតនា

*នាងខ្ញុំឈ្មោះ រតនា អាយុ ១៩ ឆ្នាំ ។ ថ្ងៃមួយជាថ្ងៃទីបី នៃបុណ្យចូលឆ្នាំខ្មែរ មិត្តភ័ក្តខ្ញុំ និងខ្ញុំបាននាំគ្នាជិះកង់ទៅលេងវត្ត ។ ពួកខ្ញុំមានកង់បួន ហើយមានគ្នាប្រាំបីនាក់ ដូច្នេះកង់មួយត្រូវជិះគ្នាពីរនាក់ ឬបីនាក់ខ្លះ ។ ភ័ក្ត និងខ្ញុំជិះកង់ជាមួយមនុស្សប្រុសម្នាក់ដែលត្រូវជាមិត្តភ័ក្រអ្នកជិតខាងម្នាក់ឈ្មោះ ធា ។ ខ្ញុំមិនដែលស្គាល់មនុស្សឈ្មោះ ធាទេ ប៉ុន្តែមិត្តភ័ក្តខ្ញុំប្រាប់ខ្ញុំថា ម្នាក់នេះជាអ្នកជិតខាងរបស់គាត់ ហើយគាត់ជាមនុស្សល្អមិនមានបញ្ហាអ្វីទេ ។*

*ដូច្នេះក្រោយពីចាប់គូរជិះកង់រួច ពួកយើងចាប់ផ្តើមជិះកង់ទៅវត្ត ប៉ុន្តែក្រោយពីជិះបានបន្តិចមកខ្ញុំកត់សម្គាល់ឃើញថា ធា បានព្យាយាមធាក់កង់យឺតៗ ហើយនៅក្រោយគេយ៉ាងឆ្ងាយ ។ ក្រោយមកទៀតភ័ក្ត និងខ្ញុំក៏មើលមិត្តភ័ក្តនៅខាងមុខលែងឃើញ ។ ខ្ញុំបានប្រាប់ធា ឱ្យប្រឹងធាក់កង់លឿនឡើង ដើម្បីឱ្យទាន់ពួកអ្នកមុខ ។ ពេលនោះ ធា បាននិយាយថា ខ្ញុំគិតថាមានគេវាយពួកអ្នកមុខហើយ ដូច្នេះយើងមិនបាច់ទៅទេត្រូវត្រឡប់ក្រោយវិញ ។ ភ័ក្ត និងខ្ញុំបានប្រាប់គាត់ថា គាត់ឆ្កួតហើយ គ្មានអ្នកណាវាយពួកអ្នកជិះកង់ទៅមុនទេ ធាឯងកំពុងនិយាយរឿងអ្វីហ្នឹង ។ គាត់មិនឆ្លើយទេ ប៉ុន្តែគាត់បានបត់កង់ជិះត្រឡប់ក្រោយ ហើយជិះទៅវិញតាមផ្លូវដដែល ។*

---

[២១] មាត្រា ៥ នៃអនុសញ្ញា CEDAW ។

[២២] អនុសាសន៍ទូទៅ យោបល់ ១៩ ចំណុចអំពីមាត្រាមួយចំនួននៅក្នុងអនុសញ្ញា CEDAW ។ ( កថាខណ្ឌ ២៤ ( ខ ) ) ។

ពេលមកដល់កន្លែងមួយដាច់ពីគេមិនសូវមានមនុស្ស គាត់បានឈប់កង់ ហើយប្រាប់ភ័ក្ត និងខ្ញុំឱ្យចុះពីលើកង់។ ពេលនោះយើងទាំងពីរភ័យយ៉ាងខ្លាំង ភ័ក្តបានលោតពីលើកង់ហើយរត់តាមផ្លូវយ៉ាងលឿន។ ខ្ញុំបានប្រឹងរត់តាមវាដែរ ប៉ុន្តែស្រាប់តែមានមនុស្សប្រុសពីរនាក់ទៀតចេញពីគម្ពោតព្រៃមកចាប់ដៃខ្ញុំកាច់ពត់ទៅក្រោយខ្នងយ៉ាងជាប់។ ខ្ញុំបានស្រែកយ៉ាងខ្លាំង ហើយប្រឹងរត់គេច តែពួកវានាំគ្នាសើចចំអកឱ្យខ្ញុំ។ ធា បានប្រាប់ខ្ញុំថាមនុស្សប្រុសទាំងពីរនាក់នេះជាមិត្តភ័ក្តរបស់គាត់ ហើយខ្ញុំគួរតែធ្វើឱ្យបានសមរម្យជាមួយពួកគេ។

ពួកគេទាំង បីនាក់បានរំលោភខ្ញុំម្តងម្នាក់ៗ។

ក្រោយពីរំលោភហើយ មនុស្សប្រុសម្នាក់បាននិយាយថា សម្លាប់ខ្ញុំចោលទៅ ប៉ុន្តែ ធាបានប្រាប់ពួកគេថាមិនបាច់សម្លាប់ទេ ឱ្យខ្ញុំទៅផ្ទះវិញទៅ។ ប៉ុន្តែពួកគេបានគំរាមខ្ញុំថា បើខ្ញុំហ៊ាននិយាយរឿងនេះប្រាប់អ្នកណា គេនឹងសម្លាប់ខ្ញុំចោល។ ពួកគេក៏ជិះកង់ចេញបាត់ទៅ ។

ខ្ញុំមានអារម្មណ៍ធ្ងន់ធ្ងរ វិលមុខ ខ្ញុំសឹងតែមិនជឿនូវអ្វីដែលបានកើតឡើងចំពោះខ្ញុំ ហើយខ្ញុំក៏ដើរត្រឡប់មកផ្ទះវិញ។ ដើរបានបន្តិច ក៏ឮសម្លេងម៉ូតូមួយជិះកាត់។ ខ្ញុំភ័យយ៉ាងខ្លាំងពេលឮសំឡេងម៉ូតូ ដោយខ្ញុំគិតវាជាម៉ូតូរបស់ពួកមនុស្សប្រុសដែលទើបរំលោភខ្ញុំ បានវិលត្រឡប់មករករំលោភខ្ញុំម្តងទៀត។ ពេលមកដល់ម៉ូតូនោះក៏ឈប់ ហើយមនុស្សម្នាក់បានចុះមកមើលខ្ញុំ។ ខ្ញុំភ័យយ៉ាងខ្លាំងស្រាប់តែ ខ្ញុំឃើញមុខគាត់ច្បាស់ ហើយស្គាល់ថាជាពូរបស់ខ្ញុំ - ខ្ញុំអរឡើងវិញ។ ពេលនោះខ្ញុំមានការខ្មាសអៀននឹងខ្លាចជាខ្លាំងក្នុងការប្រាប់គាត់អំពីបញ្ហាដែលកើតឡើងចំពោះខ្ញុំ។ ពេលគាត់សួរខ្ញុំថា ទៅណាមកណាតែម្នាក់ឯងហ្នឹង? ខ្ញុំកុហក់គាត់ថាខ្ញុំមកពីវត្ត ហើយមិត្តភ័ក្តខ្ញុំដាក់ខ្ញុំត្រឹមនេះ។ គាត់ក៏បានឱ្យខ្ញុំឡើងជិះម៉ូតូទៅផ្ទះជាមួយ ពេលនោះម្តាយខ្ញុំកំពុងទន្ទឹងរង់ចាំផ្លូវខ្ញុំនៅខាងក្រៅផ្ទះ។

ភ័ក្ត ដែលបានរត់គេចរួចពីបុរសទាំងបីនាក់នោះ ក៏កំពុងរង់ចាំជាមួយម្តាយខ្ញុំដែរ។ នាងបានរត់ទៅផ្ទះខ្ញុំ ហើយប្រាប់ម្តាយខ្ញុំអំពីរឿងដែលបានកើតឡើងចំពោះខ្ញុំ។ ពេលមកដល់ផ្ទះវិញ ម្តាយខ្ញុំបានសួរថា មានរឿងអ្វីកើតឡើងឬទេ ពេលនោះខ្ញុំបានកុហក់ម្តាយខ្ញុំថា ឥតមានរឿងអ្វីទេ។ខ្ញុំមានអារម្មណ៍អាម៉ាស់ជាខ្លាំង ហើយខ្ញុំមិនដឹងថាត្រូវនិយាយប្រាប់គាត់យ៉ាងម្តេចទេ ហេតុនេះមានត្រូវតែកុហក់គាត់។ ពេលយប់ជ្រៅបន្តិចខ្ញុំបាននិយាយរឿងពិតប្រាប់ ភ័ក្ត ហើយម្តាយខ្ញុំបានស្តាប់ឮរឿងនេះ។ គាត់ខឹងយ៉ាងខ្លាំង ហើយខ្ញុំគិតថាគាត់ប្រហែលជាខឹងខ្ញុំដែរ ប៉ុន្តែគាត់បានយំ ហើយប្រាប់ខ្ញុំថា យើងត្រូវតែរាយការណ៍ប្រាប់នគរបាល ហើយគាត់ក៏បាននាំខ្ញុំទៅជួបនគរបាលទាំងយប់ប្រហែលជាម៉ោង ៣ជិតភ្លឺ ខណៈនគរបាលកំពុងលង់លក់ក្នុងដំណេក។ ពួកគេមិនជួយខ្ញុំទេ ហើយបានប្រាប់ខ្ញុំថាចាំស្អែក សូមមកម្តងទៀត។ ព្រឹកឡើង ខ្ញុំក៏បានទៅប៉ុស្តិ៍នគរបាលម្តងទៀត ហើយរាយការណ៍ប្រាប់អំពីរឿងរ៉ាវដែលបានកើតឡើងចំពោះខ្ញុំ។ ពួកគេបានជួយសរសេរពាក្យបណ្តឹងឱ្យខ្ញុំ ប៉ុន្តែមកដល់ពេលនេះពុំទាន់ឃើញបានលទ្ធផលអ្វីនៅឡើយទេ។

ឥឡូវនេះខ្ញុំនៅតែមានសុបិន្តអាក្រក់អំពីរឿងរ៉ាវដែលបានកើតឡើងកាលពីយប់នោះ ហើយខ្ញុំតែង តែភ័យខ្លាចនៅពេលដែលខ្ញុំនៅតែម្នាក់ឯង ហើយខ្ញុំចេះតែបារម្ភថា គ្មានបុរសត្រឹមត្រូវណាស្ម័គ្ររៀបការជា មួយខ្ញុំទេ ពីព្រោះខ្ញុំអស់ព្រហ្មចារិនីហើយ ។ ខ្ញុំមានអារម្មណ៍ព្រួយ ហើយយំយ៉ាងខ្លាំង ខ្ញុំមិនដឹងថាត្រូវធ្វើយ៉ាង ម៉េចទៀតទេក្នុងមួយជីវិតនេះ ។

## ករណីសិក្សាទី៩: អំពើរំលោភសេពសន្ថវៈ-រឿងរបស់ស៊ីថា

ខ្ញុំឈ្មោះ ស៊ីថា អាយុ ២៨ ឆ្នាំ ។ កាលពីខ្ញុំអាយុ ១៥ ឆ្នាំ មានទាហានខ្មែរក្រហមម្នាក់ដែលរស់នៅ ក្នុងភូមិខ្ញុំបានចាប់ខ្ញុំរំលោភសេពសន្ថវៈ ។ ពេលនោះខ្ញុំមានអារម្មណ៍ថា អ្វីៗទាំងអស់នៅក្នុងជីវិតរបស់ខ្ញុំត្រូវ ចប់អស់ហើយ ។ ក្រោយពីត្រូវគេរំលោភរួច ខ្ញុំបានទៅជួបម្តាយខ្ញុំ ហើយនិយាយប្រាប់គាត់អំពីរឿងរ៉ាវដែល បានកើតឡើងចំពោះខ្លួនខ្ញុំ ។ ដាដំបូងគាត់មិនជឿខ្ញុំទេ ហើយក្រោយមកគាត់បាននិយាយរឿងនេះប្រាប់ឪពុក ខ្ញុំ ។ ក្រោយពីប្រាប់ហើយ ឪពុកខ្ញុំបានទៅរាយការណ៍ប្រាប់មេភូមិ ហើយសុំឱ្យមេភូមិជួយគាត់ ។ បន្តិចមកមេ ភូមិក៏បានមកជួបជាមួយឪពុកម្តាយខ្ញុំ ព្រមទាំងនាំបុរសដែលបានរំលោភខ្ញុំមកជាមួយផង ។ ក្រោយពេលជួប ហើយ ទាំងអស់គ្នាបានសម្រេចថា បុរសនេះត្រូវតែរៀបការជាមួយខ្ញុំ ព្រោះគាត់បានរំលោភខ្ញុំហើយ ដើម្បីកុំ ឱ្យរឿងនេះវែងឆ្ងាយតទៅមុខទៀត ។

ពេលនោះ គ្មានអ្នកណាម្នាក់សួរខ្ញុំថា តើខ្ញុំចង់បានអ្វីទេ ។

ឪពុកម្តាយរបស់ខ្ញុំ និងមេភូមិបានប្រាប់ខ្ញុំថា ប្រសិនបើខ្ញុំមិនព្រមរៀបការជាមួយបុរសនេះធ្វើជាប្តីទេ នោះគ្មានបុរសណាស្រឡាញ់ខ្ញុំទេ ហើយខ្ញុំនឹងពុំអាចមានលទ្ធភាពរៀបការ ឬមានគ្រួសារទេក្នុងមួយជីវិតនេះ ពីព្រោះបុរសនេះបានរំលោភសេពសន្ថវៈ ហើយបាត់បង់អស់នូវព្រហ្មចារិនីបែបនេះ ។ ដូច្នេះ ដោយខ្ញុំទើបតែ អាយុ១៥ឆ្នាំ ខ្ញុំនៅឆោតល្ងង់ងាយជឿគេហើយមានអារម្មណ៍សោកស្តាយយ៉ាងខ្លាំងចំពោះបញ្ហាទាំងអស់នេះ ។ ខ្ញុំមានភាពអាម៉ាស់យ៉ាងខ្លាំងដោយមនុស្សនៅក្នុងភូមិតែងតែនិយាយអំពីរឿងខ្ញុំពីម្នាក់ទៅម្នាក់ឥតឈប់ឈរ ។ ដោយខ្ញុំនៅក្មេង ខ្ញុំមិនហ៊ានជំទាស់ជាមួយឪពុកម្តាយខ្ញុំ និងមេភូមិទេ ហើយក៏មិនហ៊ាន តបតជាមួយនឹង បុរសដែលរំលោភខ្ញុំដែរ ។ ដូច្នេះ មានតែផ្លូវម្យ៉ាងទេ គឺព្រមរៀបការតាមការសម្រេចរបស់ចាស់ៗទាំងនោះ ។

ចាប់តាំងពីខ្ញុំបានរៀបការជាមួយបុរសនេះ រហូតមកដល់សព្វថ្ងៃ គឺមានរយៈពេល ១៥ ឆ្នាំ ហើយ ។ ហើយវាក៏ជារយៈពេល ១៥ ឆ្នាំនៃការឈឺចាប់ដ៏ខ្លោចផ្សាររបស់ខ្ញុំដែរ ដោយខ្ញុំពុំដែលមានសេចក្តីសុខ និង សុភមង្គលនៅក្នុងចិត្តទាល់តែសោះ ។ នៅក្នុងជីវិតអាពាហ៍ពិពាហ៍របស់ខ្ញុំ បុរសនេះបានធ្វើបាប ញាំញីខ្ញុំទាំង ផ្លូវកាយ និងផ្លូវចិត្តរៀងរាល់ថ្ងៃឥតល្ហែឡើយ ។ គ្រាមួយ នៅពេលដែលខ្ញុំកំពុងមានផ្ទៃពោះកូនទី ៣ គាត់

*បានវាយដំខ្ញុំរហូតដល់ខ្ញុំរបួសជាទម្ងន់ ហើយថែមទាំងបានវាយដំកូនៗទៀតផង គាត់ហាក់ដូចជាគ្មានសេចក្តីស្រឡាញ់ចំពោះកូនៗទាល់តែសោះ ។*

*ថ្ងៃមួយ បន្ទាប់ពីរងការឈឺចាប់អស់រយៈពេលជាច្រើនឆ្នាំមក ខ្ញុំបានសម្រេចថាខ្ញុំមិនអាចនៅរងការឈឺចាប់បែបនេះតទៅទៀតបានទេ ហើយខ្ញុំបានទៅជួបមេបញ្ជាការរបស់គាត់ ដោយបានរៀបរាប់ប្រាប់គាត់ថាប្តីខ្ញុំតែងតែវាយធ្វើបាបប្រពន្ធកូនជាប្រចាំ ខ្ញុំមិនអាចទ្រាំរស់នៅជាមួយគាត់បានទេ ខ្ញុំត្រូវតែលះលែងជាមួយគាត់ ។ ពេលនោះមេបញ្ជាការគាត់បានប្រាប់ខ្ញុំថា ឥឡូវនេះ កុំអាលលែងគ្នា សាកល្បងដោះស្រាយដោយផ្សះផ្សាគ្នាសិនទៅ ហើយគាត់ក៏បានហៅប្តីខ្ញុំ និងខ្ញុំមក ដើម្បីធ្វើកិច្ចសន្យាផ្សះផ្សាគ្នា ។ ពីរ-បីថ្ងៃក្រោយការផ្សះផ្សាគ្នារួច ប្តីខ្ញុំបានចាប់ផ្តើមវាយធ្វើបាបខ្ញុំជាថ្មីម្តងទៀត ដោយគ្មានផ្លាស់ប្តូរចរិតទាស់តែសោះ ។*

*នៅក្នុងជីវិតអាពាហ៍ពិពាហ៍របស់យើង ប្តីខ្ញុំតែងតែបង្ខំខ្ញុំឱ្យរួមភេទជាមួយគាត់ជានិច្ច ។ ពេលណាខ្ញុំមិនព្រម គាត់បានវាយដំ ចាប់បង្ខំ និងរំលោភខ្ញុំទាល់តែបាន ។ ខ្ញុំបានព្យាយាមរត់គេចពីគាត់ពីរ-បីដងប៉ុន្តែគាត់នៅតែតាមរកខ្ញុំឃើញ ហើយពេលរកឃើញម្តងៗគាត់តែងតែធ្វើទារុណ្ឌកម្មខ្ញុំ ហើយនាំខ្ញុំត្រឡប់មកផ្ទះវិញ ។*

*ដោយសារតែប្តីខ្ញុំរំលោភបំពានលើរូបរាងកាយខ្ញុំ និងកូនៗជាញឹកញាប់នោះ អាជ្ញាធរដែនដី និងអ្នកជិតខាងគេមិនសូវធ្វើដឹងឮអំពីបញ្ហាខ្ញុំទេ ។ ពីរ-បីខែកន្លងមក ខ្ញុំបានសម្រេចចិត្តថាខ្ញុំ ឈប់រស់នៅជាមួយគាត់តទៅទៀតហើយ ។ មានអ្នកជិតខាងម្នាក់បានជួយនាំខ្ញុំឱ្យមកជួបអង្គការមួយដែលជួយផ្តល់កន្លែងស្នាក់នៅដល់ខ្ញុំក្នុងមណ្ឌលមួយ ហើយអង្គការនោះក៏បានជួយធ្វើបណ្តឹងលះលែងឱ្យខ្ញុំផងដែរ ពេលនេះករណីរបស់ខ្ញុំកំពុងដំណើរការនៅតុលាការ ។ ខ្ញុំមានការធ្ងើយណាយជាមួយនិងបញ្ហានេះយ៉ាងខ្លាំង ប៉ុន្តែខ្ញុំខំប្រឹងធ្វើអ្វីៗទាំងអស់ដើម្បីកូនៗរបស់ខ្ញុំឱ្យពួកគេមានសុវត្ថិភាពក្នុងការរស់នៅ ។*

*នេះជារឿងរបស់ខ្ញុំ ។*

## អំពើរំលោភសេពសន្ថវៈនៅកម្ពុជា

ថ្វីត្បិតបើអំពើរំលោភសេពសន្ថវៈ មិនអាចត្រូវបានគេដឹងថាមានទំហំរីករាលដាលក៏រិតណាទេ ។ ករណីរំលោភសេពសន្ថវៈមានព័ត៌មានខ្លះបង្ហាញពីទំរង់នៃការរំលោភបំពានផ្លូវភេទកើតមានច្រើនណាស់ ។ បញ្ហានេះរួមមានការរំលោភដោយប្រើហិង្សា (រំលោភហើយសម្លាប់ចោល) រំលោភផ្លូវភេទជាពួក និងអំពើរំលោភកុមារីដែលទើបតែមានអាយុតែ២-៣ឆ្នាំប៉ុណ្ណោះ ។

**"សង្គមឱ្យតំលៃខ្ពស់ចំពោះបុរស"**

*សំដីរបស់នារីរងគ្រោះដោយអំពើរំលោភសេពសន្ថវៈ អាយុ១៨ ឆ្នាំ ហើយបង្ខំឱ្យរៀបការ រស់នៅខេត្តបាត់ដំបង។*

អំពើរំលោភសេពសន្ថវៈនៅកម្ពុជា ត្រូវបានគេប្រមើលមើលក្នុងបរិបទវប្បធម៌ និងឥរិយាបទសង្គមចំពោះនារី ទង្វើសេពមេថុន។ បុរសត្រូវបានគេចាត់ទុកថាជាវត្ថុមានតម្លៃជាងនារី ហើយនារីត្រូវបានគេចាត់ទុកថាជារបស់សំរាប់បំពេញអត្ថប្រយោជន៏ចំពោះពួកគេ។ ក្នុងបរិបទនេះមានបុរស ជាច្រើនមិនគោរពសិទ្ធិនារី ដើម្បីឱ្យនារីចាកផុតពីការរំលោភផ្លូវភេទ និងហិង្សានានាឡើយ ហើយក៏មានស្ត្រីជាច្រើនមិនមានទំនុកចិត្តក្រោកឈរប្រឈមសំរាប់ទាមទារសិទ្ធិរបស់គេដែរ។ ជាប្រពៃណី នារីទាំងឡាយសង្ឃឹមលើភាពបរិសុទ្ធដោយការថែរក្សាព្រហ្មចារិនីរហូតដល់ថ្ងៃរៀបអាពាហ៏ពិពាហ៏។ នារីដែលបាត់បង់ព្រហ្មចារី-នីមុនពេលរៀបការ ត្រូវបានគេចាត់ទុកជានារី "មិនអាចរៀបការបាន" ។ ភាពអាម៉ាស់ដោយអំពើរំលោភសេពសន្ថវៈ (អារម្មណ៏របស់ជនរងគ្រោះដោយការរំលោភសេពសន្ថវៈពីប្រទេសដទៃ) បានធ្វើឱ្យស្ថានមានភាពធ្ងន់ធ្ងរច្រើនលើសលុបពីឥរិយាបថសង្គមនៅកម្ពុជា។ ដូចជាករណីរបស់ស្ត្រីឈ្មោះ **រតនា** ភាពអាម៉ាស់នេះអាចនាំឱ្យជនរងគ្រោះមិនចង់និយាយប្រាប់អ្នកណាអំពីបញ្ហានេះ ដោយលាក់ទុកយ៉ាងស្ងៀមស្ងាត់ ឬបដិសេធមិនរាយការណ៏ទៅអាជ្ញាធរ ដើម្បីស្វែងរកការនាំជនល្មើសមកផ្តន្ទាទោសតាមច្បាប់។ ឥរិយាបថបែបនេះច្រើនតែជម្រុញ ឬលើកទឹកចិត្តដោយគ្រួសារជនរងគ្រោះ និងសមាជិកក្នុងសហគមន៏ ឬអាជ្ញាធរដែនដី ដូចជា: មេភូមិ មេឃុំ និងនគរបាលជាដើម។

ភាពធ្ងន់ធ្ងរនៃអំពើរំលោភសេពសន្ថវៈដែលជាបទឧក្រិដ្ឋជាញឹកញាប់ត្រូវបានគេបំភ្លេចចោល ឬចាត់ថាជារឿងតូចតាច បញ្ហាទាំងនេះរួមបញ្ចូលពីជំនឿដែលថា បុរសមិនអាចទប់អារម្មណ៏នៃចំណង់តណ្ហាពួកគេ ហើយមិនប្រកាន់យកភាពទទួលខុសត្រូវដែលកើតចេញសកម្មភាពចំណង់តណ្ហានេះទេ ឬក៏ថាជនរងគ្រោះជាអ្នកបង្កឱ្យមានអំពើរំលោភផ្លូវភេទ ឬព្រមព្រៀងរួមរ័កដោយស្ម័គ្រចិត្ត ។ ថ្វីត្បិតបើ អំពើរំលោភសេពសន្ថវៈត្រូវបានទទួលស្គាល់ថាជាហិង្សាធ្ងន់ធ្ងរក្តី (ជាពិសេសជនរងគ្រោះដែលមានអាយុក្មេងពេក) តែដោយភាពអាម៉ាស់ ខ្មាសអៀនអាចធ្វើឱ្យនាង និងក្រុមគ្រួសាររកការដោះស្រាយដោយវិធីស្ងៀមស្ងាត់ប្រសើរជាងការស្វែងរកវិធីផ្តន្ទាទោសជនឧក្រិដ្ឋ ។ ជនល្មើសលើករណីរំលោភសេពសន្ថវៈជាច្រើននាក់ បានគេចផុតពីការផ្តន្ទាទោសតាមផ្លូវច្បាប់ដោយពួកគេគ្រាន់តែបង់សងជម្ងឺចិត្តខ្លះឱ្យទៅជនរងគ្រោះ និងក្រុមគ្រួសារនាង ដើម្បីបញ្ចប់ ការប្តឹងផ្តល់តាមផ្លូវច្បាប់។ ការសងជម្ងឺចិត្តក្រៅប្រព័ន្ធតុលាការជាធម្មតា ច្រើនតែអាជ្ញាធរដែនដីជាអ្នកជួយសម្របសម្រួល ហើយក៏ជាអ្នកទទួលបានកម្រៃមួយផ្នែកពីការដោះស្រាយបញ្ហានេះចំពោះពួកគេ ហើយនៅក្នុង ករណីខ្លះទៀតអាជ្ញាធរដែនដី ឬគ្រួសារជនរងគ្រោះអាចបង្ខំឱ្យជនរង គ្រោះរៀបអាពាហ៏ពិពាហ៏ជាមួយជនល្មើសដែលបានរំលោភនាង។ "ដំណោះស្រាយ" ទាំងពីរបែបនេះធ្វើឱ្យបាត់បង់សិទ្ធិទទួលបាននូវយុត្តិធម៌ និងសិទ្ធិសងជម្ងឺចិត្តស្របច្បាប់ ព្រមទាំងដកយកសិទ្ធិសេចក្តីថ្លៃថ្នូរពីជនរងគ្រោះចេញទាំងអស់។ ដំណោះស្រាយបែបនេះក៏បានពង្រីកវិសាលភាពនៃសេចក្តីភ័យ

ខ្លាច និងកេរ្តិ៍ឈ្មោះជនរងគ្រោះ (និងគ្រួសារ) ក្នុងស្ថានភាព ប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ និងសិទ្ធិខាងផ្លូវច្បាប់ចំពោះករណីរំលោភសេពសន្ថវៈលើរូបនាង។

ប្រសិនបើ ជនរងគ្រោះមានជំហរពិតប្រាកដដាក់ពាក្យបណ្តឹងទៅតុលាការ ជនល្មើសអាចនៅតែគេចផុតពីការផ្តន្ទាទោស ដោយយោងលើស្ថានភាពពុករលួយរីករាលដាលនៅប៉ុស្តិ៍ប៉ូលីស និងតុលាការ ។ ភស្តុតាងដែលគួរឱ្យចាប់អារម្មណ៍បង្ហាញថា ជនល្មើសដែលជាជនក្រីក្រ (គ្មានលុយកាក់សូកប៉ាន់មន្ត្រីអនុវត្តច្បាប់) ត្រូវបានគេនាំមកផ្តន្ទាទោស ហើយទទួលទោសដោយជាប់ពន្ធនាគារយូរឆ្នាំទៀតផង ។ រីឯជនល្មើសដែលមានលុយកាក់ ឬមានខ្នងបង្អែកអ្នកមានអំណាចកម្រត្រូវបានផ្តន្ទាទោស ឬជាប់ពន្ធនាគារណាស់ ។ (អំពើពុករលួយដោយប៉ូលីស និងតុលាការត្រូវបានគេដឹងឮយ៉ាងទូលំទូលាយចំពោះជនកម្ពុជា អំពើពុករលួយនេះបានបំបែរគោលជំហរជនរង គ្រោះ និងក្រុមគ្រួសារឱ្យបោះបង់បណ្តឹងតាមផ្លូវច្បាប់ ហើយងាកមកទទួលយកសំណងក្រៅប្រព័ន្ធតុលាការវិញ ។ ការបង់សំណងជម្ងឺចិត្តភ្លាមៗ បែបនេះសំរាប់ជនល្មើស គឺជាភាពងាយស្រួលទទួលយកជាងការទទួលយកការផ្តន្ទាទោសទៅតុលាការ) ។

**អំពើរំលោភសេពសន្ថវៈនៅកម្ពុជាត្រូវបានគ្រប់គ្រងដោយ:**

- ច្បាប់អ៊ុនតាក់។
- ច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ។
- ច្បាប់ស្តីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

## និយមន័យនៃពាក្យរំលោភសេពសន្ថវៈ

និយមន័យនៃករណីរំលោភសេពសន្ថវៈគឺ "គ្រប់អំពើបញ្ចូលអង្គជាតិបែបឃោរឃៅ ដោយបង្ខំ ដោយមិនដឹងខ្លួនជាមុន" ។[២៣] ការប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ ឬ *ប៉ុនប៉ងរំលោភសេពសន្ថវៈ* ត្រូវចាត់ទុកថាជាបទល្មើសដូចគ្នានៅក្នុងច្បាប់កម្ពុជា។[២៤]

## កង្វះនិយមន័យនៃពាក្យព្រមព្រៀង

បច្ចុប្បន្ននេះពុំមាននិយមន័យអំពីធាតុផ្សំនៃពាក្យព្រមព្រៀងនៅក្នុងច្បាប់កម្ពុជា ដែលចែងពីអំពើរំលោភសេពសន្ថវៈឡើយ ។ បើពិចារណាត្រួសៗគេអាចនិយាយថា អំពើរំលោភសេពសន្ថវៈមានន័យថាជាការរួមរក័ដោយពុំមានការព្រមព្រៀង ដូច្នេះ នេះជាធាតុផ្សំមានសារៈសំខាន់ដែលត្រូវតែឱ្យនិយមន័យ។ ប៉ុន្តែច្បាប់កម្ពុជា បានបង្កើតធាតុផ្សំមួយចំនួនដូចជា " សាហាវឃោរឃៅ ដោយបង្ខំ ដោយមិនដឹងខ្លួនជាមុន" ការកំណត់ធាតុផ្សំបទ

---

[២៣] ច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល មាត្រា ៣៣ និងច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទល្មើសឧក្រិដ្ឋ មាត្រា ៥ ។

[២៤] ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទល្មើសឧក្រិដ្ឋ មាត្រា ៥ ។

ល្មើសរំលោភសេពសន្ថវៈ មិនមានវត្តមានធាតុផ្សំនូវពាក្យយល់ព្រមទេ។ នៅក្នុងករណីជាច្រើនលិខិតវិញ្ញាប័ត្រពេទ្យដែលកត់ត្រានូវអំពើហិង្សា ដែលមានរបួសស្នាមលើជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈត្រូវបានប្រើប្រាស់ ដើម្បីផ្តន្ទាទោសជនល្មើស។ ប៉ុន្តែ ប្រសិនបើគ្មានភស្តុតាងហិង្សាលើរាងកាយ និងលិខិតវិញ្ញាណប័ត្រពេទ្យបញ្ជាក់ការពិតទេនោះ ចៅក្រមនឹងប្រកាសថាការរួមភេទនេះប្រព្រឹត្តទៅដោយមានការព្រមព្រៀងគ្នា ដូច្នេះ ពុំមែនជាករណីរំលោភសេពសន្ថវៈទេ។

> **"ច្បាប់ទាំងឡាយមិនគួរលំអៀងគាំទ្របុរសៗនោះទេ សូមឱ្យច្បាប់ជួយគាំទ្រដល់ស្ត្រីៗផង។"**
>
> *សំដីរបស់ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ អាយុ៤៣ រស់នៅខេត្តបាត់ដំបង។*

ក្នុងបរិបទនៃអំពើពុករលួយក្នុងប្រទេសកម្ពុជាបានបំបាត់ចោលនូវប្រព័ន្ធយុត្តាធិការ ព្រះរាជអាជ្ញា និងចៅក្រមតុលាការដែលគ្មានភាពស្មោះត្រង់អាចប្រើឱកាសនេះសំរាប់អត្ថប្រយោជន៍របស់ខ្លួន ចេញពីកង្វះខាតនៃចន្លោះប្រហោងការកំណត់និយមន័យស្តីពីអំពើរំលោភសេពសន្ថវៈ ដើម្បីកំណត់ការសំរេចមិនផ្តន្ទាទោស ឬបញ្ឈប់បណ្តឹងចំពោះជនល្មើសណាដែលបានសូកប៉ាន់ពួកគេ ។

កង្វះនិយមន័យ ឬសេចក្តីណែនាំច្បាប់ទាក់ទងនឹងការយល់ព្រម ហើយបូករួមជាមួយវប្បធម៌លំអៀង ចំពោះអំពើរំលោភសេពសន្ថវៈដែលមានរួចមកហើយនោះ ស្តែងបញ្ជាក់ឱ្យឃើញថា ស្ត្រីត្រូវទទួលការរើសអើងនៅពេលផ្តល់សេចក្តីរាយការណ៍ពីករណីរំលោភដែលបានកើតឡើងចំពោះខ្លួន។

## អំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍

អំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ត្រូវបានកំណត់ឱ្យនិយមន័យនៅក្នុង *ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ* ហើយត្រូវបានពិភាក្សាបន្ថែមនៅជំពូកទី២ នៃច្បាប់នេះ ។ អំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍មិនមានចែងក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាលអ៊ុនតាក់ទេ ហើយនិយមន័យស្តីអំពីអំពើរំលោភសេពសន្ថវៈ ក៏មិនបានចែងឱ្យច្បាស់លាស់ឡើយ ដែលជាមូលហេតុធ្វើឱ្យមានភាពរើសអើងចំពោះនារីរងគ្រោះដែលត្រូវបានរំលោភបំពានពីសំណាក់ប្តី ឬសង្សាររបស់គេទៀតផង។

## វិធានការស្តារនីតិសម្បទា

នៅក្នុងច្បាប់ពាក់ព័ន្ធជាមួយបទល្មើសរំលោភសេពសន្ថវៈ ពុំមានមាត្រាណាមួយចែងទាក់ទងជាមួយការស្តារនីតិសម្បទាឡើយ។ អនុសាសន៍ទូទៅ ១៩ ចំណុចរបស់អនុសញ្ញា CEDAW បាននិយាយថារដ្ឋនានាគួរ

អនុវត្ត "វិធានការការពារដូចជា ៖ ជម្រើស ផ្តល់ការប្រឹក្សាយោបល់ ស្ថានីតិសម្បទា និងសេវាកម្មឧបត្ថម្ភផ្សេងៗ ទៀតដល់ស្ត្រីដែលជាជនរងគ្រោះដោយអំពើហិង្សា ឬស្ត្រីដែលប្រឈមមុខនឹងគ្រោះភ័យដោយអំពើហិង្សា" ។[២៥]

□□□

[២៥] អនុសាសន៍ទូទៅ ១៩ ចំណុចអំពីមាត្រាមួយចំនួននៅក្នុងនៃអនុសញ្ញា CEDAW ( កថាខណ្ឌ ២៤ ( ន ) ។

# ៥. អំពើជួញដូរមនុស្ស

**អនុសញ្ញា CEDAW**

*"រដ្ឋភាគីនានាត្រូវចាត់រាល់វិធានការសមស្របរួមមានច្បាប់ បង្ក្រាបរាល់ទម្រង់នៃអំពើជួញដូរស្ត្រី និង អំពើអាជីវកម្មពេស្យាចារស្ត្រី" ។*[២៦]

*"វិធានការទប់ស្កាត់ និងទណ្ឌកម្ម គឺជាវិធានការចាំបាច់ ដើម្បីជំនះអំពើជួញដូរ និងអាជីវកម្មផ្លូវភេទ ក្នុងរបាយការណ៍របស់ខ្លួន រដ្ឋជាភាគីគួររៀបរាប់អំពីទំហំបញ្ហាទាំងនេះ និងវិធានការ ដូចជាមាត្រាដែលចែងអំពីការផ្តន្ទាទោស វិធានការទប់ស្កាត់ និងស្តារនីតិសម្បទារដែលបានចាត់ឡើង ដើម្បីការពារស្ត្រីកុំឱ្យធ្លាក់ចូលទៅក្នុងពេស្យាចារ ឬត្រូវរងការជួញដូរ និងទម្រង់អាជីវកម្មផ្លូវភេទផ្សេងៗទៀត ។ ប្រសិទ្ធិភាព នៃវិធានការទាំងនេះ ក៏ត្រូវរៀបរាប់ផងដែរ ។*

*នីតិវិធីបណ្តឹង នឹងជួសជុលការខូចខាត ដែលមានប្រសិទ្ធិភាព ដូចជាសំណងជម្ងឺចិត្តគួរត្រូវបានផ្តល់ផងដែរ ។*[២៧]*"*

## ករណីសិក្សាទី៥: រឿងរបស់សុភា

*ខ្ញុំឈ្មោះ សុភា អាយុ ១៩ ឆ្នាំ ហើយខ្ញុំត្រូវគេបោកយកទៅលក់ឱ្យបម្រើផ្លូវភេទ ។ ខាងក្រោមនេះគឺជារឿងរ៉ាវរបស់ខ្ញុំ ។*

*ថ្ងៃមួយនៅចុងឆ្នាំ ២០០៣ ម្តាយមីងខ្ញុំបានមកលេងគ្រួសារខ្ញុំ ។ មីងខ្ញុំគាត់មានទ្រព្យសម្បត្តិច្រើនជាងគ្រួសារខ្ញុំ ហើយតែងតែមកលេងផ្ទះខ្ញុំជាញឹកញាប់ ព្រមទាំងផ្តល់លុយកាក់ខ្លះព្រោះពួកយើងជាជនក្រីក្រ ។ គាត់មកលេងលើកនេះដោយពោលថា ខ្ញុំគួរតែទៅទីក្រុងដើម្បីរកការងារធ្វើ ។ មីងខ្ញុំបាននិយាយថា ខ្ញុំអាចរកប្រាក់បានច្រើន ហើយគាត់ធានាថានឹងជួយរកការងារឱ្យខ្ញុំធ្វើនៅហាងលក់ម្ហូបអាហារមួយ ។ ខ្ញុំមិនចង់ចាកចេញពីឪពុកម្តាយខ្ញុំទៅរស់នៅឯទីក្រុងទេ ព្រោះមានអារម្មណ៍ភ័យខ្លាច ។ ខ្ញុំធ្លាប់បានមកលេងទីក្រុងពីរ-បីដងដែរ តែមកជាមួយឪពុកម្តាយ ។ ប៉ុន្តែដោយសារជីវភាពក្រីក្រនៃគ្រួសាររបស់ខ្ញុំ ដែលត្រូវការលុយកាក់ផងនោះ ខ្ញុំបានគោរពតាមបំណងឪពុកម្តាយយល់ព្រមធ្វើដំណើរជាមួយម្តាយមីងមកទីក្រុង ។*

---

[២៦] មាត្រា ៦ នៃ អនុសញ្ញា CEDAW ។

[២៧] អនុសាសន៍ទូទៅ១៩ ចំណុចអំពីមាត្រាមួយចំនួននៅក្នុង នៃអនុសញ្ញា CEDAW( កថាខណ្ឌ ២៤ (ឆ) (i) ។

ពេលមកដល់ទីក្រុងភ្នំពេញ ស្រាប់តែគាត់យកខ្ញុំទៅធ្វើការនៅក្នុងហាងបា ការ៉ាអូខាមួយ ដែលគាត់បានប្រាប់ថាជាកន្លែងធ្វើការរបស់គាត់ ។ ខ្ញុំគិតថាការងារនោះវាគ្រាន់តែលើកស្រាបៀរបំរើភ្ញៀវ នឹងជូតបោសសំអាតតុតែប៉ុណ្ណោះ ។ គាត់បាននាំខ្ញុំទៅកាន់បន្ទប់ខាងក្រោយ ហើយគាត់បានបង្ខំខ្ញុំឱ្យរួមរ័កជាមួយភ្ញៀវថែមទៀតដោយគាត់បានសន្យាថាឱ្យប្រាក់ខែ ២០ដុល្លារក្នុងមួយខែ ។ ខ្ញុំមានសេចក្តីតក់ស្លុតយ៉ាងខ្លាំងហើយមិនដឹងថាត្រូវយ៉ាងដូចម្តេចឡើយក្រៅពីសំងំពួនយំនៅបន្ទប់ខាងក្រោយនោះ ។

ក្រោយមក ខ្ញុំប្រាប់ម្តាយមីងថា ខ្ញុំមិនចង់រួមរ័កជាមួយភ្ញៀវទេ ហើយទទូចសុំវិលត្រឡប់ទៅផ្ទះវិញ ។ ខ្ញុំប្រាប់គាត់ទៀតថា ឪពុកម្តាយខ្ញុំមិនមែនឱ្យមកធ្វើការងារបែបនេះទេ ។ មីងខ្ញុំតបវិញថា គាត់មិនខ្វល់ ខ្វាយទេ ព្រមទាំងវាយដំខ្ញុំដោយខ្សែភ្លើងលើខ្នងរហូតដល់បែកឈាមទៀតផង ។ ខ្ញុំយំសោកពេញមួយយប់ ដោយគិតថាស្អែកឡើងខ្ញុំត្រូវរួមរ័កជាមួយភ្ញៀវទៀត ។ ខ្ញុំបានបាត់បង់ព្រហ្មចារិនី ហើយមានភាពអាម៉ាស់នូវរាល់ទង្វើដែលបានកើតមាន ។

ប្រាំពីរថ្ងៃក្រោយមក ខ្ញុំមិនអាចស៊ូទ្រាំរស់នៅទីនេះទៀតបានឡើយ ។ ហេតុនេះថ្ងៃមួយសុំខ្ញុំម្តាយមីងទៅផ្សារដើម្បីទិញស្បែកជើង ។ ខ្ញុំគិតថា ដោយសារតែគាត់យល់ថាខ្ញុំបំរើភ្ញៀវច្រើននាក់ ទើបគាត់អនុញ្ញាតឱ្យខ្ញុំទៅផ្សារម្នាក់ឯង ដោយមិនបានគិតថា ខ្ញុំនឹងរត់គេចចេញពីទីនេះទេ ។ ខ្ញុំបានទាក់ទងណាត់ជួបបងថ្លៃប្រុសខ្ញុំនៅឯផ្សារ ហើយបានជិះម៉ូតូវិលត្រឡប់ទៅកាន់ផ្ទះរបស់គាត់ ដែលជាទីកន្លែងខ្ញុំបានរៀបរាប់ពីស្ថានភាពការងាររបស់ខ្ញុំកន្លងមក ។ ខ្ញុំពិតជាមានអារម្មណ៍ភ័យខ្លាចនៅពេលនិយាយប្រាប់ពីរឿងនេះ ប៉ុន្តែគាត់ជាមនុស្សមានសន្តានចិត្តល្អព្រមទាំងជឿនូវអ្វីដែលខ្ញុំបានរៀបរាប់ប្រាប់គាត់ ។ គាត់និយាយថា មីងខ្ញុំនោះជាមនុស្សអាក្រក់ណាស់ ហើយរឿងនេះត្រូវតែទៅរាយការណ៍ឱ្យប៉ូលីស ។ ក្រោមការជ្រោមជ្រែងពីបងថ្លៃខ្ញុំយើងបានទៅប្តឹងប៉ូលីស ។ បងថ្លៃប្រុសរបស់ខ្ញុំបានទាក់ទងទៅឪពុកម្តាយខ្ញុំ ព្រមទាំងបានប្រាប់គាត់ពីរឿងរ៉ាវរបស់ខ្ញុំទៀតផង ។

ពេលឪពុកម្តាយខ្ញុំបានដឹងរឿងរ៉ាវសព្វគ្រប់ ពួកគាត់តក់ស្លុតយ៉ាងខ្លាំង ប៉ុន្តែពួកគាត់បែរជាប្រាប់ខ្ញុំមិនឱ្យប្តឹងប៉ូលីស ហើយឱ្យខ្ញុំត្រូវដកពាក្យបណ្តឹងមកវិញ ។ នៅពេលខ្ញុំសួរគាត់ថា ហេតុអ្វីខ្ញុំធ្វើបែបនេះ គាត់បានប្រាប់ថា មីងខ្ញុំជាអ្នកមានលុយកាក់ យើងមិនគួរប្តឹងគាត់ទេ បើមិនដូច្នេះទេ គាត់នឹងបង្កផលវិបាកដល់ពួកយើង ។ ខ្ញុំមានកំហឹងយ៉ាងខ្លាំងចំពោះមីងខ្ញុំ ដោយមិនយល់ព្រមតាមគំនិតជាមួយឪពុកម្តាយខ្ញុំឡើយ ។ ដោយសារមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលមួយ ខ្ញុំនៅតែបន្តបណ្តឹងនៅប៉ុស្តិ៍ប៉ូលីសដដែល ។

ក្រោយមកមានសារព័ត៌មានមួយបានចុះផ្សាយរូបថត និងរឿងរ៉ាវរបស់ខ្ញុំ ។ ច្បាស់ណាស់ថាព័ត៌មានទាំងនេះត្រូវបានផ្តល់ទៅអ្នកសារព័ត៌មានដោយប៉ូលីស ។ ខ្ញុំរឹតតែដឹងទៀតថា ព័ត៌មាននោះនឹងត្រូវបានអានដោយអ្នកភូមិរបស់ខ្ញុំជាមិនខាន ខ្ញុំរឹតតែមានអារម្មណ៍ខ្មាសអៀនចំពោះឪពុកម្តាយខ្លាំងឡើងទៀត ។

*ចុងក្រោយខ្ញុំបានទៅតុលាការចំនួនបីលើក ដើម្បីពន្យល់ពីរឿងរ៉ាវដែលកើតឡើងចំពោះខ្ញុំ ។ អង្គការមិនមែនរដ្ឋាភិបាលជួយរកមេធាវីការពារក្ដីនេះ ប៉ុន្តែខ្ញុំនៅតែជួបប្រទះការលំបាកជាច្រើនរៀងរាល់ពេលទៅកាន់តុលាការម្ដងៗ ។ ខ្ញុំនៅតែប្រកាន់ជំហររៀបរាប់នូវអ្វីដែលគេបង្ខំឱ្យខ្ញុំធ្វើជាស្រីពេស្យា នៅក្នុងតុលាការដែលសម្បូរទៅដោយបុរសៗជាអ្នកសួរសំណួរ ហើយរឹតតែធ្វើឱ្យខ្ញុំអាម៉ាស់ និងខ្មាសអៀនជាពន់ពេក ។ លោកមេធាវីបានលើកទឹកចិត្តឱ្យខ្ញុំបន្តនិយាយ ហើយសូមកុំឱ្យមានអារម្មណ៍ថាឯកោធ្វើអ្វី ព្រោះធ្លាប់មាននារីរងគ្រោះជាច្រើនធ្លាប់បានឆ្លងកាត់បទពិសោធន៍បែបនេះដែរ ។*

*ថ្វីត្បិតបើខ្ញុំបានបង្ហាញខ្លួននៅតុលាការច្រើនលើកក៏ដោយ ម្ដាយមីងរបស់ខ្ញុំនៅតែមិនទាន់ត្រូវបានគេចាប់ខ្លួន ហើយមិនទាន់ដឹងថា តើមានអ្វីនឹងកើតឡើងចំពោះលទ្ធផលករណីបណ្ដឹងរបស់ខ្ញុំដែរ ។*

## អំពើជួញដូរមនុស្សនៅកម្ពុជា

អំពើជួញដូរមនុស្សគឺជាទំរង់ទាសភាពដ៏អាក្រក់បំផុត ។ ស្ត្រីភាគច្រើនត្រូវបានគេជួញដូរក្នុងគោលបំណងបំរើអាជីវកម្មផ្លូវភេទ និងបំរើការងារតាមគេហដ្ឋានដោយបង្ខំ និងទំរង់អំពើជួញដូរផ្សេងៗទៀតក៏កើតមានឡើងដែរ ។ ប្រទេសកម្ពុជា គឺជាប្រភពដែលអំពើជួញដូរឆ្លងកាត់ និងជាប្រទេសគោលដៅនៃអំពើជួញដូរមនុស្សមួយ ហើយបច្ចុប្បន្ននេះពុំទាន់មានស្ថិតិអំពីចំនួនស្ត្រីដែលកំពុងរងការជួញដូរនៅក្នុង និងនៅក្រៅកម្ពុជាឱ្យបានច្បាស់លាស់នៅឡើយទេ ហើយក៏បានបង្ហាញយ៉ាងច្បាស់ពីអំពើជួញដូរមនុស្សនេះ ថាជាបញ្ហាមួយដែលប៉ះពាល់ដល់ស្ត្រីជាច្រើន ។

កត្តាសំខាន់ដែលនាំឱ្យមានអំពើជួញដូរស្ត្រីនៅកម្ពុជា គឺភាពក្រីក្រ និងការធ្វើចំណាកស្រុក ដែលបញ្ហាទាំងពីរនេះពាក់ព័ន្ធគ្នាទៅវិញទៅមក ។ គ្រួសារក្រីក្រតស៊ូពុះពាររស់នៅ ហើយរស់នៅក្នុងរង្វង់ស្ថានភាពក្រីក្រច្រើនតែបង្ខំចិត្តលក់កូនស្រីរបស់ខ្លួនឱ្យទៅពួកជួញដូរមនុស្ស ឬឱ្យកូនស្រីរបស់ខ្លួនទៅអ្នកណាម្នាក់ ដើម្បីកាត់សងបំណុលក្នុងគ្រួសារ ។ នៅពេលដែលស្ត្រីត្រូវបានគេជួញដូរជនរងគ្រោះត្រូវបានបង្ខំឱ្យធ្វើការដើម្បីដោះសងបំណុលដែលគ្រួសាររបស់នាងបានជំពាក់គេ ។

ស្ត្រីភាគច្រើនធ្លាក់ចូលក្នុងអំពើជួញដូរក្នុងកំឡុងពេលដែលពួកគេកំពុងធ្វើចំណាកស្រុក ដោយពួកគេបានធ្វើដំណើរទៅកាន់ទីកន្លែងផ្សេងៗ ដើម្បីស្វែងរកការងារធ្វើ ជាពិសេសស្ត្រីដែលរស់នៅតាមតំបន់ជាប់នឹងព្រំប្រទល់ប្រទេស ។ ក្នុងដំណាក់កាលចាកចេញពីលំនៅដ្ឋាន ស្ត្រីភាគច្រើនត្រូវចាញ់បោកគេដោយពួកជួញដូរមនុស្សបាន

បោកប្រាស់ថា នឹងនាំទៅធ្វើការ ពួកនេះច្រើនតែបានសន្យាថាជួយ នាំឱ្យទៅដល់គោលដៅ ដែលជាកន្លែងធ្វើការ ដោយទារថ្លៃឈ្នួលនាំផ្លូវផង។ ដំណើរការបែបនេះត្រូវគេហៅថា"ការជ្រើសរើស មនុស្ស" ។[២៨] នៅពេលដែលស្ត្រីទាំងនោះក្លាយទៅជាមនុស្ស ដែលពឹងផ្អែកលើពួកជួញដូរមនុស្សទាំងស្រុង ដូចជាបញ្ហាភាសា ម្ហូបអាហារ និងការងារជាដើម ចំណុចទាំងនេះហើយ ដែលស្ត្រីត្រូវបានគេជួញដូរ។ ចំណងបំណុល ក៏អាចកើតឡើងដោយគេប្រាប់ជនរងគ្រោះថា នាងបានជំពាក់គុណមនុស្ស ដែលជួយរៀបចំការធ្វើដំណើររបស់នាង និងការចំណាយសោហ៊ុយផ្សេងៗទៀត ដើម្បីសងបំណុលទាំងនេះវិញ ស្ត្រីទាំងនោះត្រូវបានគេបង្ខំឱ្យធ្វើការងារជាស្ត្រីរកស៊ីផ្លូវភេទ ឬធ្វើការងារក្នុងទម្រង់ពលកម្មដោយបង្ខិតបង្ខំផ្សេងៗទៀត។

**"ខ្ញុំធ្លាប់គិតថា ស្ត្រី និងបុរសមានសិទ្ធិស្មើគ្នា ប៉ុន្តែសំរាប់ខ្ញុំ វាហាក់ដូចជាខ្ញុំពុំមានសិទ្ធិស្មើគ្នាទេ។ ខ្ញុំគឺជាមនុស្សកំទិចកំទីម្នាក់ និងមានឋានៈទាបជាងបុរស។"**

*សំដីរបស់ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ អាយុ៥២ឆ្នាំ រស់នៅខេត្តបាត់ដំបង ។*

ពួកជួញដូរបោកបញ្ឆោត គឺសំដៅលើស្ត្រីដែលងាយរងគ្រោះបំផុត ដូចជាស្ត្រីក្រីក្រ ពុំបានរៀនសូត្រ និងពុំមានការយល់ដឹងអំពីសិទ្ធិស្ត្រីជាដើម ។ ស្ត្រីដែលត្រូវជួញដូរជាទូទៅឈឺចាប់ពីទំរង់ហិង្សាច្រើនប្រភេទ ។ ស្ត្រីដែលត្រូវជួញដូរក្នុងអាជីវកម្មផ្លូវភេទ ឧទាហរណ៍ ពួកគេត្រូវរំលោភផ្លូវភេទជាប្រចាំ ។ នាងអាចត្រូវតែវាយដំ ឬបង្ខំឱ្យប្រើប្រាស់ថ្នាំញៀនពីសំណាក់ម្ចាស់បន ដើម្បីធ្វើឱ្យពួកនាងស្តាប់បង្គាប់ នឹងមិនព្យាយាមចង់រត់គេចចេញ ។ ម្យ៉ាងវិញទៀត នារីដែលបង្ខំឱ្យធ្វើជាអ្នកបំរើការងារតាមផ្ទះ គឺជាជនងាយរងគ្រោះបំផុតពីការរំលោភបំពានរាងកាយ និងផ្លូវភេទពីសំណាក់ម្ចាស់ផ្ទះ ឬសមាជិកក្នុងផ្ទះនោះ ។

## ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្ស និងអំពើអាជីវកម្មមនុស្ស

នៅឆ្នាំ ១៩៩៦ កម្ពុជាបានអនុម័ត*ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្ស និងអំពើអាជីវកម្មមនុស្ស* ដែលហៅថាច្បាប់ជួញដូរ ដើម្បីឆ្លើយតបទៅនឹងការរីករាលដាលយ៉ាងលឿននៃអំពើជួញដូរមនុស្សដែលជួយរុញច្រានដោយតម្រូវការស្ត្រីរកស៊ីផ្លូវភេទ ។

**ការជួញដូរមនុស្សនៅកម្ពុជាត្រូវបានគ្រប់គ្រងដោយៈ**

- ច្បាប់ស្តីពីការបង្រ្កាបអំពើចាប់ជម្រិត ជួញដូរ និងធ្វើអាជីវកម្មមនុស្ស
- ច្បាប់អ៊ុនតាក់
- ច្បាប់អន្តោរប្រវេសន៍
- ច្បាប់ការងារ
- ច្បាប់រដ្ឋធម្មនុញ្ញ

[២៨] លីកាដូ - របាយការណ៍ស្តីពីអំពើហិង្សាលើស្ត្រីនៅកម្ពុជា ឆ្នាំ ២០០៥ ទំព័រ ១៥ ។

# កង្វះនិយមន័យក្នុងច្បាប់ជួញដូរមនុស្ស

មាត្រា៣នៃច្បាប់ជួញដូរមនុស្ស បានកំណត់និយមន័យនៃពាក្យជួញដូរថាៈ

*"ជនណាអូសទាញមនុស្សម្នាក់ទៀត ទោះជាស្រី ឬប្រុស អនីតិជន ឬនីតិជន មានសញ្ជាតិអ្វីក៏ដោយ ដោយវិធីលួងលោមសន្យាឱ្យប្រាស់កាស ឬគ្រឿងអលង្កា ឬតាមវិធីណាក៏ដោយ ទោះសាម៉ីខ្លួនសុខចិត្ត ឬមិនសុខចិត្ត ដោយវិធីបង្ខំ គំរាមកំហែង ឬប្រើប្រាស់ថ្នាំសណ្តំស្មារតី និងសតិអារម្មណ៍ ដើម្បីពង្រត់យកទៅលក់ ឬយកទៅធ្វើពេស្យាចារ ជាដើម..."។*

*"អ្នកសមគំនិត អ្នកលក់ អ្នកទទួលទិញ ឬមកទទួលយក ត្រូវមានទោសដូចអ្នកប្រព្រឹត្តដែរ។ ត្រូវចាត់ទុកជាអ្នកសមគំនិតដែរ អ្នកដែលផ្តល់ប្រាក់ ឬផ្តល់មធ្យោបាយផ្សេងៗសំរាប់ប្រព្រឹត្តបទល្មើស"។*

ដោយនិយមន័យនៃពាក្យជួញដូរខាងលើមើលទៅហាក់ដូចជាមានភាពក្បោះក្បាយណាស់ ប៉ុន្តែនិយមន័យនេះពុំបានលើកយក មកពិចារណានូវសកម្មភាពចម្រុះគ្នាដែលចាត់ទុកជាអំពើជួញដូរនោះទេ។ និយមន័យបច្ចុប្បន្ននេះបានគ្របដណ្តប់ ទៅលើទម្រង់ជួញដូរសាមញ្ញជាច្រើនដែលទាក់ទងទៅនឹងការសន្យាផ្តល់ប្រាក់កាស ការប្រើប្រាស់ការគំរាមកំហែង បង្ខិតបង្ខំ គ្រឿងញៀន និងការបោកបញ្ឆោត ។ ប៉ុន្តែ ដើម្បីបង្ក្រាបរាល់ទម្រង់នៃអំពើជួញដូរមនុស្ស និយមន័យ ត្រូវតែមានលក្ខណៈទូលំទូលាយគ្រប់គ្រាន់ ដែលអាចទប់ទល់នូវវិធីផ្សេងៗដែលអាចធ្វើឱ្យមនុស្សធ្លាក់ចូលក្នុងអំពើជួញដូរ។ ឧទាហរណ៍ និយមន័យបច្ចុប្បន្ននេះពុំបានគ្របដណ្តប់សកម្មភាពដែលឪពុកម្តាយលក់កូនស្រី ដើម្បីសងបំណុលទេ ដែលបញ្ហានេះកើតឡើងជាទូទៅនៅកម្ពុជា។ នារីដែលត្រូវបានជួញដូរដោយពុំមានការលួងលោម ឬសន្យាឱ្យប្រាក់កាស ឬដោយការបង្ខិតបង្ខំ ដើម្បីការជួញដូរក្តី ក៏នាងមិនគ្រាន់តែគោរពតាមឆន្ទៈរបស់ឪពុកម្តាយ នឹងជួយគ្រួសារ ដើម្បីសងបំណុលតែប៉ុណ្ណោះទេ។ បញ្ហានេះច្បាស់ណាស់ថា គឺនាងត្រូវបានគេជួញដូរ ប៉ុន្តែ ច្បាប់ជួញដូរមនុស្សបច្ចុប្បន្ននេះពុំបានគិតថានាងជាជនរងគ្រោះដោយករណីជួញដូរទេ ។

ពិធីសាររបស់អង្គការសហប្រជាជាតិ ដើម្បីទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មអំពើជួញដូរមនុស្សជាពិសេស ជួញដូរស្ត្រី និងកុមារ បានកំណត់នូវនិយមន័យនៃការជួញដូរយ៉ាងទូលំទូលាយមួយ ដែលជាបទដ្ឋានទទួលស្គាល់ដោយអន្តរជាតិ។

*(ក ) "អំពើជួញដូរមនុស្ស" គឺរួមមាន សកម្មភាពនៃការជ្រើសរើស ដឹកជញ្ជូន ផ្ទេរ ផ្តល់កន្លែង ឬ ទទួលមនុស្ស ដោយមធ្យោបាយគំរាមកំហែង ឬប្រើប្រាស់កម្លាំង ឬទម្រង់បង្ខិតបង្ខំផ្សេងទៀត ចាប់ជម្រិត បន្លំ បោកបញ្ឆោត រំលោភអំណាច ឬតួនាទីរបស់ជនងាយរងគ្រោះ ឬការប្រគល់ឱ្យ ឬការទទួលការចំណាយ ឬផល*

*ប្រយោជន៍ផ្សេងៗ ដើម្បីឱ្យមានការយល់ព្រមរបស់មនុស្សម្នាក់ដែលគ្រប់គ្រងលើមនុស្សផ្សេងទៀត ដើម្បីគោលបំណងធ្វើអាជីវកម្ម។ អាជីវកម្មរួមមាន ជាអប្បបរមាអាជីវកម្មពេស្យាចារក្នុងទម្រង់អាជីវកម្មផ្លូវភេទផ្សេងទៀត ពលកម្ម ឬសេវាកម្មដោយបង្ខំ ទាសភាព ឬការអនុវត្តន៍ស្រដៀង នឹងទាសភាព ការបំរើបែបទាសភាព ឬការវះកាត់យកសរីរាង្គ។*

(ខ) *ការយល់ព្រមរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅក្នុងផ្នែកណាមួយនៃអាជីវកម្ម ដែលកំណត់នៅក្នុងកថាខណ្ឌ (ក) នៃមាត្រានេះ នោះពុំមានទាក់ទងដោយមធ្យោបាយណាមួយដែលបានកំណត់នៅក្នុងកថាខណ្ឌ (ក) ដែលធ្លាប់បានប្រើហើយនោះទេ។*

(គ) *ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់ទីកន្លែង ឬ ទទួលកុមារក្នុងគោលបំណងអាជីវកម្មត្រូវចាត់ទុកជា "អំពើជួញដូរមនុស្ស" ទោះជាអំពើនេះមិនជាប់ទាក់ទងជាមួយនឹងមធ្យោបាយណាមួយដែលបានថែងនៅក្នុងកថា ខណ្ឌ (ក) នៃមាត្រានេះក៏ដោយ"។*[២៩]

និយមន័យខាងលើមានលក្ខណៈទូលំទូលាយ នឹងចាត់ទុកសកម្មភាពចម្រុះនៃការជ្រើសរើស ដែលអាចពាក់ព័ន្ធនឹងការរំលោភអំណាច ជាពិសេសអំណាចដែលបុរសប្រើទៅលើស្ត្រីសំរាប់ការបោកបញ្ឆោតដែលដើរតួនាទីសំខាន់បំផុតនៅក្នុងករណីជួញដូរភាគច្រើន នឹងកេងប្រវ័ញ្ចលើភាពងាយរងគ្រោះរបស់មនុស្ស ។

## ច្បាប់អន្តោប្រវេសន៍

មាត្រា ២៩ នៃច្បាប់ស្តីអន្តោប្រវេសន៍បញ្ញត្តដូចខាងក្រោមៈ

*"ជនបរទេសរូបណាដែលគ្មានការអនុញ្ញាតិ ហើយចូលមកព្រះរាជាណាចក្រកម្ពុជា ដោយលបលាក់បន្លំ ឬ ដោយល្បិចផ្សេងទៀតដែលផ្ទុយនឹងមាត្រានៃច្បាប់នេះ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី បីខែ ដល់ ប្រាំមួយខែ មុននឹងត្រូវបណ្តេញចេញ។"*

នេះគឺជាបញ្ហាទូទៅដែលជនរងគ្រោះដោយអំពើជួញដូរប្រឈមមុខ គឺពួកគេកំពុងធ្វើការ និងរស់នៅបរទេសដោយខុសច្បាប់ ហើយប្រឈមមុខនឹងការចាប់ឃុំខ្លួនក្នុងពន្ធនាគារថែមទៀត។ អនុសញ្ញា CEDAW បាន

---

[២៩] ពិធីសារដើម្បីទប់ស្កាត់ បង្ក្រាប និង ដាក់ទណ្ឌកម្មអំពើជួញដូរមនុស្ស ជាពិសេសជួញដូរស្ត្រី និងកុមារ បន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ។ អនុម័តនិងបើកចំហរ ដើម្បីចុះហត្ថលេខាផ្តល់សច្ចាប័ន នឹងទទួលយល់ព្រមដោយសេចក្តីសម្រេចមហាសន្និបាតអង្គការសហប្រជាជាតិ លេខ ៥៥/២៥ ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០០០។ (មាត្រា ៣) http://www.ohchr.org/english/law /protocoltraffic.htm ។

ដាក់កាតព្វកិច្ចឱ្យរដ្ឋភាគីទាំងឡាយចាត់វិធានការស្តារនីតិសម្បទា ដើម្បីការពារជនរងគ្រោះដោយអំពើជួញដូរ ប៉ុន្តែ ច្បាប់អន្តោប្រវេសន៍កម្ពុជាពុំបានលើកលែងពីការផ្តន្ទាទោសដល់ជនរងគ្រោះដោយអំពើជួញដូរឡើយ។ ភស្តុតាងនៅក្នុងករណីសិក្សាក៏បានបង្ហាញពីស្ត្រីរកស៊ីផ្លូវភេទជនជាតិវៀតណាមជាច្រើនអាចត្រូវបានគេជួញដូរត្រូវបានឃុំឃាំងដោយការចូលមកកម្ពុជាខុសច្បាប់។ ក្នុងស្ថានភាពបែបនេះ ជនរងគ្រោះដោយអំពើជួញដូរអាចប្រឈមមុខមិនត្រឹមតែការផ្តន្ទាទោសនឹងជាប់ពន្ធនាគារប៉ុណ្ណោះទេ ប៉ុន្តែត្រូវបញ្ជូនចេញពីកម្ពុជាថែមទៀត ដោយពុំមានការជួយឧបត្ថម្ភនូវសេវាកម្ម ដូចជាការស្តារនីតិសម្បទា លទ្ធភាពពលកម្ម និងសេវាកម្មឧបត្ថម្ភផ្សេងណាមួយទៀតឡើយ។ បញ្ហានេះបានរុញច្រាន ឱ្យពួកគេប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់ឡើង ដោយសារតែអាចក្លាយទៅជាជនរងគ្រោះលើកទីពីរពីការជួញដូរសារជាថ្មី។

មិនទាន់មានមាត្រាណាមួយពិតប្រាកដចែងទាក់ទងជាមួយនិងការធ្វើមាតុភូមិនិវត្តន៍ ឬស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅក្នុងច្បាប់កម្ពុជាឡើយ។ ប៉ុន្តែ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយបានធ្វើអនុស្សារណៈស្តីពីការយោគយល់គ្នាជាមួយប្រទេសវៀតណាម និងថៃឡង់ដ៏។ អនុស្សារណៈនៃការយោគយល់គ្នាបានបញ្ញត្តិស្តីពីកិច្ចព្រមព្រៀងទៅវិញទៅមកក្នុងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

## ច្បាប់ការងារ

មាត្រា ១៥ និង ១៦នៃច្បាប់ការងារបានហាមប្រាមពលកម្មដោយបង្ខំ និងការងារ ដើម្បីសងបំណុលដែលជាទម្រង់ជួញដូរមនុស្សសម័យទំនើប។ ... 

ដែលជាទម្រង់ជួញដូរមនុស្សសមញ្ញរហូតដល់ទម្រង់ទាសករសម័យថ្មី។ ប៉ុន្តែ នៅក្នុងមាត្រានេះពុំមានភ្ជាប់ការដាក់ទណ្ឌកម្ម ទៅនឹងអំពើរំលោភបំពាននេះទេ។

## វិធានការស្តារនីតិសម្បទា

ក្នុងច្បាប់ជួញដូរមនុស្សមិនមានចែងពីមាត្រាណា ដែលចាត់វិធានការស្តីអំពីការស្តារនីតិសម្បទាតាមតម្រូវការដូចមានក្នុងអនុសាសន៍ទូទៅ ១៩ ចំណុច នៃអនុសញ្ញាស្តីអំពីការលុបបំបាត់នូវរាល់ទំរង់នៃការរើសអើសប្រឆាំងនារីភេទឡើយ។[៣០]

[៣០] អនុសាសន៍ទូទៅ ១៩ រៀបរាប់យ៉ាងជាក់លាក់ក្នុង CEDAW (វគ្គខណ្ឌ ២៤-ឆ-(i)

# សេចក្តីសន្និដ្ឋាន

សេចក្តីអនុម័តច្បាប់ជួញដូរមនុស្សឆ្នាំ ១៩៩៦ ជាជំហានមួយឆ្ពោះទៅរកការលុបបំបាត់ការប្រព្រឹត្តអំពើជួយដូរមនុស្ស ។ ប៉ុន្តែ ភាពចាំបាច់មួយដែលមានសារៈសំខាន់ចំពោះច្បាប់នេះត្រូវមានចំណុចសំខាន់ៗគ្រប់គ្រាន់ដើម្បីគ្របដណ្តប់លើបញ្ហាស្មុគ្រស្មាញលើអំពើជួញដូរមនុស្ស រួមមានចំណុចមួយចំនួនដូចជា ការជ្រើសរើសមនុស្ស ការធ្វើមាតុភូមិនិវត្តន៍ និងស្តារនីតិសម្បទា។ ច្បាប់ជួញដូរមនុស្សសព្វថ្ងៃមានការកំណត់អត្ថន័យទំរង់មិនគ្រប់គ្រាន់ដើម្បីបំពេញឱ្យ សមស្របទៅនឹងអនុសញ្ញាស្តីអំពីការលុបបំបាត់នូវរាល់ទំរង់នៃការរើសអើសប្រឆាំងនារីភេទនៅឡើយ ។

□□□

# ៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

រៀងរាល់ថ្ងៃស្ត្រីកម្ពុជាច្រើននាក់រងគ្រោះឈឺចាប់ខ្លោចផ្សារដោយអំពើហិង្សាជាប្រចាំ។ នេះគឺជាលទ្ធផលនៅក្នុងសង្គមរស់នៅអន់ខ្សោយ ជាទូទៅចំពោះស្ត្រីកម្ពុជាត្រូវរែកងប្រវ័ញ្ចពីសំណាក់ប្តី ឪពុក អ្នកជិតខាង អាជ្ញាធរ និងដោយមនុស្សដទៃទៀតក្នុងសង្គមរស់នៅរបស់ខ្លួនជា។

**"ខ្ញុំមិនយល់ទេថាហេតុអ្វីបានជាមានការរើសអើងរវាងបុរស និង ស្ត្រី។ បុរស និង ស្ត្រីមានសិទ្ធិស្មើគ្នា។ ដូច្នេះ បុរស និង ស្ត្រីត្រូវតែប្រព្រឹត្តទៅស្មើៗគ្នា។"**

*សំដីរបស់ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ អាយុ៤៤ឆ្នាំ រស់នៅទីក្រុងភ្នំពេញ ។*

ច្បាប់បច្ចុប្បន្ននេះត្រូវតែការពារស្ត្រីកម្ពុជាអំពីអំពើហិង្សា ប៉ុន្តែនៅមានការរើសអើងចំពោះពួកគេយ៉ាងពិតប្រាកដ និងមិនអាចប្រកែកបានឡើយ ហើយវារឹតតែបង្ហាញយ៉ាងច្បាស់នូវការឈឺចាប់ និងភាពងាយរងគ្រោះរបស់ពួកគេពីអំពើហិង្សា។ ករណីសិក្សាដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ បានផ្អែកលើរឿងរ៉ាវជាក់ស្តែងនៃអំពើអាក្រក់ និងអំពើហិង្សាដែលបានកើតឡើងឥតឈប់ឈរចំពោះស្ត្រីកម្ពុជា ហើយនិងគោលការណ៍ច្បាប់ និងការអនុវត្តន៍ច្បាប់នៅកម្ពុជាតែងតែបរាជ័យដោយមិនបានជួយជនរងគ្រោះច្រើនឡើយ ។

សមាជិកគណៈកម្មាធិការស្ត្រីកម្ពុជា (CAMBOW) សង្ឃឹមថារបាយការណ៍នេះនឹងជួយជម្រុញឱ្យមានការផ្លាស់ប្តូរនៅក្នុងទម្រង់ច្បាប់កម្ពុជាមួយចំនួន ដែលទាក់ទងជាមួយអំពើហិង្សាលើស្ត្រី។ ហេតុដូច្នេះ រាជរដ្ឋាភិបាលកម្ពុជាត្រូវចាប់ផ្តើមពិនិត្យប្រព័ន្ធច្បាប់សារជាថ្មី ដើម្បីលុបបំបាត់ការរើសអើងដែលកើតឡើងចំពោះជនដែលងាយរងគ្រោះ និងដើម្បីឱ្យស្របជាមួយមាត្រានានានៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនារីភេទ (CEDAW) ដែលកម្ពុជាបានផ្តល់សច្ចាប័នតាំងពីឆ្នាំ ១៩៩២ ។

## អនុសាសន៍

១-សហគមន៍អន្តរជាតិគួរប្រើប្រាស់ឥទ្ធិពលរួមរបស់ខ្លួន ដើម្បីធ្វើយ៉ាងណាឱ្យរដ្ឋាភិបាលកម្ពុជាសម្រេចកាតព្វកិច្ចរបស់ខ្លួនឱ្យបានតាម *អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ* ។

២-អង្គការសង្គមស៊ីវិលត្រូវរួមសហការគ្នា ដើម្បីផ្តោតការយកចិត្តទុកដាក់ចំពោះបញ្ហាហិង្សាលើស្ត្រីដែលជាបញ្ហាបន្ទាន់ជាទីបំផុត ដោយប្រើប្រាស់គ្រប់កាលៈទេសៈ ដើម្បីសុំទាមទារឱ្យរដ្ឋាបាលកម្ពុជាបំពេញកាតព្វកិច្ចរបស់ខ្លួនតាម *អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ*។

ជាពិសេស CAMBOW សូមអំពាវនាវទាំងសហគមន៍អន្តរជាតិ និងអង្គការសង្គមស៊ីវិលកម្ពុជាធ្វើការបញ្ចុះបញ្ចូល និងជំរុញឱ្យរដ្ឋាបាលកម្ពុជាអនុវត្តអនុសាសន៍ខាងក្រោមនេះជាបន្ទាន់ ។

- អនុម័តច្បាប់ទាំងឡាយដែលប្រឆាំងនឹងអំពើហិង្សាលើស្ត្រី ដើម្បីឱ្យស្របជាមួយអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ និងច្បាប់អន្តរជាតិផ្សេងៗទៀត ។

## អំពើហិង្សាក្នុងគ្រួសារ

- អនុវត្តអនុក្រិត្យ ដើម្បីឱ្យមានការប្រតិបត្តិ *ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ* ឱ្យបានច្បាស់លាស់ ។
- ធ្វើវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដោយរាប់បញ្ចូលនូវអំពើហិង្សាផ្នែកសេដ្ឋកិច្ចជាទម្រង់នៃអំពើហិង្សាក្នុងគ្រួសារទៅក្នុងច្បាប់នេះ ។
- ធ្វើវិសោធនកម្មច្បាប់ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដោយដាក់បញ្ចូលមាត្រាដាក់ទោសទណ្ឌមួយចំនួនទៅក្នុងច្បាប់នេះផង ។ ជាពិសេស ផ្នែកនេះគួរដាក់បញ្ចូលនូវការផ្តន្ទាទោស ចំពោះអំពើហិង្សាខាងរាងកាយ ខាងផ្លូវភេទ ខាងផ្លូវចិត្ត និងផ្នែកសេដ្ឋកិច្ចផងដែរ ។
- ប្រសិនបើមិនអាចព្រាងឱ្យមានផ្នែកផ្តន្ទាទោសដាក់ក្នុងច្បាប់នេះបានទេ នោះត្រូវធ្វើវិសោធនកម្មច្បាប់ព្រហ្មទណ្ឌអន្តរកាលនូវមាត្រាដែលពាក់ព័ន្ធជាមួយនឹងការផ្តន្ទាទោសវិញ ។
- ធ្វើវិសោធនកម្ម ឬដាក់បញ្ចូលនូវក្រមព្រហ្មទណ្ឌនូវមាត្រាការពារខ្លួនចំពោះបទក្រិដ្ឋ ដូចជាៈ ឃាតកម្ម មនុស្សឃាត និងវាយបង្កឱ្យមានរបួសស្នាម ។
- បន្ថែមនិយមន័យអំពីរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ នឹងកំណត់និយមន័យពីសញ្ញាណនៃការព្រមព្រៀងឱ្យបានច្បាស់លាស់ ។
- បញ្ជាក់ និងកំណត់ន័យនៃពាក្យ *"អាជ្ញាធរមានសមត្ថកិច្ច"* ឱ្យបានច្បាស់លាស់ ។
- លុបចោលមាត្រាពាក់ព័ន្ធជាមួយនឹងការជម្លៀសជនរងគ្រោះចេញពីកន្លែងកើតហេតុ ដោយពុំចាំបាច់មានសំណើរបស់សាម៉ីខ្លួន ( មាត្រា ២៥) ។
- ធ្វើវិសោធនកម្មមាត្រាស្តីពីការផ្សះផ្សា ដោយអនុញ្ញាតឱ្យមានជម្រើសផ្សេងៗក្នុងការជ្រើសរើសអ្នកសម្រុះសម្រួលអព្យាក្រិត្យ ហើយបញ្ជាក់ឱ្យបានច្បាស់លាស់ពីសកម្មភាពហិង្សាបែបណាខ្លះដែលត្រូវឆ្លងកាត់ការផ្សះផ្សា ឬមិនត្រូវការផ្សះផ្សាជាជាងការផ្តន្ទាទោស ។
- ត្រូវធានាថាជនរងគ្រោះដោយអំពើហិង្សា ដែលស្វែងរកការលះលែងពីជនល្មើស គឺមិនចាំបាច់ឆ្លងកាត់ដំណើរការផ្សះផ្សា ឬការសម្រុះសម្រួលពីសំណាក់មន្ត្រី ឬតុលាការមូលដ្ឋានសំរេចឱ្យនាងត្រូវវិលទៅរស់នៅជាមួយជនល្មើសវិញទេ ។

- ដាក់បញ្ចូលនូវវិធានការស្តារនីតិសម្បទា សម្រាប់ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារនៅក្នុងច្បាប់ ។

## អាពាហ៍ពិពាហ៍ និងគ្រួសារ

- លុបចោលនូវមាត្រា ដែលផ្តល់ឱ្យឪពុកម្តាយ ឬអាណាព្យាបាលនូវសិទ្ធិអនុញ្ញាតឱ្យកូនស្រីរៀបអាពាហ៍ពិពាហ៍ក្នុងកាលៈទេសៈជាពិសេស (ដូចជាមានផ្ទៃពោះជាដើម) នៅវ័យក្មេងជាងអាយុដែលមានចែងនៅក្នុងច្បាប់ ។
- គួរកាត់បន្ថយនីតិវិធីក្នុងការផ្សះផ្សាខ្លះ ដើម្បីឱ្យស្ត្រីងាយស្រួលក្នុងការលះលែង ដោយកាត់ចោលនូវរយៈពេលនិងចំនួនពេលនៃការផ្សះផ្សាកុំឱ្យមានដំណើរវិធីផ្សះផ្សាច្រើនដង និងចំណាយពេលយូរដូចសព្វថ្ងៃ ។
- ធ្វើវិសោធនកម្មលើច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ត្រង់ចំណុចដែលលើកឡើងថា ពេលមានហេតុផលសង្ស័យណាមួយថាមានអំពើហិង្សាកើតឡើងនោះ ហើយប្រសិនជនរងគ្រោះព្យាយាមស្វែងរកការលះលែងគ្នា នាងមិនត្រូវចូលរួមវគ្គស្តារនិតិសម្បទាជាមួយនិងជនល្មើសទេ ។

## អំពើរំលោភសេពសន្ថវៈ

- អនុម័តច្បាប់ស្តីពីអំពើរំលោភសេពសន្ថវៈដោយមានការឱ្យនិយមន័យនូវធាតុផ្សំ "ព្រមព្រៀង" ឱ្យបានច្បាស់លាស់ដែលវាជាពាក្យមួយយ៉ាងសំខាន់ដែលត្រូវការ ដើម្បីវាយតម្លៃឱ្យច្បាស់ថា តើជាបទល្មើសរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភសេពសន្ថវៈ ។
- ធ្វើវិសោធនកម្ម *ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ* ដោយកំណត់ន័យនៃពាក្យបទឧក្រិដ្ឋនៃអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ឱ្យបានជាក់លាក់ និងច្បាស់លាស់ ។
- ដាក់បញ្ចូលនូវវិធានការស្តារនីតិសម្បទាសម្រាប់ជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈ ។

## អំពើជួញដូរមនុស្ស

- អនុម័តច្បាប់ស្តីពីអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទឱ្យបានឆាប់តាមដែលអាចធ្វើបាន ។ ច្បាប់នេះគួរដាក់បញ្ចូលនូវនិយមន័យនៃអំពើជួញដូរមនុស្ស ដែលជាបទដ្ឋានអន្តរជាតិឱ្យបានទូលំទូលាយ ។
- ច្បាប់នេះក៏ត្រូវដាក់បញ្ចូលមាត្រាអំពីកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរ រួមទាំងស្តារនីតិសម្បទានិងមាតុភូមិនិវត្តន៍ ដែលជាភារៈកិច្ចចាំបាច់និងសេវាកម្មឧបត្ថម្ភមួយចំនួនទៀត ។
- ធ្វើវិសោធនកម្មច្បាប់អន្តោប្រវេសន៍ដោយឈប់ផ្តន្ទាទោសជនបរទេសដែលត្រូវបានគេជួញដូរមកកម្ពុជា

□□□

# ឧបសម្ព័ន្ធទី ១: ឯកសារសិក្សាប្រៀបធៀប

១. **មូលនិធិអាស៊ី** "ការធ្វើសមាហរណកម្មឡើងវិញចំពោះការផ្តល់ជំនួយដល់ស្ត្រីនិងកុមារដែលត្រូវគេជួញដូរនៅកម្ពុជា: ឯកសារសង្ខេប" ខែកញ្ញា ឆ្នាំ២០០៥។

របាយការណ៍នេះ ធ្វើការពិនិត្យជាទូទៅឡើងវិញលើបទដ្ឋាននៃមូលនិធិអាស៊ីដែលទាក់ទងនឹងដំណើរការធ្វើសមាហរណកម្មឡើងវិញនៃការជួញដូរ។ របាយការណ៍នេះសង្ខេបពីចំលើយតបពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាចំពោះការជួញដូរ ដែលរួមទាំងសេចក្តីសង្ខេបនៃច្បាប់ និងកម្មវិធីនានារបស់រដ្ឋាភិបាលដោយផ្តោតលើការជួញដូរ។ របាយការណ៍នេះក៏បង្ហាញពីការឆ្លើយតបពីសំណាក់ភ្នាក់ងារអន្តរជាតិ ដោយផ្តោតលើកម្មវិធីផ្សេងៗរបស់អង្គការអន្តរជាតិលើការប្រឆាំងនឹងការជួញដូរ ។ចុងក្រោយរបាយការណ៍នេះបង្ហាញពីការឆ្លើយតបពីសំណាក់បណ្តាអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា ចំពោះការធ្វើសមាហរណកម្មឡើងវិញលើការជួញដូរ។

២. **គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា** លើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារី និងគណៈកម្មាធិការស្ត្រីកម្ពុជា"ការអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទនៅកម្ពុជា" ឧបត្ថម្ភដោយជំនួយព្រះវិហាដាណឺមាក (DCA) ឆ្នាំ ២០០៥។

របាយការណ៍ស្រមោលលើកទី១ ទី២ និងទី៣ ដែលរៀបចំដោយរាជរដ្ឋាភិបាលកម្ពុជាសំរាប់គណៈកម្មាធិការអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ ដើម្បីធ្វើការត្រួតពិនិត្យនាខែមករា ឆ្នាំ២០០៦។ របាយការណ៍នេះបានពិភាក្សាអំពីច្បាប់នានា និងការអនុវត្តច្បាប់របស់ រដ្ឋាភិបាលដែលពុំគោរពតាមអនុសញ្ញាស្តីពីការលុបបំបាត់រាល់ ទម្រង់នៃការរើសអើងប្រឆាំងនារីភេទដោយបង្ហាញពីឧបសគ្គនានា ចំពោះការអនុវត្តន៍អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ និងផ្តល់អនុសាសន៍ដើម្បីលើកកំពស់ស្ថានភាពស្ត្រីក្នុងប្រទេសកម្ពុជា ដោយផ្អែកលើសិទ្ធិស្ត្រីមួយចំនួនដូចជា សិទ្ធិដីធ្លីនិងធនធានធម្មជាតិ សិទ្ធិទទួលការអប់រំ សិទ្ធិសុខភាពបន្តពូជ សិទ្ធិសេដ្ឋកិច្ច ស្ត្រីក្នុងការសំរេចចិត្ត និងអំពើហិង្សាលើស្ត្រី។

៣. **គណៈកម្មាធិការអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ** "របាយការណ៍រួមស្តីពីដំណាក់កាល ទី១ ទី២ និងទី៣ របស់ភាគីរដ្ឋាបាលកម្ពុជា" ថ្ងៃទី១១ ខែ កុម្ភៈ ឆ្នាំ២០០៤។

នេះជារបាយការណ៍ដំបូងរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយលំអិតនូវការខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ នៅពេលដែលកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញានេះនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ ១៩៩២ ដោយមិនបានព្រាងទុក។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថាខ្លួន ពុំបានគោរពតាមចំនុចមួយចំនួនក្នុងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ ដោយអះអាងថាសង្គ្រាមស៊ីវិលអស់រយៈពេលពីរទស្សវត្សបានធ្វើឱ្យរាំងស្ទះដល់ការអនុវត្តន៍សិទ្ធិមនុស្សអន្តរជាតិទាំងស្រុង។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថា ការប្រកាន់ប្រពៃណីទំនៀមទំលាប់ជាឧបសគ្គរាំងស្ទះមិនឱ្យមានការទទួលស្គាល់ និងគោរពសិទ្ធិស្ត្រី ប៉ុន្តែ បែរជាអះអាងថាដើម្បីឱ្យមានការផ្លាស់ប្តូរការការយល់ឃើញបែបនេះ ជាពិសេសនៅតាមសហគមន៍ជនបទគឺត្រូវការពេលវេលាដ៏យូរមួយ។

៤. **គណកម្មាធិការអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ** "សេចក្តីសន្និដ្ឋានរបស់គណៈកម្មាធិការអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទៈ កម្ពុជា" សម័យប្រជុំលើកទី៣៤ (ថ្ងៃទី១៦ ខែមករា ដល់ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០៦) ថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៦។

គណៈកម្មាធិការអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ លើកឡើងពីការព្រួយបារម្ភសំខាន់ៗ និងអនុសាសន៍មួយចំនួនដល់កម្ពុជា។

៥. **គណៈកម្មាធិការអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ** "ការឆ្លើយតបនឹងបញ្ហា និងសំនួរមួយចំនួនដើម្បីធ្វើការពិចារណាលើរបាយការណ៍ដំណាក់កាលទី១ ទី២ និងទី៣ៈ កម្ពុជា "ក្រុមការងារមុនការប្រជុំសម័យប្រជុំលើកទី៣៤ (ថ្ងៃទី១៦ ខែមករា ដល់ ថ្ងៃទី៣ ខែកុម្ភៈ) ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៦។

ឯកសារនេះរួមមានបញ្ជីសំនួរដែលលើកឡើងដោយ គណៈកម្មាធិការអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទដល់រាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការព្រួយបារម្ភនិងអនុសាសន៍ពីសំណាក់គណៈកម្មាធិការអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ និងការផ្តល់ចំលើយពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា។

៦. **គណៈកម្មការសេដ្ឋកិច្ច និងសង្គមក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក** "អំពើហិង្សា និងការជួញដូរលើស្ត្រីជាសញ្ញានៃការរើសអើងៈ សក្តានុពលរបស់គណកម្មាធិការអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើស

អើងប្រឆាំងនារីភេទ ជាដំណោះស្រាយ" ឯកសារពិភាក្សាលើយេនឌ័រ និងអភិវឌ្ឍន៍ លេខ១៧ ខែធ្នូ ឆ្នាំ ២០០៥។

ឯកសារនេះលើកឡើងពីការពិភាក្សាលើការជួញដូរដែលផ្អែកលើការរើសអើងយេនឌ័រ និងសក្តានុពលរបស់អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ ដែលជាឯកសារផ្លូវច្បាប់ដើម្បីបង្ហាញពីអំពើហិង្សា និងការជួញដូរលើស្ត្រី។ ឯកសារនេះបានផ្តល់និយមន័យលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទក្នុងការប្រើអំពើហិង្សា និងការជួញដូរស្ត្រី។

៧. **អង្គការលីកាដូ** "ការរំលោភសេពសន្ថវៈ និងការបៀតបៀនកេរ្តិ៍ខ្មាស " ខែមិនា ឆ្នាំ២០០៤ ។

របាយការណ៍នេះធ្វើការរីកញែកព័ត៌មាន ដែលអង្គការលីកាដូបានទទួលតាមរយៈការស៊ើបអង្កេតលើករណីរំលោភសេពសន្ថវៈ និងការបៀតបៀនកេរ្តិ៍ខ្មាសនៅឆ្នាំ ២០០២-២០០៣។ ឯកសារ នេះផ្តោតលើបញ្ហាច្បាប់ និងដំណោះស្រាយលើករណីនេះក្នុងប្រព័ន្ធយុត្តិធម៌។

៨. **អង្គការលីកាដូ** "អំពើហិង្សាលើស្ត្រីនៅកម្ពុជា" ខែមករា ឆ្នាំ២០០៦ ។

របាយការណ៍នេះពិនិត្យលើស្ថានភាពអំពើហិង្សាក្នុងគ្រួសារ អំពើរំលោភសេពសន្ថវៈ និងការជួញដូរស្ត្រីក្នុងគោលបំណងអាជីវកម្មផ្លូវភេទនៅកម្ពុជា នឹងរីកញែកលើការឆ្លើយតបរបស់រាជរដ្ឋាភិបាលចំពោះបញ្ហាទាំងនេះ។ ក្នុងការរីកញែកនោះក៏បានផ្តោតលើច្បាប់ការពារស្ត្រី និងឧបសគ្គចំបងៗដែលកើតមានក្នុងការអនុវត្តច្បាប់ និង/ឬ ការធ្វើកំណែទំរង់។

៩. **អង្គការលីកាដូ** "អំពើហិង្សាលើស្ត្រីនៅកម្ពុជា" ខែមីនា ឆ្នាំ ២០០៧ ។

របាយការណ៍នេះលើកឡើងពីដំណើរជីវិតពិត ដែលស្ត្រីខ្មែរទទួលរងការឈឺចាប់ពីអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ និងការជួញដូរស្ត្រីក្នុងគោលបំណងអាជីវកម្មផ្លូវភេទ។ របាយការណ៍នេះក៏បានផ្តល់ពតិមានថ្មីៗ ដែលទាក់ទងនឹងរបាយការណ៍របស់អង្គការលីកាដូស្តីអំពីអំពើហិង្សាលើស្ត្រីនៅកម្ពុជា ឆ្នាំ២០០៦។

១០. **លីនសេ មារីស** "របាយការណ៍សរុបៈ ស្ត្រី និងប្រព័ន្ធច្បាប់កម្ពុជា" ខែធ្នូ ឆ្នាំ១៩៩៤ ។

របាយការណ៍នេះរីកញែកលើច្បាប់កម្ពុជា ដែលទាក់ទងនឹងបញ្ហាស្ត្រីដោយផ្អែកលើការស្រាវជ្រាវនៅកម្ពុជា (ខែកុម្ភៈ ដល់ ខែសីហា ឆ្នាំ២០០៤)។ របាយការណ៍នេះសំដៅលើប្រវត្តិសាស្ត្រ និងតំលៃវប្បធម៌ទាក់ទងនឹងស្ថានភាពស្ត្រីនៅកម្ពុជា។

១១. **ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន** "ឯកសារគំនិតៈ ការពង្រឹងយន្តការ និងយុទ្ធសាស្ត្រប្រឆាំង នឹងការជួញដូរ" ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០២។

របាយការណ៍ស្ដីពីការឆ្លើយតបរបស់រដ្ឋាភិបាលកម្ពុជាចំពោះការជួញដូរស្ត្រី។ របាយការណ៍នេះបង្ហាញជាទូទៅនូវយុទ្ធសាស្ត្ររបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជនអំពីការជួញដូរលើស្ត្រី ដោយរាប់បញ្ចូលទាំងការទប់ស្កាត់ ការការពារ ការស្តារលទ្ធភាព និងការធ្វើសមាហរណកម្មឡើងវិញ និងការសហការ និងការសំរបសំរួល។

១២. **ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន** "ការស្រាវជ្រាវលើយុទ្ធនាការផ្ដល់ព័ត៌មានពីសំណាក់ភាគី ពាក់ព័ន្ធអំពីការប្រឆាំងនឹងការជួញដូរ ក្នុង៦ខេត្ត-ក្រុងៈ លទ្ធផលដំបូង និងអនុសាសន៍ (អង្គការអន្តរជាតិសំរាប់ជនភៀសខ្លួន ទីភ្នាក់ងារអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជនកម្ពុជា)" ខែមេសា ឆ្នាំ ២០០៤។

របាយការណ៍នេះបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវតាមតំបន់ចំពោះការជួញដូរនៅកម្ពុជា។

១៣. **បណ្ឌិត ដាក់ម៉ា អបប៊ីលី** (**GTZ** - ការលើកស្ទួយសិទ្ធិស្ត្រីនៅកម្ពុជា) "តួនាទី និងដែនកំណត់នៃច្បាប់ជាតិប្រឆាំងនឹងការជួញដូរមនុស្ស" បទបញ្ញត្តិក្នុងសន្និសីទកូរ៉េ ឆ្នាំ២០០៣។

របាយការណ៍នេះធ្វើការពិភាក្សាលើប្រភេទច្បាប់ ដែលអាចយកមកអនុវត្តយ៉ាងមានប្រសិទ្ធភាពក្នុងការប្រឆាំងនឹងការជួញដូរមនុស្ស។

១៤. **ដាយណេ អូកូណែល** "ការរំលោភសេពសន្ថវៈ និងការបៀតបៀនកេរ្តិ៍ខ្មាសៈ បទឧក្រិដ្ឋក្នុងសហគមន៍" របាយការណ៍ពិសេសរបស់អង្គការលីកាដូ ខែកុម្ភៈ ឆ្នាំ២០០១។

របាយការណ៍នេះធ្វើការស្រាវជ្រាវពត៌មាន ដែលអង្គការលីកាដូបានទទួលតាមរយៈការស៊ើបអង្កេតលើករណីរំលោភសេពសន្ថវៈ និងការបៀតបៀនកេរ្តិ៍ខ្មាស ក្នុងចន្លោះឆ្នាំ១៩៩៩ និង ២០០០។ របាយការណ៍នេះក៏បានធ្វើការពិភាក្សាលើករណីរំលោភសេពសន្ថវៈជាក់ស្តែងនៅកម្ពុជា បញ្ហាជាច្រើន ដែលជនរងគ្រោះប្រឈមមុខក្នុងការ ស្វែងរកការតបស្នងតាមផ្លូវច្បាប់ និងមូលហេតុនាំឱ្យមាននិទណ្ឌភាពរបស់ជនល្មើស។

១៥. **វីអេស រីកា** "គំរោងពង្រឹងរដ្ឋលេខាធិការនៃក្រសួងកិច្ចការនារីនៅកម្ពុជាៈ របាយការណ៍ត្រួតពិនិត្យលើច្បាប់ (ក្រមសីលធមិរបស់ស្ត្រីខ្មែរ ឆ្នាំ១៩៩៤)" មូលនិធិអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ដើម្បីស្ត្រី ឆ្នាំ១៩៩៤។

របាយការណ៍នេះលើកឡើងនូវអនុសាសន៍ចំពោះក្រមសីលធមិរបស់ស្ត្រីខ្មែរ សំណើរឆ្នាំ ១៩៩៤ ហើយក៏បានពន្យល់ លើមាត្រានានារបស់ក្រមសីលធមិស្ត្រីខ្មែរ ដែលទាក់ទងនឹងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ និងអនុសញ្ញាទាក់ទងនឹងអង្គការពលកម្មអន្តរជាតិ។

១៦. **អាបីចេល ស្កុរីត**"ការជួញដូរផ្លូវភេទនៅកម្ពុជា" កាសែតកូឡុំប៊ី ទាក់ទងនឹងច្បាប់នៅអាស៊ី ចេញផ្សាយលើកទី១៧ លេខ២ (២០០៣-២០០៤)ទំព័រទី ៣៧១ ដល់ ៤៣២។

ឯកសារនេះធ្វើការរិះគញ្ញែកដ៏ទូលំទូលាយចំពោះច្បាប់កម្ពុជា ទាក់ទងនឹងការជួញដូរផ្លូវភេទ ដែលការរិះគញ្ញែកនេះចេញពីទស្សនៈសិទ្ធិស្ត្រី និងធ្វើការពិនិត្យដ៏ទូលំទូលាយលើស្ថានភាពប្រទេសកម្ពុជា ចំពោះការជួញដូរផ្លូវភេទ។

១៧. **មូលនិធិអភិវឌ្ឍន៍អង្គការសហប្រជាជាតិដើម្បីស្ត្រី ធនាគារពិភពលោក ធានាគារអភិវឌ្ឍន៍អាស៊ី កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ និងនាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស សហការជាមួយក្រសួងកិច្ចការនារី និងអតីតយុទ្ធជន** "ការចែករំលែកប្រកបដោយយុត្តិធមិចំពោះស្ត្រីៈ ការវាយតំលៃលើយេនឌ័រនៅកម្ពុជា" ខែមេសា ឆ្នាំ២០០៤។

របាយការណ៍នេះធ្វើការពិនិត្យជារួមលើអំពើហឹង្សាលើស្ត្រីនៅកម្ពុជា ដោយផ្អែកលើការពិនិត្យពតិមានដែលមានស្រាប់ពីសំណាក់រាជរដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល និងការប្រឹក្សាយោបល់ដ៏ស៊ីជំរៅជាមួយបណ្តាភាគីពាក់ព័ន្ធនានាផងដែរ។

១៨. **លី វិហុតា** (ជំនួយផ្នែកច្បាប់សំរាប់កុមារ និងស្ត្រី) និងអ្នកច្បាប់ផ្សេងទៀត "យេនឌ័រ ការជួញដូរមនុស្ស និងប្រព័ន្ធយុត្តិធមិ ចំពោះបទឧក្រិដ្ឋនៅកម្ពុជា" ការសហការតំបន់អាស៊ីដើម្បីទប់ស្កាត់ ការជួញដូរមនុស្ស ខែធ្នូ ឆ្នាំ២០០៣។

ឯកសារនេះធ្វើការពិភាក្សាតាមដាន ថាតើច្បាប់ជាតិដែលបានតាក់តែងឡើងដើម្បីដោះស្រាយការជួញដូរនៅកម្ពុជាមានលក្ខណៈគ្រប់គ្រាន់ដែរឬទេ។

១៩. **មេលានី វ៉ាល អនុបណ្ឌិតចិត្តវិទ្យា** "របាយការណ៍ពីស្ថានភាពស្ត្រីនៅកម្ពុជា: អំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានផ្លូវភេទ និងការជួញដូរក្នុងគោលបំណងអាជីវកម្មផ្លូវភេទ" គំរោងស្តីពីសិទ្ធិស្ត្រីនៅកម្ពុជា: ភាពជាដៃគូ : អង្គការ លីកាដូ -ជាមួយ **UQAM** ខែមីនា ឆ្នាំ២០០៧។

របាយការណ៍នេះបង្ហាញពីស្ថានភាពស្ត្រីនៅកម្ពុជាក្នុងភាពជាឯកជន និងសាធារណៈ ពិសេសផ្តោតទៅលើការប្រើអំពើហិង្សាលើយេនឌ័រ។ របាយការណ៍នេះក៏បានពិនិត្យមើលក្របខ័ណ្ឌច្បាប់ដែលទាក់ទងនឹងការប្រើអំពើហិង្សាលើស្ត្រី ដោយមានការពន្យល់ពីខ្លឹមសារច្បាប់ និងបង្ហាញពីឧបសគ្គនានាក្នុងការអនុវត្តច្បាប់នោះ។ របាយការណ៍នេះក៏បានផ្តល់ពត៌មានអំពីធនធានរបស់ជនរងគ្រោះ និងយុទ្ធសាស្ត្រការពារដែលបង្កើតដោយសហគមន៍ អាជ្ញាធរដែនដី និងអង្គការមិនមែនរដ្ឋាភិបាលនានា។

២០. **តាកាស៊ី យ៉ាស៊ុនណូប៊ុ** "ប្រឆាំងនឹងការជួញដូរមនុស្សនៅកម្ពុជា: បង្កើតច្បាប់ដើម្បីចាត់វិធានការឱ្យមានប្រសិទ្ធិភាពចំពោះការប្រឆាំងនឹងការជួញដូរមនុស្ស" ឯកសារដែលត្រូវបំពេញដើម្បីទទួលបានថ្នាក់អនុបណ្ឌិតផ្នែកអភិវឌ្ឍន៍អន្តរជាតិប្រកបដោយចេរភាព នៅនាយកដ្ឋានគោលនយោបាយសង្គម និងការគ្រប់គ្រង នៃសាកលវិទ្យាល័យ ប្រែនឌី ខែឧសភា ឆ្នាំ២០០៤។

ឯកសារនេះធ្វើការពិភាក្សាលើក្របខ័ណ្ឌច្បាប់កម្ពុជា ដែលទាក់ទងនឹងការជួញដូរស្ត្រី និងកុមារដោយបញ្ចូលទាំងការវែកញែកប្រៀបធៀបរវាងច្បាប់ជាតិដែលពាក់ព័ន្ធជាមួយនឹងក្របខ័ណ្ឌ ជាមួយនឹងក្របខ័ណ្ឌច្បាប់ផ្សេងៗ ក៏ដូចជាបទដ្ឋានអន្តរជាតិផ្សេងៗទៀត និងបានធ្វើការរិះគន់ចំពោះការអនុវត្តន៍ច្បាប់ផងដែរ។

# ឧបសម្ព័ន្ធទី ២: សមាជិករបស់ CAMBOW

| ល.រ | ឈ្មោះអង្គភាព | បុគ្គលទំនាក់ទំនង | អាស័យដ្ឋានទំនាក់ទំនង |
|---|---|---|---|
| ០១ | សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា **(ADHOC)**<br>Cambodian Human Rights and Development Association | Mr. Thun Saray, President<br>Ms. Lim Mony, Women Project Coordinator | 016 880 509<br>012 834 449<br>Email: adhoc@forum.org.kh |
| ០២ | អង្គការបន្ទាយស្រី **( Banteay Srei)**<br>Banteay Srei | Ms. Chhoeun Thavy, Executive Director<br>Ms. Chhun Sarorn, Advocacy Program Officer | 012 932 357<br><br>011 615 483<br>Email:<br>banteaysrei@online.com.kh |
| ០៣ | ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា **(CDP)**<br>Cambodian Defenders Project | Mr. Sok Som Oeun, Executive Director<br>Ms. Meas Sokhom, Women chief department | 012 901 199<br><br>092 938 083<br>Email:<br>samoeun_sok@cdpcambodia.org |
| ០៤ | មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម **(CSD)**<br>Center for Social Development | Ms. Seng Theary, Executive Director<br>Ms. Eam Sivnin, Personal Assistant | 012 222 552<br><br>012 1993 118<br>Email: theary@csdcambodia.org |
| ០៥ | អង្គការជំនួយកុមារ និងស្ត្រីជនបទ **(CWARO)**<br>Organization for Children and Rural Women | Ms. Lim Davy, Executive Director | 012 821 178 |
| ០៦ | អង្គការកម្ពុជា ដើម្បីជួយស្ត្រីមានវិបត្តិ **(CWCC)**<br>Cambodian Women's Crisis Center | Mrs. Nup Sarin Sreyroth, General Secretary<br>Mrs. Sin Lypov, Shelter Manager | 012 947 186<br><br>011 976 839<br>Email: cwccpnp@cwcc.org.kh |
| ០៧ | សម្ព័ន្ធស្ត្រីកម្ពុជា ដើម្បីអភិវឌ្ឍន៍ **(CWLD)**<br>Cambodian Women League for Development | Ms. Sorn Dy Deline, Deputy Director<br>Ms. Tith Vandy Executive Director | 011 889 920 or 012 942 692 |
| ០៨ | មជ្ឈមណ្ឌលកម្ពុជា ដើម្បីការពារសិទ្ធិកុមារ **(CCPCR)**<br>Cambodian Center for the Protection of Children's Rights | Ms. Tep Sopheap, Trainer<br>Mr. Yim Po, Executive Director | 012 963 907<br>Email: ccpcr@online.com.kh |
| ០៩ | សមាគមអភិវឌ្ឍន៍វប្បធម៌ស្ត្រីកម្ពុជា **(CWCD)**<br>Cambodian Women's Culture Development | Mrs. Heng Sovuthy, Executive Director | 012 891 153<br>Email: sovuthy_cwcd@yahoo.com |
| ១០ | ភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីកម្ពុជា **(CWDA)**<br>Cambodian Women's Development Agency | Ms. Serey Mealy, Counselor<br>Mrs. Kean Sereyphal, Executive Director | 012 824 957<br>Email: cwda@online.com.kh |
| ១១ | មជ្ឈមណ្ឌលកម្ពុជាសង្គ្រោះទុរគតជន និងអភិវឌ្ឍន៍ **(CDRCP)**<br>Cambodian Development and Relief Center for the Poor | Mrs. Leng Sothea, Executive Director | 012 651 123<br>Email: cdrcp@online.com.kh |

| | | | |
|---|---|---|---|
| ១២ | អង្គការខារាមកម្ពុជា **(CARAM Cambodia)**<br>Coordinator of Action Research on AIDs and Mobility | Mr. Ya Navuth, Executive Director | 012 961 427<br>Email: caram.cam@online.com.kh |
| ១៣ | សមាគមអភិវឌ្ឍន៍កម្ពុជា **(DAC)**<br>Development Association of Cambodia | Ms. Po Tieng, Executive Director | 016 555 144 / 012 543 209<br>Email: potieng@yahoo.com |
| ១៤ | សមាគមវិចិត្រសិល្បៈ **(FAA)**<br>Fine Art Association | Mr. Hang Puthea, President<br>Mr. Ne Sony, Vice President | 012 959 666<br>012 987 676<br>Email: nicfec@wicam.com.kh |
| ១៥ | អង្គការយេនឌ័រ និងការអភិវឌ្ឍន៍ដើម្បីកម្ពុជា **(GAD/C)**<br>Gender and Development for Cambodia | Mrs. Ros sopheap, Executive Director | 012 627 857<br>Email: gad@online.com.kh |
| ១៦ | អង្គការហាការ **(HAGAR)**<br>Hagar Project | Ms. Soun Samnieng, Assessment Center Manager<br>Ms. Elise Elzinga, Research and Advocacy | 012 202 894<br>Email: soun.samnieng@hagarproject.org<br>092 429 516<br>Email: elise.elzinga@hagarproject.org |
| ១៧ | សមាគមឥន្ទ្រទេវី **(IDA)**<br>Indradevi Association | Mrs. Dy Ratha, President | 012 897 161<br>Email: indra@camshin.com.kh |
| ១៨ | វិទ្យាស្ថានខ្មែរសំរាប់លទ្ធិប្រជាធិបតេយ្យ **(KID)**<br>Khmer Institute for Democracy | Ms. Nay Dina, Executive Director | 011 924 286<br>Email: director.kid@online.com.kh |
| ១៩ | អង្គការខេមរា **(KHEMARA)**<br>Khemara | Ms. Koy Phallany, Executive Director | 012 927 279<br>Email: khemara@camnet.com.kh |
| ២០ | មជ្ឈមណ្ឌលសំលេងស្ត្រីខ្មែរ **(KWVC)**<br>Khmer Women's Voice Center | Ms. Yim Nimola, Executive Director | 012 919 099 or 016 396 699<br>Email: kwvc@forum.org.kh |
| ២១ | សហប្រតិបត្តិការស្ត្រីខ្មែរ ដើម្បីអភិវឌ្ឍន៍ **(KWCD)**<br>Khmer Women's Cooperation for Development | Mrs. Sum Satum, Executive Director | 012 866 617<br>Email: kwcd@online.com.kh |
| ២២ | អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ **(LICADHO)**<br>Cambodian League for the Promotion and Defense of Human Rights | Dr. Pung Chhiv Kek, President | 012 802 506<br>Email: contact@licadho.org |
| ២៣ | អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា **(LAC)**<br>Legal Aid of Cambodian | Mrs. Peung YorkHiep, Executive Director<br>Mr. Lao ChhunThy, Vice Director | 012 823 745<br><br>012 807 236<br>Email: lacdirector@online.com.kh |
| ២៤ | អង្គការមាតាខ្មែរអភិវឌ្ឍន៍ **(MKD)**<br>Meada Khmer Development | Ms. Tep Savery, President<br>Ms. Prom Mon, Administrative Chief | 012 728 049<br>012 390 843<br>Email: tepsavery@online.com.kh |
| ២៥ | អង្គការព្រហ្មវិហារធម៌នៃមាតា **(MLNV)**<br>Mother's Love and Non Violence | Mrs. Nou Sambo, Executive Director | 012 880 193 |
| ២៦ | គណៈកម្មាធិការអព្យាក្រឹត្យនិងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរីនិងត្រឹមត្រូវនៅកម្ពុជា **(NICFEC)**<br>Neutral and Impartial Committee for Free and | Mr. Hang Puthea, President<br>Ms. Tim Sisoda; Program Officer | 012 959 666<br>012 544 931<br>Email: nicfec@wicam.com.kh |

| | | | |
|---|---|---|---|
| | Fair Election in Cambodia | | |
| ២៧ | អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ **(PADV)**<br>Project Against Domestic Violence | Mrs. Hor Phally, Executive Director | 012 838 721<br>Email: padv@online.com.kh |
| ២៨ | អង្គការស្តារកម្ពុជា **(STAR kampuchea)**<br>STAR Kampuchea | Mr. Nhek Sarin, Executive Director | 011 725 873<br>Email: star-director@starkampuchea.org.kh |
| ២៩ | ក្រុមកិច្ចការពិសេសសិទ្ធិមនុស្សកម្ពុជា **(TASK FORCE)**<br>The Cambodian Human Rights Task Force (CHRTF) | Ms. Uth Malen, Executive Director | 012 566 475<br>Email: chrtf@forum.org.kh |
| ៣០ | ក្រុមប្រតិបត្តិការអភិវឌ្ឍន៍តំបន់ជាយក្រុង **(USG)**<br>Urban Sector Group | Mr. Lim Phay, Executive Director<br>Ms. Tun Somphy, Project Coordinator | 012 859 226<br><br>012 636 768<br>Email: usg@forum.org.kh |
| ៣១ | សមាគមយុវជនស្ម័គ្រចិត្ត ដើម្បីលទ្ធិប្រជាធិបតេយ្យ **(VYCD)**<br>Volunteer Youth Congress for Democracy | Mrs. Chin Sokha, President | 011 871 388 or 012 404 045<br>Email: 012998639@mobitel.com.kh |
| ៣២ | អង្គការប្រឆាំងអំពើហិង្សាលើស្ត្រី និងកុមារកម្ពុជា **(VAWCC)**<br>Violence Against Women and Children of Cambodia | Mrs. Ek Pra Neith, Executive Director | 092 982 292 |
| ៣៣ | មជ្ឈមណ្ឌលនាវាថ្មី **(WVC)**<br>Neavea Thmey Center | Mr. Nhim Sambath, Trauma Project Manager | 012 817 721<br>Email: sambath_nhim@wvi.org |
| ៣៤ | អង្គការសេវាស្ត្រី **(WOSO)**<br>Women Service Organization | Ms. Srey Sokhon, Executive Director | 012 688 364<br>Email: sokhon_woso@hotmail.com |

CAMBOW